# ពិម្ពានិព្វាន

## ភាគ១



ចម្លងដោយៈ

បណ្ណាគារអ៊ែត្រូអេង

ពោធិសត្វនិងនាងពិម្ពាកាលកើតជាជនទុគ៌ត
បានបរិច្ចាគទានចំពោះព្រះសាវ័ះប្រាថ្នាជាពុទ្ធភូមិ

ផ្ទះលេខ ១៣៦ E0 វិថីខេមរភូមិន្ទ រាជធានី ភ្នំពេញ

ព.ស. ២៥៤២ គ.ស. ១៩៩៨

អំណោយពីលោក ឡៅ ឃុនសិរីវ័ឍ ដល់គារណាទ្បែរ
សម្រាប់ដាក់ទុកក្នុង Library of Cambodia.

# ពិម្ពានិព្វាន

អ្នកឧកញ៉ាវិបុលរាជសេនា

នូ - កាន

រៀបរៀង

បោះពុម្ពលើកទី ៣

ព. ស. ២៥០៣ គ. ស. ១៩៦០

សម្បត្តិ របស់រោងពុម្ពខេមររដ្ឋ

# រឿងពិម្ពានិព្វាន

កាព្យពាក្យ ៨

សូមបង្គំព្រះបរមត្រៃលោកនាថ ជាកំពូលមោលីតួ លោកណាថុ នរជនជាតិទាំងពួងសឹងវន្ទា ។ ព្រោះព្រះគុណាប្រកបនែបនាំសត្វ រំលងកាត់វដ្តភាលជ្រៀលធំធារ គឺអន្លង់ឱឃោសាគរា ដាក់ដល់នាអមតរដ្ឋបុរី ។ សូមបង្គំធម្មោត្តបរិយត្តិ តួបដិបត្តិបដិវេធភេទភូមិបី ជាសំពៅជ្រៅជ្រោះទសបារមី នាមពោធិបក្ខិយលៃផ្ទុកសត្វ ។ សូមបង្គំចំពោះអស្តាសីយ លោកយាងត្រង់អង្គផ្សិវទៅអម៉ត ព្រះរតនទាំងបីថ្លៃថ្លាក្តាត់ ទ្រង់កំចាត់កាត់ជ្រិះអស់អវិជ្ជា ។ ខ្ញុំបង្គំចំត្រង់ព្រះអង្គនោះ ដោយចិត្តលុះផ្ទុះផើតកើតសទ្ធា វេញកនឹកគុណណាស់ប្បាស់ក្នុងនា មនោទ្វារភ្លឺស្វាងក្រចាងថែង ។ ទើបអញខ្ញុំសុំលើកល្បើកព្រះជាតិ ព្រះនាងនាថពិម្ពាជាគម្តែង ត្រង់គារនិព្វានប្រោរាណភាថ្លៃរ ទុកតាក់តែងជាក្រោយឱ្យជ្រះថ្លា ។

សម័យនេះខ្ញុំនិះប៉ុះសំរួល ជាពាក្យជួនជូនផ្ទេរកែបញ្ញា
ប្រាប់ពាក្យភាគបួនម្ហូនមាត្រា — គឺខេមរាន់ស្រាយរាយ
រឿងកាត់ ៗ តក្រៃប្រែតាមស្យាមភាសា ដែលព្រះអង្គ
សុមារតីក្សត្រិ ក្នុងព្រះកេតុជេដ្ឋាធីតាបាត់ ទ្រង់អនុ
វត្តព្រះទានមានប្រាប់ ៗ លេមសមុតឈុតបម៉ោបរះធ្យាន
ឈ្មោះពិម្ពានិញាននិទានស្ដី មេប្រាពីរជាតិកំណើតស្រី
សវនីយ៍ផ្ទើយទូលព្រះសាស្ដា ៗ ហើយបង្គំសុំទោស
ព្រះអរិរាបថ យកតែជាតិលោកប្លែកឯកអស្ចារ្យ គឺកំសត់
អត់ឃ្លានធ្វើទានញ្ញ ទាំងខំអាប្រមាទឡ្យាតខុស ៗ
កំតីពីរលិវត្តិពុទ្ធបរិវារ ជាសង្ឃតិកាបារ្យបញ្ចុះ រួមបញ្ចូល
ពោលយកមកបណ្ដុះ ផ្សំបម្រុះរឿងណាគួរនិយាយ ៗ
ដើមកំណើតជាតិព្រិនអនន្តា ហួសភិសតាអ្នកក្រោយ
ឃើញពោយពាយ ទោះតឹងព្រិសរើសរៀនបានរឿងរាយ
ជ្រៅទូលាយឆ្ងាយណាសរ៉ះមិនគ្រប់ ៗ

ខ្ញុំភូឈ្មួយសេនាបតីហ្លួង ឧុទ ក្រសួងជើងទឹកតឹក
ប្រាវត្តិ មានស្រីប្រាវម្ភសរំដ៏ក្រែះល៉ីសលប់ ក្រែងជំពប់ជំពាក់
ហ៊ាក់ឧបមា ។ ព្រោះកំណាព្យកាព្យក្លួនមានឃ្លាល្បះ
លោកអ្នកចាស់បុះក្រងបងរបនា តែងនឹងធៀបប្រៀប
ប្រាយដោយភេហារ តម្រូវប៊ាះដោយខ្លួនទាំងបួនបាប ។
ជួនក៏ជួនមិនស្រួលពានដំដែល យកប្រហែលទាំងសៀង
ទៀងតាមខ្នាត ទើបកម្រើគិតអានឲ្យបានស្អាត តែងតែ
ខាតកន្លះខ្វះសំដី ។ មួយយ៉ាងទៀតខ្ញុំឆ្លៀតគិតរៀបបំ
ពោលបន្សំទំនង់យោងជាថ្មី ក្រង់និរាសប្រាសព្រាត់
វង្គបុរី ភាប់បក្សីបក្សាមាត់កាំភ្លាន ។ ឬប្រលូងប្រលោម
លោមកាមគុណ ទាំងសោកសុនខ្មេញម្ញេញរំខាន
ក៏ត្រូវប៉ះទាំតាមស្មាមលំអាន ពាក្យប៉ុន្មាននេះសង្កង
មុសា ។ ហេតុនេះខ្ញុំសុំទោសសព្ទោសទុក តទៅមុខ
កុំមានបានតវ៉ាហោ ជាជំនៀលដល់លោកអ្នកប្រាជ្ញា

ជាទំជាតាមចិត្តទៅតាមអ្វី ៗ ហើយនឹងសូមខមាលា
បាបកម្ម ពីសីលប្រាកម្មបថសុចរិតបី សូមសម្ម
ស្ថិតសុវត្ថិ ជាសិរីមង្គលដល់ខ្ញុំផង ៗ

ដំណាលកាលព្រះនាងនាថពិម្ពា ទ្រង់ផ្នួសជាថេរី
ស្រីជាច្បង ព្រោះនាងមានញាណព្រឿយុវិកថ្លង់ លើស
ពួកកងសាវិកានាងភិក្ខុនី ៗ ព្រះនាងបែកបដិសម្ភិទា
នឹងអភិញ្ញាសមាបត្តិប្រាំបី ស្មើព្រះអគ្គសាវកហ្លួសព្រាក
ស្រី ដោយបារមីត្រកព្រាក់ប្ញាស់ធម្ម ៗ ព្រះនាងជ្រាប
បុព្វេនិវាសញ្ញាណ ជានឹងចូលនិព្វានសុទ្ធខន្ធ តែ
និទានគ្មានជាព្រះពិម្ពា មានព្រះពុទ្ធលោកគោះប្តូរ ៗ
ព្រះនាងទ្រង់បានជ្រាបសភាពជាក់ ទ្រង់សៀកពាក់ចីវរ
លើព្រះហាន ជាបរិមណ្ឌលយល់ជើងជាន នាងក៏បាន
យាងដល់ព្រះប្រថាប់ ៗ ក្នុងវិហារជេតពនគន្ធកុដី ពួក
ភិក្ខុនីទាំងពាន់ហែហមនៅខាប់ ព្រះនាងយាងចូលដល់

បល្លង្កស្រាប់ ក៏ឱនអភិវាទព្រះនាថា ។ ព្រះនេត្រនាង
ទតសង្កេតយល់ ព្រះទសពលមុនីមោលីកា មាន
ឆព្វណ្ណរង្សីថ្លៃភ្លឺថ្លា ព្រះកញ្ញាពិនិត្យរំភើបរវង់ ។
ដោយអាការទ្ធិតឹងស្រឹងស្រៀបស្រស់ ពេញជាមហាបុរស
លក្ខណ៍បក្រិតពង្ស ព្រះនាងនឹងសរសើរពីរោះទ្រង់
ឆ្នួនអាគង់ស្លូតគិតរឹតជ្រះថ្លា ។

ខណៈនោះព្រះមុនិន្ទពិនត្រៃភព ទ្រង់ជ្រាបរព្វជ្រាប
ចិត្តរាជកញ្ញា បង់កាយគន់សង្កេតព្រះនេត្រា ទត
លក្ខណាព្រះរូបព្រះជិនស្រី ។ ទើបទ្រង់ផ្សាយឆព្វណ្ណ
រាត់រុងរឿង ស-ក្រហម-ខៀវ-លឿង-បៃតងខ្ចី អន
កណ្តៀងរៀងគ្នាជារង្សី មានរស្មីផ្ទុះដីទឹកមេឃា ។
សឹងតែបេញវេញជុំសព្វាង្គ ពេញព្រះកាយរូបរស់ព្រះឈ្នះ
មារ លើសសុរិយចន្ទបរលើវេហាស ព្រះពិម្ពាទត
ជាក់ភ្លឹកស្ញប់ស្ញែង ។ ទើបលំអុតលំទោនឱនព្រះអង្គ

លើកកំបង់អញ្ជលីភ័ទ្រថ្លែង ហាបពិត្រព្រះបកុណផុតភព ស្តែង ខ្ញុំអម្ចាស់ច្បាស់ថែងនឹងនេត្រា ។ ឃើញព្រះអង្គ រុងរឿងយ៉ាងអនេក ពេញជាឯកអគ្គត្រូលោកា វេលា នេះខ្ញុំម្ចាស់អស់ភិសគា បួលមកសូមខមាទោសព្រះអង្គ ។ ដ្បិតអាការព្យាធិគឺលានរោគ ប្រជុំជោគមកជួបរួបរួម ស - ង្ហារឲ្យខន្ធខ្ញុំម្ចាស់វិនាសបង់ ពុំតម្រង់លង់យូរ តទៅបាន ។ ហេតុដូច្នេះខ្ញុំម្ចាស់សូមព្រះអង្គ ប្រោស លះបង់សង្គ្រោះទោសប៉ុន្មាន ដែលខ្ញុំម្ចាស់ល្មើសលើក ហួសហេវហាន ពីបោរាណបានភពប្រសប់គ្នា ។ ដ្បិត ខ្ញុំម្ចាស់នេះបានប្រាណជួបជាប់ គ្រប់ភពជាតិកើតរាប់ មិនបប់ឃ្លា បានប្រមាទខាតខុសព្រោះពិម្ពា គួសម្ភារ កសាងខាងបារមី ។ មុនខ្ញុំម្ចាស់លះខន្ធកាន់និព្វាន សូមព្រះទានទោសទាស់ព្រោះសំដី ឬខុសខាងកាយ ចិត្តល្អិតផងស្រី សូមខន្តីលៃលោះប្រោសមេត្តា ។



ខ្ទមលំហរនៃជនទុគ៌ត

ទោះយោបីស្រីខុសឆ្គោះអតីត ឬបច្ចុប្បន្នគន់គិតភ្លាត់ត្រង់
ណា ដោយបំពោះព្រះភក្ត្រដាក់អស្វារ្យ ឬដោយការ
កំបាំងសំងំពុំល្អ ។ ក៏សូមទ្រង់បង់បោះអស់វេរា ឲ្យ
ពិម្ពាខ្ញុំម្ចាស់ជ្រះទោសគត់ នឹងសូមលានិព្វានសូន្យដំណរ
ដោយស្មោះសរបរិសុទ្ធផុតទោសា ។ បង្គំភ្លាងព្រះនាង
ប្រណាម្យហត្ថ សំដែងអត្ថបាលីនៃគាថា អតីតេក្រើ
កាលព្រះសាសនា អង្គព្រះព្រហ្មសម្មាសម្ពុទ្ធត្រាស់ ។
ខ្ញុំព្រះអង្គនឹងទ្រង់បង្កើតជា អ្នកកំព្រាទុគ៌តខ្សត់ពេក
ណាស់ ក្រទាំងប្ដីប្រពន្ធវណ្ណាស្លៀកប៉ះ សុំពីព្រឹក
ល្ងាចខ្វះផ្ទះនៅគ្មាន ។ ជ្រកតែខ្ទមលំហរសសរបាក់
គ្មានមាសប្រាក់ដើមទុនជាធនបាន ស្រូវអង្ករក៏អត់រឹត
ស្រែកឃ្លាន ស្មើរតែដើរសុំទានគេអាស្រ័យ ។ តាំងពី
ភពប្រសប់ប្ដីប្រពន្ធ សែនទុរន់ធ្ងន់បុះហួសវិស័យ ជន
ទាំងពីរនិយាយដោយក្រៃក្រៃ ថាយើងក្រយូរថ្ងៃខែឆ្នាំ



កាលព្រះនាងកើតជាជន

កំសត់ទុគ៌ត ស្វាមីភរិយា នាំគ្នារែកឧសលក់

ហើយ ។ គួរតែខំនាំគ្នារកកាប់ឧស ក្នុងព្រៃបុស្សបេះស្លឹកឈើជាត្រើយ យកមកដូរលក់កុំទុក្ខឡើយ គង់នឹងស្បៀងឲ្យគ្រាន់បានអាហារ ។

ថ្ងៃមួយនោះបុរសប្តីប្រពន្ធ ដើរទៅគន់បានកាប់ឧសបេះផ្កា យកមកដូរបានស្បៀងសៀងអាត្មា បានភោក្តព្រឹកល្ងាចរួចស្រេកឃ្លាន ។ តាំងពីនោះស្រុះចិត្តប្រពន្ធប្តី ស្វែងរបរតបីខែប្រជាន បុណ្យនិស្ស័យឲ្យត្រូវទៅជាមាគ ទទួលទានឆ្អនឆ្អែតតិតឯខ្វះ ។ លុះបំណោរភរិយានឹងស្វាមី មានប្រក្រតីខ្មីឃ្មាតសង្វាតណាស់ រកអម្រែស់ឧសភ្លើងគ្រឿងបូរឆ្លាស់ ក៏ដើរទៅប្រទះនឹងព្រះសង្ឃ ។ នៅក្នុងព្រៃអរញ្ញជាទីស្ងាត់ លោកជាព្រះអរហាត្តប្រព្រឹត្តត្រង់ ជនទាំងពីរប្លាជ្រះលុះចិត្តបង់ បេះបុប្ផាទៅបង្គំបូជា ។ ព្រះសាវ័កស្រាកស្រួលទទួលទស់ ហើយសង្គ្រោះព្រោះជ្រាបភាពឬកពា



ជនទាំងពីរនាក់ស្វាមីភរិយាមានសទ្ធាជ្រះថ្លា បេះបុប្ផ
នឹងផលាផល បូជាចំពោះព្រះសាវក

ជាជាពោធិសត្វសុទ្ធសទ្ធា ផងទាំងពីរក៏លាមកទ័ឋាន ។ តពីនោះបុរសលុះសទ្ធា នាំភរិយាទៅធ្វើកុដិបាន នៅកណ្តាលទួលទីព្រៃស្មសាន ហើយប្រិមាណគិមន្តលោកគង់ខ្ញី ។ ដោយផលានិសង្សអង្គពោធិ៍ ព្រមទាំងពីរនរជនប្រពន្ធប្តី ព្រះពិស្ណុការនិម្មិតប្រាសាទស្រី ព្រមទាំងបីដើមផ្កាបក់ប្បព្រឹក្ស ។ ជនពីរប្រាណមានហ៊ាន ទីប្រសិទ្ធ តាមប៉ុនបំត្តប្រាថ្នាសច្ចានឹក ក៏ទៀងជាសេដ្ឋី ថ្លៃពន្លឹក មានសន្លឹកប្រាក់មាសលើសលោកិយ ។

ហេតុដូច្នោះទោះកម្មខ្ញុំពីម្តា កាលដែលជាទុគ៌ត ខ្សត់ក្រក្រី បានប្រមាទខាតខុសព្រោះខ្ញុំស្រី ធ្វើព្រះអង្គជាប្តីឲ្យអន់អាក់ ។ សូមព្រះអង្គទ្រង់ប្រោសលើកទោសកា ដោយនូវកាយវាចាចិត្តថ្លាំងថ្នាក់ បន្ទូលភ្លាងព្រះនាងនាថ វរលក្ខណា នាំដំណើរជាវគ្គទូលទៀតថា ។ ជាបពិត្រ ព្រះមកុដផុតត្រៃភព កាលយូរលប់កប្បខ័ណ្ឌអនន្តា

នោះព្រះអង្គទ្រង់កើតជាក្សត្រា នាមព្រះមហានន្ទរាជ អំណាចណាស់ ។ ខ្ញុំពិម្ពាជានន្ទីមហេសី គ្រងបុរីរដ្ឋណាពុំច្បាស់ ព្រះអង្គទ្រង់មនោរម្យនឹងខ្ញុំម្ចាស់ កាលសាសនាអង្គព្រះព្រហ្មសាមី ។ មានសម័យថ្ងៃមួយមហាក្សត្រា ស្តេចយាត្រាប្រពាតឃ្លាតបុរី ព្រមព្រះនាងនន្ទីអគ្គមហេសី នឹងសេនីយសេនាយោធាហាន ។ កាលទៅដល់មណ្ឌលទីអធ្វា ព្រះជាយាបែរនេត្រទតកំសាន្ត ឃើញផ្កាវាំងក្នុងទីរហោឋាន នាងកល្យាណមានចិត្តគិតប្រាថ្នា ។ បង់នឹងបេះប្រឡេះរើសផ្កាវាំង យកមកតាំងគ្រឹបក្រងចងហត្ថា ទើបនាងត្រាស់ប្រាសប្រើពលសេនា ឲ្យប្រភាភារឡើងវាំងខ្ពង់ខ្ពស់ ។ ឯព្រះមហាក្រសត្រខត្តិយាវង្ស កាលដែលទ្រង់ឮនាងមនោរស ក៏អាស្សូរមហេសីស្រីទ្រង់យស ព្រះអង្គដោះព្រះមកុដរត្នមាលា ។ ឡើងចុះវាំងភ្លាងនឹងព្រះអង្គឯង

ហើយកាច់ស្មែងផ្ការីកបែកគន្ធា  មកព្រះទានសម្ដេច
ព្រះជាយា  នៅក្នុងគ្រានោះព្រះអាណាពិតស្រី ។ ដោយ
អាការស្រឡាញ់ពេញចំណង់  មិនគិតនឿយព្រួយអង្គ
ពង្សនរបតី  ហេតុដូច្នេះសូមព្រះប្រោសប្រណី  លើក
សេចក្ដីកំហុសខុសពិម្ពា ។ ទើបព្រះនាងទៀងទូល
ទំនួលថ្លែង  កាលអង្វែងព្រេងជាតិទ្រង់កើតជា  ពៅ
មាណពមួយនោះលុះសុទ្ធា  បានទៅបួសផ្នួសជាមហា
ឥសី ។ ខំចំរើនឈានឆាប់ជាប់ទាំងអស់  បានធ្យាន
ហោះផ្លោះភ្លាមតាមលោកិយ  គង់នៅក្នុងគោហាជា
ប្រក្រតី  ខ្ញុំជាស្រីបរិសុទ្ធបុត្រកុដុម្ពី ។ ក្នុងឱកាស
សាសនាព្រះជាគ្រូ  សយម្ភូវនាបជាតិមុនី  ខ្ញុំអាយុ
សោឡសស្រស់ឆើត  ពាលពេញទីក្រមុំទំនេរនៅ ។
សម័យមួយធីតាយាត្រាត្រាច់  ដើរទៅកាប់កាប់ឧសក្នុង
ជ្រោះជ្រៅ  ជាកណ្ដាលទីព្រៃស្រីពាលពៅ  តឹក ៗ ទៅ

ស្រណោះអាណោះលន់ ។ ទើបប្រភិភរស្ទៀងបុងឈើ
ខ្ពស់ ហើយពិគ្រោះព្រោះតាមកាមទមួន ក៏បញ្ចេញ
សូរសៀងច្រៀងអង្រិន់ ពាក្យក៏ទន់លន្លោចព្រួចពីរោះ ។
ឯឥសីសេដ្ឋោពោធិសត្វ បានសមាបជិបត្តិប្រព្រឹត្តខ្ពស់
ក៏ចូលឈានធ្យានបោះផ្លោះកាត់ជ្រោះ ឲ្យមានមោះព្រោះ
ឮសំឡេងស្រី ។ ច្រៀងក្រលួចព្រួចប្រុងក្នុងអង្គប្រាណ
ទប់ពុំបានឈានភ្លឹកធ្លាក់ដល់ដី ដើរទៅស្តាប់ចាប់ចិត្ត
គិតបេតី មហាឥសីស្តីបង់នាងនោះណា ។ ហេតុ
សម្ផស្សស្សូរបបំពើបថ្មី មហាឥសីទឹងនាងកំពុងភ្លា
ក៏បង្ខំសំរេចកិច្ចតណ្ហា មុខអស្ចារ្យគួរខ្លាចអំណាចកាម ។
ទោសទាំងនេះក៏ព្រោះឈ្មោះខ្ញុំម្ចាស់ ដើរស្វែងសួះទៅ
ច្រៀងព្រះផ្ទៀងចាំ ស្តាប់ឮជាក់ធ្លាក់ឈានខានឧបត្ថម្ភ
ខុសបំណាំតាំបាបជាបដោយទុក្ខ ។ ឥឡូវនេះខ្ញុំម្ចាស់
សូមព្រះអង្គ ប្រោសលះបង់សង្គ្រោះទោសខ្ញុំមុខ

ទូលបប់ភ្លាងព្រះនាងនាំទំនុក លំដាប់យុគយូរណាស់ ត្រាសទៀតថា ។

អតីតេ កាលេ កាលពុទ្ធោ សុមនោសព្វញ្ញុតពុទ្ធាចារ្យ ខ្ញុំអម្ចាស់នឹងព្រះអង្គនេះណា វិលកើតសាជាត្រីអណ្តែងងាំង ។ ព្រះជិនស្រីជាត្រីអណ្តែងឈ្មោល ខ្ញុំក៏យោលជាញីគូជីវិ នៅនឹងគ្នាយូរលង់ក្នុងត្រពាំង ទាំងខួបប្រាំងវិស្សាជាទិវន្ត៍ ។ គួបិច្ចាស្នាគម្យូរូបរស លុះមានពោះនោះនាងមានទម្ងន់ នឹកចង់ស៊ីយាប្លងទងទង់ៗ ក៏គិតគន់ដណ្តឹងទៅឈ្មោលថា ។ ភាណអើយ ភាណាប្អូនឃ្លានឲ្យយាប្លង ធ្វើម្តេចម្តងបងរកមកឆាប់រ៉ា ឲ្យខ្ញុំប្អូនបានស៊ីជាអាហារ ព្រោះប្អូនឃ្លានណាស់ណាគួរអាណោត ។ ឯត្រីឈ្មោលបានព្រមបះបា កើតមេត្តាជាខ្លាំងនៅក្នុងចិត្ត ហើយលោមលាត្រីញីពីរឿងរឿត ចេញទៅតាមបរិតដែលគិតបង ។ ជួនជិតនន់ជិត

ទឹកពន្លឹកខ្លាំង លិចត្រពាំងបឹងប្លូទន្លេផង ត្រីអណ្ដែងង
ឯងអាចហាចហែលឆ្លង ទៅតាមដងវង្កះឆ្ងាយណាស់សា
មានអន្លង់បឹងមួយជុំទ្រួយស្មៅ អណ្ដែងស្មៅទៅដល់
យល់ស្លឹកផ្កា ទ្រួយយាប្លងក៏ខាំពារីលឆ្លា បង់ប្រាជ្ញា
តំងយកមកឡើញ ៗ អតិប្ចាមិប្លាអណ្ដែងជាំង ខំរលះ
រលាំងហែលឆ្លងទី បៀមយាប្លងក្នុងមាត់ពុំទំហែលរ៉
មកជិតដល់ ដលធីក្បៀររង្វះ ។

វេលានោះគ្រោះជួនព្រានប្រមង់ ដើរមកត្រង់ជ្រើង
ស្រែប្រែប្រទះ ឃើញអណ្ដែងវែងស្ដឹងប្រឹងរលះ ស្ទុះ
ទៅពះប្រញាប់កាប់ត្រូវត្រី ៗ ជាប់កន្ទុយស្ទុយពោរព
ផ្លោតតាមបាប់ ត្រីក្រឡាប់ក្រាបគេចមុជទៅដី ដល់
ទឹកជ្រៅផ្លូវត្រង់ប្រឹងហែលខ្មី ខ្ទក់ខ្លីវ៉ហែលដល់
មាត់ ៗ ឯយាប្លងដែលពាំខាំពុំជ្រុះ ព្រោះបិត្តនោះ
ស្មោះគិតមិត្រពុំងា ពុំឈឺសាប់ជាប់ដោយកាំបិតព្រា

កំមីម្ហាហែលឥល់យល់ត្រីញ ។ ខ្លាក់យាប្លង់ឲ្យនាង
អណ្តែងស្រួល នាងទទួលបាភាំពាំទៅស៊ី ស្រាប់
តែឃើញប្តីជាប់សាច់ខ្ទេចខ្ទី ក៏សោកពិលាបលន់ពន់
ប្រមាណ ។ យំហើយសួរស្រីដ៏ទៅប្តីថា ឱភស្តាគ្រូ
គាប់ផ្លាប់សុខសាន្ត នៅសំបុកល្អកល្អនប្អូនបឋមប្រាណ
ពៀរអ៊ីបានជាមោះគ្រោះបង្រៃ ។ ឲ្យអ្នកមកខូចសាប់
ជាប់កន្ទុយ អស់ទាំងព្រួយកន្ទុលហ្វួលហើមក្រៃ ផា
ក្រពើឬឆ្លាមខាំអ្នកថ្លៃ ក្នុងសម័យនេះអ្នកផ្លាក់ប្ដូស់ការ ។
ព្រោះតែប្អូនគួនប្រើរកបំណើ ឲ្យស្មោខ្ទីស្រិបង់បរិភោគ
ភ្ដា នោះត្រីឈ្មោលក៏ពោលតបវាចា ឋាហៃគូជីភិមាស
បងអើយ ។ គឺជាកម្មនាំបងផ្លូងតម្រង់ ទៅលើព្រាន
ប្រមងប្រមើលហើយ ឃើញបងពាំយាប្លងហែលផ្លូង
ត្រើយ គេក៏សើយសំពត់រត់សំដៅ ។ បងនឹងស្ទុះ
ពុំលុះរួសរហ័ស គេគាប់ប្រាសប៉ះសាធជាថណោពៅ បង

ក៏ស្រាបហៃលពាំនាំឱ្យស្មោ ទោះជីបៅទៅមិនដល់
អរពរភា ។ ខ្ញុំនអន្តរាយពុំស្ដាយឡើយប្អូនស្រី ស្ដាយ
បំណាំស្រីបង់ប្រឹងលេលា ឲ្យប្អូនបានបរិភោគរសឱជា
កុំពុំងាអំពល់ខ្វល់ធុរៈ ។ អណ្ដែងញីព្យឈ្មោលពោល
ប្រាប់អស់ ក៏ស្រីណោះប្រែប្រាណខ្លួនញីរញាក់ វិយោគ
យំដំនួលកូលទុគាត់ ហើយវិលក្ដណ៌ជាកមាតបំទបៀម
ប៉ោ ។ ស្រីបជញ្ជក់យកខ្វះលុះកន្ទុយ សះជុះព្រួយ
ស្ដុយបាត់ឥតហ្មងសៅ ដោយសម្ភារបារមីស្រីឆោមឆ្លៅ
ទ្រង់ពុំក្ដៅក្រោយកាយជាសះ ។ ទោសជំច្នេះនេះខុស
ព្រោះខ្ញុំប្រើ ព្រះប្រសើរជាប្ដីក្រៃពេកណាស់ សូមព្រះអង្គ
ទ្រង់ប្រោសទោសស្រីឡូះ ឲ្យខ្ញុំម្ចាស់អស់កម្មពៀរវិរា ។
ទើបព្រះនាងទៀងទូលទំនួលត ជាជំណាររតិទានមានវគ្គ
ឃ្លា ជាបពិត្រព្រះអង្គទ្រង់សម្ភារ កាលក្នុងគ្រាសាសនា
ព្រះមង្គលៈ ។ នោះព្រះអង្គនឹងខ្ញុំមានកម្មជាប់ ឲ្យអក់ព្ទ

អាប់ប្រាណបានសម្ភារៈ ទ្រង់កើតជាបុរសឈ្មោះសុគ មានធុរៈទុគ៌តខ្សត់ក្រក្រី ។ ខ្ញុំអម្ចាស់នេះក៏ជាភរិយា មានតាមាចំពោះឈ្មោះសុទ្ធី ទាំងពីរជនមានបុត្រាបុត្រី ប្រុសពិសីឈ្មោះទិត្តកុមារ ។ ប្អូនបន្ទាប់ឈ្មោះនាងមង្គលី បុត្រទាំងពីរក៏ធំបំរើនភ្លា បុរសប្តីប្រពន្ធសែនទុក្ខា ដោយ ការក្រខ្សត់សង្កត់ចុះ ។ ទើបនាំគ្នានិយាយរាយរៀបរាប់ ថាយើងក៏ក្រជាប់អភ័ព្វតុះ តែងនឹងលះស្លឹកឈើដើរ រកឧស គ្រប់បំណុះអម្រស់ដូរកីស្តផល ។ គង់តែទៅ អាស្រ័យមិនពេញពោះ ហេតុពីព្រោះគ្រោះកម្មតាំមកផ្តល់ ដោយអំពើទុច្ចរិតសុទ្ធអកុសល ដែលដំកល់ទុកតពី ជាតិមុន ។ គឺពុំបានសាងសីលខ្ជិលធ្វើទាន ចិត្តក៏មាន កំណាញ់ពេញទ្រូស្តគុណ ទើបកើតមកលំបាកតោក យាកសុំន មិនមានទុនធនទ្រព្យអភ័ព្វម៉េះ ។ ឥឡូវ ត្រូវតែយើងនឹងខ្នណាះ ខំស្វែងសួះជាស់ចិត្តគិតឲ្យចេះ

សាងសន្សំសីលទានមានតម្រិះ គិតធ្វើណោះធ្វើណេះបុះ
ជាបុណ្យ ។ តែយើងទាល់សល់សែនគ្មានអ្វីសោះ ទោះ
ជាស្មោះលុះខ្លាំងគង់ស្កុកស្កុន ព្រោះខ្លួនយើងអភ័ព្វទិន
អាប់ចុន ឲ្យជាបជុនក្សីណាខ្សត់អនាថា ។ នោះប្រពន្ធ
បានស្តាប់សព្ទស្វាមី ក៏ស្រដីឆ្លើយតបសបវាចា ថាចិត្ត
ខ្ញុំក៏ភ្ញាក់ដូចអ្នកថា តែយើងមានបុត្រានឹងបុត្រី ។ បើ
យើងលុះជ្រះថ្លាជឿជាក់ហើយ នែអ្នកអើយអ្នកកុំចាំគិត
ថ្វី ត្រូវតែយើងយកបុត្រសុទ្ធពិសី ទៅស្រដីបញ្ចាំបំរើ
ទ្រព្យ ។ គេអ្នកមានយើងហ៊ានយកបានធន មកធ្វើ
បុណ្យប៉ុន្មានបានល្អគាប់ ប្តីបានឮប្រពន្ធគន់វះរាប់ ក៏ឲ្យ
ជាប់ចិត្តចូលមូលព្រមគ្នា ។ នាំបុត្រាបុត្រីខ្ញុំទៅទុក
នឹងអ្នកមុខយកទ្រព្យមកចាយជា ឈ្នួលឲ្យជាងកសាង
ព្រះវិហារ កុដិសាលាអាវាសអង្គាសសំឃ ។ គ្រប់គ្រងវត្ត
ថ្វាយភត្តចំណាយទាន តាមធនបានចំនួនសោឡសអង្គ

ហេតុកុសលផលះធ្វើអំពើត្រង់ កក្តៅកង្វល់ដល់មណ្ឌល ទី ។ នៃអាសនាឥន្ទ្រាជាអាភេទ ព្រះហស្សនេត្រភ្លែត ផ្លោះពោះអំពី ត្រៃត្រឹង្សាកាឡាជាផាងមណី ផ្លែងឫទ្ធិ និម្មិតប្រាសាទឋាន ។ ល្អចំពោងចំញោចស្ងាបដោយ មាស ភ្លឺឱភាសពាសពេញផែនដែនឋាន មានមាស ប្រាក់បាក់គរហួសប្រមាណ ជំនពីរប្រាណបានជាមហា សេដ្ឋី ។ ទើបទៅលោះដោះសាគាគាំបុត្រ មកឆាប់ ធុតឥតមោះព្រោះបារមី ចៅសុគៈមាណពភពសុទី សែន សម្បីសម្បូណ៌ហូរសម្បត្តិ ។ រឿងដូច្នេះខ្ញុំម្ចាស់ណាស់ ប្រារក្ក ដោយដំណាំដំណើរក្រខិតខាត់ គង់ខេរខឹងនឹង គ្នាជាប្រើនក្តាត់ មិនស្មៀមស្ងាត់មាត់កល្អសោះឡើយ ។

សូមព្រះអង្គទ្រង់ប្រោសទោសពិម្ពា ទុកជាខ្ញុំបាទា គ្រាគេះហើយ លុះទូលអស់ព្រះទាងនាចត្រាណាត្រើយ ថាព្រះអង្គខ្ញុំអើយកាលព្រះអង្គ ។ នាមបទុមសម្ពុទ្ធជា

មកុដភព ត្រាស់គិរប់កប្បយូរបើរាប់ត្រង់ ថយទៅ
ក្រោយអណ្តាប់កប្បធេះបង់ សែនយូរលង់ព្រះអង្គនឹង
ពិម្ពា ។ បានឧប្បត្តិជាក្សត្រខត្តិយាវង្ស ព្រះនាមទ្រង់
អង្គរៈរាជសម្ភារ ខ្ញុំបទុមទេវីអគ្គជាយា តែខ្ញុំជារាស្ត្រ
សុទ្ធបុត្រកុដុម្ពី ។ តែងនឹងដើរច្រៀងរាំពុំលោះខាន
មានរូបប្រាណល្អល្អះស្រស់ឆវី ស្តេចក៏សព្វព្រះទ័យ
ដោយនារី មានរូបវិលាសលេចជាប់ផែនដី ។ កាល
ដែលទ្រង់តាំងទុកទំនុកស្មោះ ឲ្យរបស់ទ្រព្យធនច្រើន
គប្បី មានមាសពេជ្រលេចលើសហួសអ្វីៗ មានពួក
ស្រីប្រិយជាបរិវារ ។ ស្តេចដំកើងនាងខ្ពស់ព្រោះទាញ
នាំ មិនឲ្យនាងច្រៀងរាំតាមធម្មតា មានខែត្រខណ្ឌ
កំណាន់នាំសួយសា ថ្វាយកញ្ញាថែមទៀតឥតឯខ្វះ ។
នាងក៏ស្រួលខ្ទួលតាមឱង្ការ មិនប្រាថ្នារាំច្រៀងជឿង
ជាក់ច្បាស់ ស្តេចក៏អរសាទរសរសើរណាស់ ថ្នមអង្គ

ព្រះធីតាស្មើដួងច័ន្ទ ។ តែវាសនានារីពីមុនជាប់ ទៅ
ទំលាប់ស្រីបស្រាលពាលនិស្ស័យ មិនលះចិត្តគិត
ខ្លាសរាស្ត្រក្រុងត្រៃ ដូនមានថ្ងៃណាស្ដេចត្រាចចាកទី ។
ទៅដោយការរក្សានគរស្រុក នាងអង្សុកក្រោកនាំស្នំនារី
ទៅក្រសាលវាលកាល ។ ចរលី មានមនុស្សម្នាមកឪរ
ពីនិត្យជាក់ ។ ស្គាល់ជានាងយាងបេញចរលេលា គេ
នាំគ្នាសរសើរឋានអ្នក នោះពីដើមរាំច្រៀងសៀងរត្នាក់
ភិរម្យរ័ក្កជាក់ណាស់ពីរោះក្រៃ ។ ធ្វើម្ដេចហ្ន៎នឹងបាននឮ
នាងម្ដងទៀត សមបេញស្មៀតបំឡែកផ្លែកប៉ូដៃ នាង
បាននឮផ្ដោះស្រីស្រស់ថ្លៃ ឡើងរាំច្រៀងវិស័យស្រីរបាំ ។
ព្រះបក្រពង្សទ្រង់ជ្រាបសភាពច្បាស់ ក៏អៀនណាស់ត្រាស់
ប្រាមហាមប្រចាំ ទោសនេះច្បាស់ខ្ញុំម្ចាស់ទាស់បណ្ដាំ
ខ្ញុំធ្វើកម្មព្រះអង្គបង់កិត្តិយស ។ សូមព្រះអង្គទ្រង់ប្រោស
ទោសពិម្ពា សូមស្វាមីណាទិញ្ញនកុំមានមោះ លះទួល

អស់ព្រះនាងទៀងទូលផ្គាះ នាំទូរសេវាទឹតទៀតហា ។

ហាបពិត្រព្រះមកុដផុតភពត្រៃ ឧបនិស្ស័យនៃខ្ញុំ នាំសង្ខារ ឲ្យព្រះអង្គនឹងខ្ញុំជុំជាតា មានវាសនាអភ័ព្វ ហាប់ភពភាគ់ ។ ទៅកើតជាប្រើសមាសនិវាសទី ទាំងឈ្មោលញីពីហ្វូងនៅក្នុងជាន់ សម័យនោះព្រះភ្លៀងរាំងរូសរាគ់ សត្វរយពាគ់ស្លុតស្លាប់សព្វទិសទី ៗ ព្រោះរីងគោកទឹកអស់សព្វជ្រោះប្រាំង ត្លុកត្រពាំងបឹងបួរួវគិរី ខ្ញុំនព្រះអង្គនឹងខ្ញុំនាំគ្នាលី . លាទៅរកទឹកនិវាសហ្វូងហ្វាយ ៗ បេះតែដើរ ៗ ទោះជ្រៅត្រមោច មុខអាណោចអាណាិតម្បិតក្រហាយ នឹងស្រេកណាស់ខះកដើរក៏ឆ្ងាយ បានទៅឃើញបទ្បាយមួយមានទឹក ៗ ល្មមនឹងក្រេបលេបស្មានបានមួយផ្អែត តែជាហេតុឲ្យឈ្មោលក្តួលបិត្តនឹក ហាបើសិនបានលេបមួយក្រើក អស់សន្ទឹកគោករីងលែងបានញី ។ បើខ្ញុំនអត់ក៏អត់ឥតុបើហា ឲ្យតែបាន

សង្សារគ្រួជីវ៍ គិតដូច្នោះប្រើសល្បោចពោលវាទី ថាមាស
បងនាងលីលាចុះទៅ ៗ ផឹកឲ្យបានឆ្អួនឆ្អែតជ្បិត
ស្រេកណាស់ ញីរហាស់ចុះភ្លាមពុំស្មៀមនៅ ពុំត្រឹមតែ
ឈរផឹកទឹកត្រង់ជ្រោ លុកលុយទៅត្រូវជើងលើក
ឡើងបុះ ៗ ជីកផុលខ្ទលឡើងក្នុងវង់ត្លុក ទៅជាភក់
ល្អក់រល់ទាល់សព្វសុស ថែមបស្សាវៈទៀតផតជីងខុស
បំកំហុសកំហូពខ្ទបនៅញ៉ ៗ ទោសទាំងនេះខុសណាស់
អម្ចាស់ថ្លៃ ជាវិស័យស្រីខ្ញុំនាំវើ ធ្វើព្រះអង្គបង្កើត
ហេតុទុក្ខទី នៅក្នុងទីវដ្ដភិលពលជំពាក់ ៗ សូមព្រះអង្គ
ទ្រង់ប្រោសទោសពីម្ដា តំងស្មាលាពីប្រាណកុំមានទាក់
ទូលពុំលង់ព្រះនាងនាថវីរលក្ខណ៍ លើកជាតិជាក់មក
តជំណាថ្លែង ៗ ថាភន្តេ ភគវា មហាបពិត្រ ពីអតីត
ជាតិមុនស៊ុតអង្វែង ក្នុងព្រះពុទ្ធកណ្ឋាជាគម្ដែង ព្រះ
អង្គឯងនឹងខ្ញុំពិម្ហាពិត ៗ បានអគ្គោលយោលជាតិកើត

ជាស្វា នៅក្នុងព្រៃព្រឹក្សាជាគូមិត្ត ឯពានរញីឈ្មោល
មួលជាប់ជិត នៅនៃបនិត្យរើសរកញីមានផ្ទៃ ។ ពានរ
ញីបង់ស៊ីផ្លែឧទុម្ពរ ព្រោះឧទរចំអើនកើតមានវ័យ ហាប្ដីអើយ
ប្ដីគិតអាណិតលៃ រកផ្លែល្វាក្នុងព្រៃឲ្យស្រីស៊ី ។ ព្រោះ
ខ្ញុំទំទម្ងន់ឃ្លានអាហារ បង់ភោក្ដាល្វាទុំចាំសម្ដី ប្ដីបាន
ឮប្រពន្ធសែនទុក្ខទី ក៏ម្នាម្នីប្រលោមលោមលាកណា ៗ
លោតរំលងឆ្លងឈើមើលពិនិត្យ នៅទៀបជិតឥតមាន
ជ្រៃដើមល្វា បេះតែលោតទៀតតក់ទស្សនា ឃើញឧទុម្ពរ
មួយភ្ជិះជាប់គេ ៗ មានផលាស្រគាលរន្ធាលទុំ បក្សី
ជុំហោមចឹកធ្លាក់ជ្រុះផ្អេរ ស្ដេចពានរក៏ឡើងតុំរង់រេ ពុំ
ទំនេរបង្គង់តាំងតែបេះ ៗ បៀមក្នុងមាត់ពត់ចងផ្គង
លើស្មា ទាំងហត្ថាក៏កាន់វណ្ណាចង្កេះ លុះបានពេញ
សំនួនមានតម្រិះ តាំងប្រឡេះប្រឡំភោត្តា ៗ ហេតុ
តែកម្មពុំទៀរទៀរពានរ ចុះពីដើមឧទុម្ពរក៏មានខ្លា ក្រាប

ប្របគល់យល់ស្រេចជាស្រេចស្នា ក៏ស្ទុះឆ្លាទៅទាំពុំប្រែណា ។ សែនអនិច្ចាស្ងាសពោធិសត្វ ទៅរំបត់ជ្រៀតខាងឥន្ទ្រាស្ត្រីយ ជាទំពាស់សាច់ឆាច់សរសៃ នៅក្រោមដើមល្វាខ្ទីក្បួយជីវិត ។

ស្វាញីករិយាទៅនាប៉ាន ឲ្យប្រមាណមិនយល់ដល់គូពិត ធ្លាប់ទៅព្រឹកមកល្ងាចដូចដែលគិត ស្រាប់តែម័តបាត់លែងដល់លំនៅ ។ បាតមួយថ្ងៃក្រកើង ១៣ នោះនាងស្វាក៏ស្ទុះលះចេញទៅ ខំដង្ហោយស្រែកបោកក្នុងព្រៃជ្រៅ ដាកម្មពោះនៅកំពុងស្នេហា ។ នាងខ្សឹកសោករកស្វាមី ជាខ្ញុំប្ដីស្រីប្រាសជីវ៉ា ម្ដេចក៏ត្រូវទៅបាត់ស្ងាត់ម្ល៉េះណា ឲ្យប្អូនផ្សាក្រហាយកាយរកាំ ។ ឬអ្នកទៅត្រូវបិតស្និទ្ធស្នេហា ញីឯណាជាប្ដីឲ្យស្រីចាំ ឬមានទុក្ខធុរៈធ្លាក់បែកស្រាំ ឬសត្វខាំអ្នកថ្លៃក្សួយដឹងអើយ ។ នូស្វាមីថ្លៃថ្លើមផ្ដើមបណ្ដាច់ ប្អូនគិតស្រេចប្រែជាបើឃ្លាត

ហើយ ប្អូនមិនទើងចង់រស់ស្មោះជាត្រើយ អ្នកប្តីអើយ ស្តាយប្អូនស្ងួតស្ងួនជន្មា ។ មុខអន់ច្ចាស្វាញ៉ីឥភាសគូ ចេះតែសូសោកយំក្រអង្គា មិនបានដេកបានស៊ីពីរទិវា ក៏ប្រែះទ្រូងមរណាកណ្តាលព្រៃ ។ រឿងយ៉ាងនេះព្រោះតែខ្ញុំពិម្ពា ប្រែព្រះអង្គមរណាជីវិតក្ស័យ សូមព្រះអង្គទ្រង់ប្រោសអត់ទោសពៀរ ឲ្យរួចភ័យវិបត្តិជ្វៀតផ្តាំផង ។

លំដាប់នោះព្រះមហាថេររតន៍ នាំប្រវត្តិអតីតជាតិរំលង តាមទំនុកដំណាលពោលទាក់ទង ដោយទំនងដំណើរស្នើទូលថា ។ បពិត្រសម្តេចព្រះអរហំ កាលកំបាំងបាត់ស្ងាត់អតីតា ក្នុងរវាងគ្រានោះព្រះសាសនាព្រះអភិសម្មាមុនីនាថ ។ នោះព្រះអង្គនឹងខ្ញុំបន្ទិត កើតជាសត្វកិន្នរជោយសរជាតិ នៅក្នុងព្រៃហិមពាន្តពុំមានឃ្លាតជុំសាចញាតិកិន្នរជាបរិវារ ។ ជួនមួយថ្ងៃកិន្នរពោធិសត្វនាំប្អូនកាត់ផ្កាត់ផ្លៀលហើរយាត្រា ទៅច្រៀងរាំក្រោម

ម្លប់ជ្រៃសាខា កើតវិតាបោកបក់សន្លឹកខ្លាំង ។ ផ្ទើម
រំលោភិរុណាផង់ផង្រ្គែ មេឃស្រទំជុំជិតបិទស្រាំង ព្យុះ
ក៏បក់បាក់ឈើព្រៃក្តុងក្តាំង ទឹកក៏តាំងជោរជន់ពន្លឹកក្រៃ ។
ឯកិន្នរញីឈ្មោលដែលជ្រកឈប់ ទៅក្រោមម្លប់និគ្រោធ
កើតពិស្ម័យ ដោយទឹកជន់លន្លាមលិចព្រៃផ្សៃ របួត
ដៃភ័យភ្លាត់ព្រាត់ពីគ្នា ។ ហើរបែកខ្ចែកវិកជ្រែករកទ្រនំ
តាមឈើធំឈើតូចខ្លាចមរណា ស្តេចកិន្នរក៏ព្រាត់បាត់
ភរិយា គំរាលឃ្លាឃ្លាតស្ងួនស្យដោយខ្លួនទៅ ។ កើត
ទោមនស្សអាណោះអាល័យគ្លូ លុះឃប់យូរក៏យំក្រិកទ្រូង
ទៅ ឈ្មោលក៏យំញីក៏យំទាំងយប់ជ្រៅ ប្រឹងស្រែក
ហៅពុំព្រន្ទឹងល់ ។ ព្រោះវង្វះអសន៍បាញ់ព្រៃព្រឹក្ស
ស្ងរគគឹកគគុកឈាក់នឹងខ្យល់ គួរអនិច្ចាជាកម្មនាំឲ្យខ្វល់
ឲ្យសែនសល់ក្របាយកាយនែសត្វ ។ ទំរាំតែភិរុណាអន់
រំលោ ពេះសុរិយាក៏រះស្រឡះថ្លាត់ ទើបកិន្នរទាំងគូស្ង

ហើរកាត់ រកគ្នាប្តូចប៉ុន្មានបានឃើញយល់ ។ អំពើ
កម្មដែលនាំឱ្យទ្រាំទុក្ខ ក្នុងជង្ហុកឱយោយូរអម្តល់ ក៏ពី
ខ្ញុំពិម្ពាជាប្រួសគល់ ឱ្យរវល់ដល់អង្គព្រះឈ្មះមារ ។ មិន
អង្គីពីអ្វីក្រៅស្រីប្រុស ឱ្យនាំចុះនាំឡើងគ្រៀងពន្ធនា
ទើបព្រះអង្គវង្វេងវែងយូរយារ ក្នុងវេលានេះខ្ញុំសុំប្រណី ។

ទើបព្រះនាងព្រាងទូលព្រះសាស្តា ឋាបពិត្រ
ព្រះមហាបមជំនស្រី កាលសាសនាបញ្ញាពុទ្ធបារមី
យើងកើតជាប័ក្សីប័ក្សាសត្វ ។ ចាកក្រពាករកសុំតែ
មច្ឆា ជាអាហារចិញ្ចឹមតាមវិប័ត្តិ ខ្ញុំអម្ចាស់ជាញីនៅទី
ស្ងាត់ ទ្រង់បានចាត់អាហារសារពើត្រី ។ ឱ្យខ្ញុំម្ចាស់
មិនខ្វះពេលវេលា ព្រោះខ្ញុំជាគូគាប់ជាប់បេតី ព្រះអង្គ
អើយខ្លួនខ្ញុំពុំធ្វើអ្វី ស្រេចលើប្តីបីបាច់គ្រប់កិច្ចា ។
និស្ស័យកម្មខ្ញុំម្ចាស់នឹងលាណាក ឱ្យព្រាត់ព្រាកបាកទ្រង់
ក្នុងវក្ខ ថ្ងៃមួយនោះព្រះអង្គទ្រង់ហើរឆ្លា ទៅទំបាំមច្ឆា

ក្បៀរមាត់ស្រះ ៗ ជួនឲ្យមានព្រះសង្ឃអង្គសាវក លោកជាអ្នកជាក់ជាំអភិធម្មច្បាស់ បានសម្រេចវិមុត្តិផុតស្រឡះនិមន្តស្ទុះមោះមកជ្រកនៅគល់ ៗ ឈើដែលចាកក្រពាកសំកក់ទុំ លោកនិយមខំសូត្របាត់ឲ្យយល់ នៃបាលីត្រៃលក្ខណ៍ជាក់ចប់ដល់ ទៀបទោទល់រសៀលជ្រេរជ្រៀលថ្ងៃ ៗ ចាកក្រពាកឮពាក្យឯកសម្ងំ ស្តាប់អភិធម្មជាំបានមានសម័យ ដោយបញ្ញាដែលធ្លាប់ជាប់និស្ស័យ ជាបច្ច័យវៃជាំពីដើមស្រាប់ ៗ ក៏រំពឹងក្នុងចិត្តពិនិត្យថា ឱអាត្មាអញអើយឲ្យបានស្តាប់ សូរព្រះធម៌ពីរោះខ្ពស់បំណាប់ អញមិនគួរបើចាប់ត្រីភោគក្តា ៗ គិតដូច្នោះហើយបុះចាកទ្រនំ ទៅដល់ទំទៀបបាទព្រះថេរាហើរកាងស្លាបបង្គំសុំសមា. ទានរក្សាសីលប្រាំកម្មបបិជប់ ៗ ព្រះសាវកលោកបានឲ្យទានសីល ចាកក្រពាកឯកវិលហើរត្រឡប់ ទៅទ្រទំទំស្ងៀមសង្រួមបប់

ចិត្តក៏ស្ងប់ដាប់ចាំសីលប្រាំបាន ។ មិនបរិភោគអាហារ
ប្រាំពីរថ្ងៃ ផុតជីវិតក្សិណក្ស័យប្រល័យប្រាណ ផលសីល
ប្រាំនាំបីតចិត្តសន្តាន ទៅបង្កើតក្នុងឋានសួគ៌ាល័យ ។
មានបរិវារប្រាសាទស្អាតបំផុត ទើបទេវបុត្រគិតនឹកញឹក
មមៃ សំឡឹងដឹងក្នុងញាណបានច្បាស់វៃ ឃើញ
និស្ស័យពីសត្វចាកក្រពាក ។ បានរក្សាសីលប្រាំពី
ថ្ងៃ ហើយក្សិណក្ស័យមកកើតជាតិពេញភាគ្យ ប្រឹង
សំឡឹងដឹងថាញីព្រាត់ព្រាក ដែលលះលោកចាកគ្នាគួរ
ប្រណី ។ ព្រោះជាត្តគួសាងសំអាងគាប់ ជាកន្សៀ
ថ្ងៃផ្ដាប់ដាប់បារមី ឲ្យស្លុងស្លុតទេវបុត្រស្រុតដលដី
ឃើញបក្សីយោបំក្រិសោកា ។ មុខអាសូរលំបាកចាក
ក្រពាក សោកព្រាត់ព្រាករកគួយូរណាស់ណា ប្រាំពីរ
ថ្ងៃក្រៃក្រិតដំណាំផ្សា នាងខ្ញុំជាឪប្ដីសំឡាញ់ ។
ហេតុដូចម្ដេចគេចបាត់ស្ងាត់ស្ងួនស្ងាសោះ ឱស្រែណោះ

ប្រុសប្រាណប្អូនបានកាញ់ គិតរាប់ពេលដែលប្រុសចុះ
ពេលអញ ខ្ញុំបង់បាញ់ពេញប្រាំពីរថ្ងៃហើយ ។
ប្អូនធ្លាប់ស៊ីអាហារដោយសារប្តី ពាំនាំត្រីមកឲ្យមិនព្រួយ
ឡើយ ឥឡូវម្តេចប្រុសគេចស្ងួស្យកន្តើយ ឱប្រុស
អើយប្រុសសាត់បាត់បែកចិត្ត ។ ទៅបានគួជទៃថ្មីជឹង
ឬ ឬហ៊ាត់ឈើចុកចាប់ស្លាប់ខ្ទេចល្អិត ឬគេបៀតបៀន
បានក្នុងឋានចិត ដែលប្រុសស្និទ្ធធ្លាប់ជ្រកករកម្ល្ហា ។
បើប្រុសប្រែបែរមានគូគាប់ចៃ ឬប្រុសក្ស័យជីវិតពិត
យ៉ាងណា ប្អូនក៏សុំលាប្រុសស្លាប់រួសរ៉ា មិនរស់នៅឲ្យ
ផ្សាក្រោយឡើយ ។ ចាកក្រពាកសោករាប់សព្វ
ទំនុក ជំណាំទុក្ខពេកពន់ធ្ងន់ពុំស្បើយ ក៏ហើរហោះ
បោះពួយដោយខ្លាំងហើយ ធ្លាក់ទៅកើយលើគល់ផ្ដល់
សន្លប់ ។ ទទួលពេលទេវបុត្តស្រីតមកដល់ ឃើញបក្សី
សោកសល់ញ័រចំប្រប់ ហើយហើរចុះជ្រិះធ្លាក់ឲ្យនឹកថប់

ប្រុសប្រាណប្អូនបានកាញ់ គិតរាប់ពេលដែលប្រុសចុះ
ពោលអញ ខ្ញុំបង់បាញ់ពេញប្រាំពីរថ្ងៃហើយ ។
ប្អូនធ្លាប់ស៊ីអាហារដោយសារប្តី ពាំនាំត្រីមកឲ្យមិនព្រួយ
ឡើយ ឥឡូវម្តេចប្រុសគេចស្ងួស្យកក្តើយ ឱប្រុស
អើយប្រុសសាត់បាត់បែកចិត្ត ។ ទៅបានគូដទៃថ្មីដឹង
ឬ ឬប្អាត់ឈឺចុកចាប់ស្លាប់ខ្ទេចល្អិត ឬគេបៀតបៀន
បានក្នុងឋានថីត ដែលប្រុសស្ទុំធ្លាប់ជ្រករកម្ហា ។
បើប្រុសប្រែបែរមានគូគាប់បែ ឬប្រុសក្ស័យជីវិតពិត
យ៉ាងណា ប្អូនក៏សុំលាប្រុសស្លាប់រួសរ៉ា មិនរស់នៅឲ្យ
ផ្សាក្រហាយឡើយ ។ ចាកក្រពាកសោករាប់សព្វ
ទំនុក ជំណាំទុក្ខពេកពន់ធ្ងន់ពុំស្បើយ ក៏ហើរហោះ
បោះព្លួយដោយខ្លាំងហើយ ធ្លាក់ទៅកើយលើគល់ផ្តល់
សន្លប់ ។ ទន្ទួលពេលទេវបុត្រស្រីតមកដល់ ឃើញបក្សី
សោកសល់ញ័រចំប្រប់ ហើយហើរចុះជ្រិះធ្លាក់ឲ្យនិកចប់

បំណាច់នេះហោងបងកើតជា ។ អង្គទេវបុត្តសុទ្ធសាធ ស្អាតសុរិល ដោយផលសីលដែលកាន់មិនពាគា ដល់ជីវិតសត្វផងយើងលេលា មកនាំពាគពៅទៅសួគ៌ឆាយ ។

ឲ្យឃើញឋានវិមានយានសឹងមាស ភ្លឺឱភាសផ្លាស ផ្លុះប្រិះព្រោងព្រាយ មានស្រីស្នំក្រមការល្អះភោភាយ សែនសប្បាយដោយរូបទិព្វកញ្ញា ។ ទំបំផុតទេវបុត្តពិសុទ្ធសក្តិ ចាប់នាងដាក់លើដៃវៃហោះហា ដោយទេវឫទ្ធិនិម្មិតពិតអស្ចារ្យ ដល់ទៅត្រៃត្រឹង្សាសួគ៌ទិព្វទី ។ នាំបង្ហាញបន្ទប់ទិព្វបន្ទំ ទែគមនោរម្យបន្ទាប់ភពនារី ទាំងបន្ទប់ទឹកស្រង់នឹងភោជនី តាមបន្ទើងគ្រឿងពិធាតជន្ត្រី ។ បាកក្រពាកដាកមើលយល់ប្រាសាទ ប្រសើរស្អាតផុតបំផុតគិតបេតី ភ្លេបសម្បុកទ្រទំទំប្រក្រតី ភ្លេបបំណើបំណុកស្រុកមនុស្សា ។ រូបទេវបុត្តក៏ស្រូតប្រូតបុះ នាំនាងនោះលុះដល់ដៃនរក្កា ឲ្យឱភាទស្វាធ្យាយ

រាយគាថា តើបាណាទៅដល់សីលមេរ៍យ ។ ឡើតាំងបិត្តគិត កត់កំណត់ចាំ សីលទាំងប្រាំកុំភ្លេចជាប់និស្ស័យ នាងក៏ទ្រាំបាំសីលប្រាំពីរថ្ងៃ ទាល់តែក្ស័យទៅកើតជាតិជួបគ្នា ។

ហេតុនេះឯងខ្ញុំថ្លែងទូលព្រះអង្គ កាលយើងបង្កើតខុសព្រោះវេរា ខ្ញុំនព្រះអង្គទ្រង់គ្នៀយព្រយអង្គាតែងលេលារកត្រីឡើខ្ញុំម្ចាស់ ។ បាបបំពោះព្រោះខ្ញុំនាំព្រះអង្គ គ្នៀយជួយស្រង់យោងយិតឥតឯខ្ទះ បើកុំទ្រង់មេត្តាករុណាណាស់ ពុំបានត្រាស់ប្បាស់ធម៌ដល់ម្លេះឡើយ ។ ឬទោសានុទោសល្មើសទាំងគ្រប់ សូមព្រះអង្គទ្រង់លុបលើកឲ្យហើយ ព្រោះខ្ញុំសូមលាលុះព្រះគុណអើយ ទៅកាន់ត្រើយនិញ្វនសួគ្យសង្ហារ ។

ទើបព្រះនាងប្រណម្យលំអុតកាយ នាំបរិយាយរាយរឿងទំនងថា បពិត្រព្រះអង្គទ្រង់សីលា កាលភពភាន់កន្តារជាយូរណាស់ ។ ខ្ញុំនព្រះអង្គនឹងខ្ញុំនាំកំណើត ទៅ

បង្កើតជាសត្វកំប្រុកច្បាស់ នៅក្នុងឆ្នេរសមុទ្របុត្រខ្ញុំម្ចាស់ កើតស្រឡះជាឈ្មោលទោលតែឯង ។ ព្រះអង្គហើយនឹងខ្ញុំជុំជួបជាក់ បានរួមរក្សាបុត្រីសុទ្ធស្តែង បុត្រទើបកើតកំណើតសត្វនោះតែង លោតប្រវែងរពិសណាស់សោះសា ។ មេពុំសូវទៅឃ្លាតរវាទឆ្ងាយ នៅកៀកកាយបីឱបថ្នាប់ឱរា ឈ្មោលក៏តែងស្វែងរកយកផលា ជាអាហារបំញ៉ុមពុំលោះថ្ងៃ ។ តាំងពីពេលសំរាលរយាលយូរ សត្វទាំងគូក៏ថ្នមបមបុត្រថ្លៃ ជួនពេលមួយដោយពៀរជាបច្ច័យ មានសម័យឲ្យមេរេរះគិត ។ ចង់ទៅរកអាហារពីខ្លួនឯង ទើបចាប់ចងនឹងឈ្មោលពោលពាក្យពិត ថាពេលនេះខ្ញុំរិះចង់ឲ្យមិត្រ នៅពិនិត្យមើលបុត្រសុទ្ធសង្ហារ ។ ព្រោះកូនយើងរពិសណាស់ណាប្តី ខ្ញុំទៅរកចំណីឲ្យភោក្តា អ្នកប្រយ័ត្នពិតពិលមើលព្យាបាល់ កុំទៅណាឲ្យឆ្ងាយឡើយអ្នកថ្លៃ ។ ផ្តាំ

ផ្កាក់ទុកកំប្រុកញីលេលា លោតផ្លងភិរតាមវល្លិ៍ឈើព្រៃ
ផ្សៃ ឯកូនពួនទៅរន្ធមិនអាថ៌ ឈ្មោលពានិត្យពិបៃរតៃ
ថៃ ។ ជួនជាឆ្កែលប្រឹះប្រាណពួនឆ្មេចលក់ កូន
កំប្រុកសុកសុរមមុលបែរ ចេញពីរន្ធបន្ទិចគេចប្រុះប្រែ
ភិរតាមខ្សែវល្លិយុះទៅដល់ទឹក ។ មិនតែភិរសៀរសោត
លោតបណ្តើរ ដូចគេហើរប៉ើងជើងឡើងសន្ទូក ធ្លាក់
មកស្មោះខុសវល្លិញ័ររំក ដូចគេភ្លឹកភ្លាត់កាយឆ្ងាយ
ស្រឡះ ។ ធ្លាក់របូតរហូតទៅក្នុងទឹក ជ្រៅពន្លឹកហាក់
ហៃលផែលតែះតះ បានតែមួយស្របក់ខ្កក់កខះ អស់
បម្រះបះដៃក្បូយជីវា ។ លិចក្នុងទឹកភ្លឹកភ្លាត់បាត់
ស្រមោល កំប្រុកឈ្មោលអាពុកភ្ញាក់កាយា
ក្រឡេកទាន់ឃើញបុត្រលោតធ្លាក់ធ្លា ក៏មីមារហោតតាម
ភ្លាមពុំយូរ ។ ផ្ទង់តម្រង់បង់វល្លិដែលយុះជ្រុះ ទៅអេះ
អុះស្លុះស្វាសពាសមម្ស គិតប្រែថ្មយលយះហែលតាមដែល
ស្ទូ ឃើញកូនគួជីវិតលិពាបាត់ស្រឹប ។ ក៏ប្រែឡាស

ស្ងាសស្លុះលុះតែហត់ សោកកំសត់ស្លុតស្លាំងឈាំងក្រអឹម
ស្មើរតែស្លុះអស់ខ្យល់រល់សង្ហឹម ប៉ះសង្រ្ហឹមត្រៅទំករីករក
បុត្រ ។ កំប្រុកញីតាំងពីលាណាកប្តី បានចំណីវ៉ាពាំនាំ
ចំហុត ស្រូតហោតផ្លោះលុះដល់ក៏ចូលផុត សែនស្រយុត
ព្រោះបាត់កូនពីរន្ធ ។ ប្តីក៏បាត់ស្ងាត់ជ្រៀបទើបហៅរក
ថាកូនអើយម៉ែមកយកទំនុំទត់ ក៏ប្រុកឈ្មោលកាលឮសួរ
ប្រពន្ធ ថែមទម្ងន់តានតឹងប្រឹងបង់លាក់ ។ គិតពុំដាច់
ស្រែបបាច់ដូចបំណង ទើបហោតឆ្លងតាមរល្លីខ្ញែរញាក់ ប្រាប់ហើយយំក្រិក្រូនខ្ទួនទាក់ ហានគ្អក
នាងកុំបន្ទោសបង ។ ដ្បិតបុត្រយើងឯងនេះព្រោះមាន
កម្ម ពៀរប្រចាំនាំវាឲ្យវារឆ្លង របូតធ្លាក់ទឹកបាត់ស្ងាត់តែ
ម្តង ប្តីត្រកងមិនទាន់ភាន់ស្មារតី ។ បានហោតតាម
រំពេចលិចបាត់ស្មោះ បងក៏អស់ចំណេះព្រោះកូនខ្ចី ធ្លាក់
ទៅបាត់ឥតផុះសោះប្អូនស្រី ប្អូនគប្បីពីគ្រោះបុះណានាង ។

គួរអនិច្ចាជាកម្មកំប្រុកញ   កាលបានឮភិទពី ឈ្មោលភ្លាង ដូចជីវិតបាត់ទៅនៅតែរាង ដួលស្រទាង លើចុងឈើបម្រះ ។ ននៀលនឹកទឹកនេត្រសម្តេចបា ឱកូនគូជីវាម៉ែឈឺណាស់ មិនគួរកូនសូន្យជន្មមិនទាន់ បាស់ កូនស្រទ្បះប្រាសម៉ែទីទៃគ្នា ។ ម្តាយទ្រាំទ្រពរ ពោះលុះបាកើត សមកំណើតជាឈ្មោលមូលមិត្រភ្ញា ម៉ែក្រទ្រាំបំបៅចៅឲ្យជា គ្រប់វេលាបាធំមាំជើងដៃ ។ បាបេះរាវសៀវបាប់ជាប់ទាំងអស់ បេះកៀវកោះផ្លោះថ្លែង ម៉ែក្រែងក្រែ ក្រែងកូនលោតរបូតធ្លាក់យប់ថ្ងៃ ក្នុង សម័យនេះម៉ែបានផ្តែផ្តាំ ។ ឲ្យបិតាបាមើលហ្កាល ប្រយ័ត្ន ម៉ែទៅបាត់គាត់ឪមិនទៅជាំ ទើបកូនម៉ែបែរ ធ្លាក់ទឹកតាក់តាំ គឺជាកម្មម៉ែកូនខានឃើញគ្នា ។ ឱអ្នក ប្តីអំបិតុតតធម៌សោះ ញុំឲ្យកូនខ្ញុំអស់ជីពជន្មា គំអ្នក ឥតពិតពិលរមិលភ្នា ទើបកូនខ្ញុំមរណាព្រោះតែអ្នក ។

នេះតទ្បូរត្រូវតែអ្នករាវរក ឲ្យបានខ្មោចកូនមកនឹងយល់ជាក់ ឲ្យតែខ្ញុំជាម្ដាយបានឃើញភក្ត្រ តើវាធ្លាក់ស្លាប់ត្រង់កន្លែងណា ។ ពោធិវង្សទ្រង់កើតជាសត្វស្ទអាល័យបុត្រផុតគិតរកទុក្ខផ្សា ទាំងកោតខ្លាចប្រពន្ធបន្ទោសថា ក៏យាត្រាតាមវិល្លិទៅដល់ទឹក ។ ដោយគំនិតគិតប្រឹងនឹងរំលីង បាបឲ្យវង្សសម្រិទ្ធពិតតាមនឹក កាលណាគោករកខ្មោចមិនខ្លាចភ្លឹក ទើបបុះរកកន្ទុយដោយឧស្សាហ៍ ។ កាលដែលដោកទទឹកហាក់រហាស មិនឈប់សោះបុះឡើងប្រឹងណាស់ណា បាត់ស្រែកឃ្លានប្រមាណក្នុងចិត្តថា គង់ផលសារវឹងតាមព្យាយាមខ្លាំង ។

អនិច្ចាកំប្រុកទុក្ខភ្លាំងភ្លឹក យកកន្ទុយបាចទឹកសន្ធឹកតាំង រំលងយប់គ្រប់ខ្លួបកូនមរណា កូនក៏ញាំងប៉ោងឡើងប៉ងនឹងផុះ ។ ដោយអំពើព្យាយាមកំប្រុកឈ្មោល ក៏ក្ដៅពោលដាលដល់មណ្ឌលផុះ នៃសម្ដេច

អម្រិត្តពិតបណ្តុះ ស្តេចក៏បុះទស្សនាភ្ញារឃើញជាក់ ៗ
ជាព្រះពោធិសត្វបត្តិញឹក យកក្នុយបាបទឹកនឹកឲ្យរាក់
ពីព្រោះបុត្រភ្លាត់ស្មៀតហោតឲ្យធ្លាក់ ព្រះឥន្ទភ្ញាក់ភ្លឹក
ភ្លាំងតាំងភិសវង់ ៗ ឲ្យអាស្ចូរពោធិ៍នារីសត្វ ទើបហោះ
កាត់ពពកមកពុំរង់ កាលបើដល់ផលផ្ទីទ៏កំពង់ ក្អូន
ដែលលង់ក៏ផុះផ្អុះឡើងខ្ពី ៗ ទើបព្រះឥន្ទ្រព្រះអង្គស្រង់ឡើង
ស្មោះ ហើយព្រួសប្រស់រស់ប្រាណមានស្មារតី ក្អូនក៏ប្រុក
ភ្ញាក់ព្រឹតកើតជាថ្មី ព្រះកោសីរ៉ៃហុចឲ្យមាតា ៗ ក៏ប្រុក
ពីរញីឈ្មោលដែលអ្អូលអាក់ បានឃើញជាក់ជាអង្គឥន្ទ
កោសា ប្រស់រស់បុត្រវិសុទ្ធដូចប្រាថ្នា ក៏អរឱនកាយា
អភិវាទ ៗ ព្រះឥន្ទ្រខៀវហៀវហោះផ្លោះត្រដឹង ទៅ
ត្រៃត្រឹង្សត្រូវខ្ពស់លុះឃ្លាឃ្លាត ទូលបប់ស្រៀបសម្តេច
បើរនាថ ឱនក្រាបបាទបង្គំសុំទោសា ៗ សូមព្រះអង្គ
ទ្រង់ប្រោសអត់ទោសពៃរ ឲ្យរួចភ័យវិប័ត្តិផុតវាសនា

ព្រោះខ្ញុំគំហកកំហែងហ៊ា ឲ្យអាត្មាព្រះអង្គទ្រង់គិតខុស ។ យកកន្ទុយបាចទឹកនឹកឲ្យគោក សាគរលោកឱឃៈវែងជ្រៅបុះ ទោសខ្ញុំម្ចាស់ណាស់លើសល្មើសកំហុស ខ្ញុំបន្តះបន្ទោសកំហួសការ ។

ថ្លែងបប់បុះព្រះមហាះបិរីរតន៍ គាំប្រវត្តិពិតទូលពោលបណ្ហា បពិត្រព្រះមុនីនាថសាស្តា កាលសាសនាព្រះពុទ្ធមកុដមោលី ។ ព្រះនាមារើតពុទ្ធង្កុរ ខ្ញុំព្រះអង្គយោនយោលមូលវេណី ជាសសេះបក្សាគួឈ្មោលញី និត្យនៅទីហិមពាន្តឋានព្រឹក្សព្រៃ ។ វេលានោះសសេះញីគព្ភា មានប្រាថ្នាបង់ផឹកទឹកនៅនៃ អនោតត្តជាតស្រះប្លាប្រពៃ ក៏សន្ទែសន្ទឹកនឹកខ្លោចផ្សា ។ សសេះឈ្មោលយល់ញីជាទុក្ខក្រៃ ក៏គួរសមសំណោះជាស់ស្ងួរហា ហៃព្រះលឹងមាសបង ៗ សង្កា នឹងភក្ត្រាប្អូនក្រៀមស្ងៀមជាទុក្ខ ៗ នាគបើឈើឬនឹកអាពុកម្ដាយ ទើបធោជផាយណាយ

ទៀយព្រ្យយសូត្រមុខ សសេះញាក់ភ្លើយវាយទំនុក ថាប្អូន
គ្មានកលិយុគនឹកអ្នកណា ។ នឹកតែបងស្រងស្រូបក្រោប
ទឹកស្អាត អនោតត្តជាតស្រះស្រង់រងប្លា បើជាបង
សង្គ្រោះស្មោះបិត្តា ទៅពាំនាំទឹកវារីស្រះស្រង់ ។ បាន
សម្រេចដូចក្តីស្រីប្រាថ្នា ប្អូននេះមហាអំណរអរអស់បង
បើប្រសិនមិនស្រេចដូចបំណង ប្អូនមិនសង្ឃឹមខ្លួនបាន
រស់ទេ ។ សសេះឈ្មោលកាលឮញីថាប្រោះក៏ស្រួលស្រុះ
ណាស់ហើយឆ្លើយថាមេ នាងកុំភ័យស្រីបងចាំបងគេរ
ហើររំពេររំពៃឲ្យបាន ។ កុំថាឡើយប្អូនអើយដល់ស្រះ
ស្អាត អនោតត្តជាតរស់ទោះនៅឋាន ឆ្ងាយលើសផង
ក៏បងហើរផ្លូងជាន ទៅមិនខានបានទំនាំមកដល់ ។

ថាប៉ុណ្ណោះសសេះពោធិសត្វ ក៏ហើរកាត់អាកាស
ប្រាសដោយខ្យល់ សំដៅទៅអនោតត្តហេតុតែផល
បុណ្យកុសលពុទ្ធោពោធិសត្វ ។ ហើរដោយខំបំប្រះបុះ

ម្នីម្នា ហើយបៀមពាំគង្គាលេលោហ្វាត កាលដែលហើរ
តិចមកទឹកហ្វាតបាត់ សូន្យក្នុងមាត់ញាត់ចុះទៅពោះធេង
ៗ សសេះនោះលុះឆកដឹងទឹកអស់ ក៏ហិបហោះផ្លោះ
វិលចូលទន្លេង ចុះទន្ទាបក្រែបទឹកផឹកបៀមលេង គុន់
គិតល្បែងឋាពាំនាំឲ្យបាន ។ ព្រោះក្នុងពោះយើងផឹក
ទឹកឆ្អែតហើយ មិនស្រែកឡើយនឿយទ្រាំពុំប៉ុន្មាន ត្រូវតែ
បៀមកុំលេបជ្រាបក្នុងប្រាណ ហើយក៏ហើរពីឋាននោះ
ម្នីម្នា ៗ តាំងប្រឹងផ្លោះហោះហើរលើអាកាស ត្រឡប់
ប្រាលមកក្រោយដោយនភា បានតែមួយស្របក់ភ្លេច
ឆកភ្ជា មាត់ទំពាជញ្ជក់លេបទឹកអស់ ។ កាលដែល
ដឹងក្នុងមាត់ស្ងួតឥតទឹក ដូចគេភ្លឹកភ្ញាក់ខ្ទន្ទ្ទឹនហើរហោះ
វិលទៅពាំបៀមទៀតផ្ទៀតផ្លិបផ្លោះ មិនឈប់សោះលុះ
វិលប្រាំពីរសា ៗ បៀមពុំបានគ្មានទឹកដូចឆកសោះ
ពាល់តែងហោះផ្លោះទៅមករួសរ៉ា ក៏ឲ្យព្រួយប្រួបចិត្តគិត

ចិបថា ខាល់ប្រាជ្ញាត្រឡប់មកប្រាប់ញី ៗ

ថាប្អូនអើយប្អូនពៅចៅថ្លួងចិត្ត ចូរអាណិតដ្បិតបង ហើរឆ្លងទី ទៅដល់ស្រះអនោតត្តជាតភរី បងសំភីពាំ យកទឹកស្រះនោះ ៗ គឺបងបៀមពាំនាំតាមធម្មតា មាត់មិនហាតាំងចិត្តបិទជិតពុះ តែធ្វើម្តេចតិបទឹកនឹកមិន លុះ នឹងមានជ្រុះអស់ទៅក្រៅក៏ទេ ៗ គឺវាជ្រាបលេប ចូលមូលក្នុងពោះ បងពិគ្រោះបុះពាំនាំថែមទ្រេ ប្រិតិរ ដងបងអស់នឹងរិះរេ ក៏ដូចគេមិនបៀមក្រៀមស្ងួតស្បសោះ ៗ តាមតែស្រីប្រណីអាណិតបង ខុសបំណងនាងហើយ ល្ហើយពៅស្រស់ សសេះញ៉ឭហើយតឹកខ្ញុលខ្មោះ ក៏ ក្រោកដោះស្លុះភ្លាងតាំងស្តីថា ៗ អើអ្នកឯងនេះមិញ មិនពេញប្រុស ប្រាសទៅបុះមោះមិនទាន់បុ៉ណ្ណា អ្នក មិនមែនបានទៅភ្លូតមុសា អាងបំណោះបេះបាបៀមពុំ បាន ៗ ថាបុណ្ណោះហើយស្លុះទៅក្រាសបីក ឈ្លើ

ក្រញិកក្រញីដោយសាមាន្យ ដេរប្រទេបផ្កាសាខ្វាខ្វាប ប្រាណ ឈ្មោលពុំហ៊ានប្រទេកឥតមាត់ក ។ លេះតែ ទុំសាំកក្រុកមុខស្លុតស្ងប់ មិនវឹងស្តាប់ញីឡើយឆ្លើយអង្វរ ដោយអាការសោរភាពរាបស្មោះសរ ទាំងឱបអរមេត្រីក្តី ស្នេហា ។ ព្រះនាងនាបចើរស្រីវិលក្ខណ៍ នាំប្រវត្តិ ផុតវិគ្គមកបរបា ទូលសុំទោសព្រះមុនីនាថសាស្តា សូម ទ្រង់ករុណាប្រោសប្រណី ។ ខ្ញុំពិម្ពាជាខ្ញុំធំលើម្ចាស់ អាចបំពានប្រាសព្រះអង្គទ្រង់បារមី ដោយរំលោភរំលងផ្គង់ ច្បាប់ស្រី ពេញសេចក្តីប្រមាទខាតលក្ខណា ។ លំដាប់ នោះព្រះសង្ឃនឹងគ្រហស្ថ បុថុជ្ជនទាំងអស់ក្រាសតណ្ហា បានស្តាប់រឿងសរសេះសត្វបក្សា ញីប្រហារតិះដៀល ឈ្មោលលើសលុប ។ សង់សាំគ្នាខ្សឹកខ្សួលអួលឱរា អាណិតព្រះសាស្តាបារូបមភព ទើបព្រះនាងទៀងទូល ពោលប្រារព្ធ ជាបពិត្រព្រះសព្វញ្ញូញាណ ។

កាលសាសនាព្រះនេយ្យវិះពុទ្ធ ជាបមមកុដិមោលី លោកប្រធាន នោះព្រះអង្គនឹងទុំពុំធ្វើទាន ពុំដែលមាន សីលសត្យសុចរិតបី ។ កំរង្វេងទៅកើតជាសត្វអក តែងសំកកជ្រកទុំបាំបាប់ត្រី ខ្ញុំអម្ចាស់ញាស់ពងគ្រង កូនខ្ចី ខ្លួនព្រះអង្គអកប្តីខ្ញុំឧស្សាហ៍ ។ ហើរសូះស្វែង ឯងឯងឯករកចាប់ត្រី នាំមកឲ្យកូនខ្ចីនឹងមាតា ជាទេស កាលពេលមួយខ្យុអស្សាឍ្យ មានភ្លើងឆេះរុក្ខាជាខ្លាំងព្រៃ ។ អណ្តាតភ្លើងឆេះឡើងប៉ើងត្រសុក ឆាបឆ្លួលដល់សម្បុក អកឯងៗ កូនក៏ជ្រុះប៉ះលើភ្លើងទៀបក្បែរ អកឈ្មោល ញីស្មើដៃវ៉េទទះ ។ លត់អណ្តាតអគ្គីនឹងស្លាប ហើយ ហើរឆាបចាប់កូនមួនមិនលះ ភ្លើងរលត់បុត្ររួចភើប បានឈ្នះ ដោយគេជះព្រះពង្សពោធិសត្វ ។ ដែល អំពល់ទល់ទុក្ខមុខវេទនា ព្រោះពិម្ពាជាហេតុភេទឧប្បត្តិ នាំព្រះអង្គវង្វេងវែងយូរក្លាត់ នៅប្រវាត់ក្នុងវាលវដ្តសង្សារ

ឲ្យវិលកើតវិលស្លាប់រាប់មិនធួន តាមរុកក្លួនព្រះអង្គឲ្យ
បង់ការ ក៏ពីព្រោះតែខ្ញុំសាំខាំងខា ព្រះសាស្តាឲ្យទ្រង់
បង់កម្លាំង ៗ ទើបព្រះនាងភ្លាងនាំនិទានត ថាបពិត្រ
ព្រះបរមនាថ ដ៏មានធូរព្រះគុណអនន្ត កាលកំបាំង
បាត់ស្ងាត់អតីតា ៗ

មានព្រះពុទ្ធមួយអង្គទ្រង់នាមនៃ ព្រះមារវិជ័យ
ប្រពៃថ្លា ព្រះអង្គចុះមកត្រាស់ក្នុងលោកា ខ្ញុំពិម្ពានឹង
ទ្រង់បង្កើតច្បាស់ ៗ ជាក្រសត្រខត្តិវង្សគ្រងក្រងក្រៃ
ព្រះបមត្រៃព្រះនាមតាមសម៉ាស់ ឈ្មោះព្រះបាទអភង្គ
ទ្រង់តបះ ខ្ញុំអម្ចាស់នាមនាងអះនោមា ៗ ជាឯកអង្គ
មហេសីប្រពៃស្រស់ ព្រះអង្គស្មោះស្រឡាញ់ពេញទ័យា
មាននារីឧត្តមស្នំស្រីង្គារ មានយោធាទាហានយាម
ប្រាសាទ ៗ មានមន្ត្រីវិសេសនវាំងដំណាក់ មានឯកអគ្គ
សេនាបមហាមាត្យ មានរាជគ្រូប្រិយវង្សគង់គាល់បាទ

មានគ្រប់ខ្នាតគួរស្នាមប៉មបន្ទាយ ។ មានសម័យថ្ងៃមួយ
ព្រះជាយា អនោមានារីភិរម្យរាយ គាល់ព្រះបមបក្រពង្ស
ទ្រង់និយាយ ដោយឧបាយយោបល់គល់ប្រដិព័ទ្ធ ។
ឋាបពិត្រព្រះអង្គទ្រង់សម្ភារ ខ្ញុំជាស្រីស្រោល
មិនដែលស្មាត់ ឮតែចាស់បុរាណបានប្រវត្តិ ពោល
រាល់មាត់ថាព្រៃព្រះហិមពាន្ត ។ បើនឹងទៅជ្រៅឆ្ងាយ
សប្បាយណាស់ ភ្នំកៃលាសខ្ពស់ខ្ពង់សឹងវិមាន នៃកិន្នរ
នាគគ្រុឌសត្វហោះធ្យាន លោកបានឈានទំនើបទើប
ទៅដល់ ។ ធ្វើម្ដេចន៍ពរម្ចាស់នេះដឹងអ្វី ខ្ញុំជាស្រីខ្លៅ
ខ្លាចអំណាចខ្យល់ ខ្លាចវេហាស៍អាកាសខ្ពស់ស្កឹមស្កល់
បើមានផលសំណាងជាងបេះពោះ ។ ក៏នៅខ្លាចពុំអាចរួច
ទៅបាន ព្រោះសន្តានអ្នកថយ ឲ្យអាប់យស នឹងទៅ
ហើយស្មើរយបិត្តគិតស្រណោះ មិនគួរសោះមកកើត
ភេទជាស្រី ។ ព្រះបក្រពង្សទ្រង់ឮសូរវាចា ព្រះកន្ដដ្ឋ

វិលក្ខណ៍អគ្គមហេសី ក៏ឲ្យក្ដួលអាណិតគិតប្រណី ព្រះបក្រីវៃត្រាស់ប្រាស់ថា ៗ ព្រះលឹងបងឆាងនឹងចង់ ខ្លាំងណាស់ ទៅមើលភ្នំកៃលាសភ្នំហិមវា បងនឹងជូន ប្អូនទៅតាមត្រូវការ ទោះប្រាថ្នាទៅទៀតក៏ឆ្លៀតបាន ៗ

លុះព្រឹកព្រាត្រគប់សព្វបប់ពុំលង់ ព្រះចមពង្សបង្គាប់ ជាងចំណាន ឲ្យរចនាជាហង្សមាសរូបហាន ដូច សណ្ឋានហង្សរស់ផ្ដោះពោះហា ៗ រូបធំជាងហង្សសត្វ សុទ្ធប្រើចក្រ មានខ្សែយន្តកន្ត្រាក់ដាក់ប្រែងខារ ពីលើ ខ្នងមានខ្នាតស្អាតរចនា ជាក្រឡាកំសាលផ្គាល់ស្ដេច គង់ ៗ មានកន្លែងស្រីប្រុសបំណុះរាប់ ប្រាំបួនដប់នាក់ នៃបងបតាមខ្នង កាលបើជាងធ្វើរួចស្រេចពុំលង់ ព្រះចម ពង្សនឹងនាងយាងលេណា ៗ ព្រមដោយស្រីភីលៀងនឹង ជាងចក្រ មួលកន្ត្រាក់យន្តពោះផ្លោះម៉ីមា ស្ដេចដោយ ហង្សខ្ពង់ខ្ពស់ហួសវេហាស៍ ព្រោះឫទ្ធានុភាពឆាបហៀវ

ហោះ ៗ កាត់តម្រង់ត្រង់ទិសឧត្តរា លុះសុរិយា
សាយណ្ហទន់ទៀបសោះ ស្ដេចទៅដល់ទួលខ្ពស់ឃ្លួសរេ
បន្ទោះ ភ្នំជាកោះសង្កាត់សត្តបរិភ័ណ្ឌ ៗ យុគន្ធរនិមិន្ធរអស្ស
កណ្ណ ករវិកាឥសិន្ធរវិនត័ នឹងព្រះបាររៀងទូជាជួរជាន់
មានសិធន្តសាគរតអណ្ដាប់ ៗ ជាន់កណ្ដាលទោលទូ
សុមេរា ខ្ពស់ស្ហាជាធំភ្នំតាន់តាប់ ហង្សរង់រេលេលាបុះ
បកបាប់ លើខៃនស្រាប់ជាអាសន៍កែលាសឋាន ៗ ព្រះ
បមពង្សទ្រង់នាំនាងយុរយាត្រ យាងប្រពាតលើភ្នំជុំដែន
ជាន ទតម្រឹគព្រឹក្សជាសំពន្ធ លុះស្សូរផានអស្ដង្គបាំង
គិរី ៗ ដោយទេវឫទ្ធិនិម្មិតប្រាង្គប្រាសាទ ប្រសើរស្អាត
អណ្ដែតលើនភា បុះមកជាប់កំពូលភ្នំមោលី ថ្វាយព្រះពង្ស
ពោធិនឹងមហោស្រ ៗ ពោធិវង្សគង់ក្នុងប្រាង្គមណីរតន
ហើយសោយភត្តទិព្វាហារបំណើ សឹងឱជារសូមព្រមព្រះ
ស្រី ភគវតីបិយោអនោមា ៗ ត្រឹមតែទ្រង់គង់ប្រាំពីរថ្ងៃ

នៅលើកៃលាសគិរីវេហាស៍ មានបក្រទិព្វសម្រាប់បុណ្យ
សម្ភារ សាត់អណ្តែតមកជាយានព្រះអង្គ ។ ទាំងមាន
ឫទ្ធិមានរូបភាពប្រាសាទ ធំពេញខ្នាតស្អាតស្អាងយ៉ាង
ត្រចង់ ភ្លឺត្រចះត្រចែងលើសលែងហាក្យ ដោយ
អានិសង្សឲ្យគង់ទ្រង់ហៀវហោះ ។ កាលព្រះអង្គទ្រង់
គឹករលឹកភាំង បក្រទីតាំងដឹងន័យអៃតាំផ្លោះ ត្រង់ព្រះ
រាជមន្ទីរពានស្មោះ មួយជំទាស់ក្របកស្តេចមកដល់ ។
សោយសម្បត្តិសំបូរឥស្សរយស ស្រួបកំពស់កំពូលមូល
សាកល ក្នុងជម្ពូទីបទ្វីតិរទុក្ខល់ ដោយកុសលផល
ពោធិសម្ភារ ។ បពិត្រព្រះមុនីមោលីលោក ខ្ញុំអម្ចាស់
ផ្លាស់ជោគផ្លាស់ឫកពា ពីអាក្រក់ធ្លាក់ល្អក្រទៀងជា
មានភោគាហើយខ្សត់អត់ស្រែកឃ្លាន ។ ក៏ព្រមមួយ
ដោយជិតឥតឃ្លាតឃ្លា ពីព្រះបមភពនាថជាប្រធាន
ព្រះអង្គសុខខ្ញុំសុខទុក្ខមិនមាន ព្រះអង្គពានបានទុក្ខខ្ញុំក៏

ទុក្ខ ៗ ព្រោះព្រះអង្គនឹងខ្ញុំជួបជាតិ ពុំឃ្លាឃ្លាតប្រហាំ ឧបត្ថម្ភក(១) វិស័យរូបស្រមោលហ្គោលនៅមុខ តែងទំនុក មកជាប់រាប់មិនធ្លន ៗ កើតជាតិណាជាមនុស្សឬជា សត្វ ពៀរវិបត្តិព្រាត់ប្រាសនិរាសម្ងួន សោកក៏សោក យំក៏យំក្រិក្រាសក្រួន ឬក៏ជួនបានស្ដើងវង់វៀងក្រែ ៗ មិនតែដើរលើដីបណ្ដោយប្រាស ហោះអាកាសជាសដិត ផុតវិស័យ ដូចព្រះបាទអភង្គនឹងស្រីថ្លៃ ពិស្ម័យមាន បក្រនឹកគិតបាន ។ ហេតុដូច្នេះខ្ញុំម្ចាស់អស់ជាតិភព សូមប្រារព្ធលុបលាងរាងទោសប្រាណ ទោះដោយកាយ វាចាចិត្តសន្តាន ដែលប្រមាណប្រមាទឃ្លាតត្រង់ណា ៗ កុំសូម្បីន័យដឹងជាយ៉ាងល្អិត ទោះប្រណិតតិតដឹងតូចរង់ ធ្នារ ខ្ញុំក៏សុំព្រះអង្គទ្រង់មេត្តា លើកទោសានុទោសប ប្រោសឲ្យអស់ ៗ

---

(១) ឧបត្ថម្ភក = បាលី. ប្រែថា អ្នកទំនុកបំរុង. ត្រូវថា ឧបត្ថម្ភក

ទើបព្រះនាងភ្លាងទូលទំនូលត ជាដំណាដំណាល ពោលឲ្យស្មោះ ជាបពិត្រព្រះសត្ថាមហាបុរស កាលបន្ទោះសាសនាព្រះគម្តែង ។ អើតសព្វញ្ញូមោលីលុបទ្រង់កើតជាមាណពតុបតាក់តែង ធ្វើទានសីលភាវនាជាអង្វេង មាណពឯងនាមហៅចៅសុខមា ។ ខ្ញុំអម្ចាស់ឈ្មោះនាងមបារិយៈ បានរួមរ័កជាគូយវវិស្សា តែនាងនោះទ្រុស្ដសីលខិលត្រូវការ មិនប្រាថ្នាបរិច្ចាគឧបដ្ឋាកសង្ឃ ។ មានគំនិតគិតកាញ់កំណាញ់ស្វិត មិនចូលចិត្តធ្វើទានមានខ្លាចបង់ ឯមាណពជាប់គិតឥតបង្អង់ មានបំណងបង់ចែករំលែកទ្រព្យ ។ ហើយនិមន្តសមណៈព្រាហ្មណ៍ព្រឹទ្ធ មកបូជាភោជនីយ៍តាមទំលាប់ ប្រពន្ធខឹងប្រឹងឈ្លោះគំរោះជាប់ ព្រោះពុំគាប់ចិត្តឆ្ងាយស្តាយទ្រព្យ ។ ប្ដីពុំស្ដាប់ប្រាប់ទូន្មានប្រដៅ ជាតែនៅកុំទៅខំក្រោធា យើងកើតមកជាមនុស្សមានយសងារ សម្បត្តិហារហួរសំបូណ៌បុណ្យ ព្រោះនិស្ស័យបាយ

បែករំលែកទ្រព្យ ឃ្មុំជាប់ជាទានមានជំនុន នឹងសង្គ្រោះ
មនុស្សប្រុសត្វខ្សត់អាប់ឫន មិនរិះគន់កំណាញស្រឡាញ់
ស្តាយ ។ បើជានាងវៀងវិសចៀសបរិច្ចាគ កម្ម
លំបាកយ៉ាកបុនដុនដាបកាយ កាលបើស្លាប់ទ្រព្យយើង
គង់អន្តរាយ បាត់ខាតខ្ចាយមិនងាយនាំទៅបាន ។
រូបដែលស្លាប់គេកប់ផុតស្រឡះ បុរាណចាស់តែងថាជា
លំអាន តែមួយស្លឹងបង់មាត់ភ្លាត់ខូចខាន គ្មានដែល
បាននឹងតាំតាំទៅណា ។ អ្នកកំណាញ់កាញ់គិតបិត្ត
លាមក ស្លាប់ធ្លាក់ទៅនរកទុក្ខក្តៅផ្សា ហេតុដូច្នេះប្រុស
បងប៉ងប្រាថ្នា ឲ្យកល្យាណបានបុណ្យទុនទៅមុខ ។
ប្តីនិយាយរាយរៀបធៀបយ៉ាងណា ប្រពន្ធមិនជ្រែះថ្លាតាម
ទំនុក សុខមាណពតែងឧបត្ថម្ភក(១) តតាំងទុកបរិច្ចាគ
លាកលះទ្រព្យ ។ ធ្វើជាទានមានបាយទឹកបម្រុង
ជាអម្ពូងក្នុងជាតិនោះញឹកញាប់ កំក្តៅដល់កោសិស្តី

(១) ឧបត្ថម្ភក = ត្រូវអានថា ឧបត្ថម្ភក ។

បង្គាប់ ព្រះមាតលីលេលាប់ធាប់ម្ហូម្ហា ។ ទើបទេវបុត្ត
នាំរថវិសុទ្ធថ្មី ចុះមកទ្រពរបីនៃអង្គមា ណាពឲ្យជិះរថថ្កើង
ឡើងសួគ៌ា ព្រះឥន្ទ្រាក៏បែងវិជ្ជិងវិមាន ។ ឲ្យចៅសុខ
មាណពសោយទិព្វរាជ ពេញអំណាចជាស្ដេចព្រះសប្ត-
ទាន នៅយូរលង់ក្នុងសួគ៌ជាប្រធាន ប្រែវិញ្ញាណរឭក
នឹកភរិយា ។ ទើបសំពះព្រះឥន្ទ្រមកកាន់ភព សុខ
មាណពជួបជុំខំនាំពារ ឲ្យប្រពន្ធភជ័យន្តព្រះឥន្ទ្រា
គន់ទេវាមាតលីសារបឹបរ ។ នាងកំណាញ់ក៏ចេញមើល
ឃើញប្ញាស ភ្លឺត្រចះអស់រូបទេពនិករ ទោះទាំងមឹងនាង
ឥតគិតស្មោះសរ ប្ដីអង្វរឲ្យកាន់សីលឲ្យទាន ។ ក៏មិន
កើតជ្រះថ្លាលុះសទ្ធា គងរឹងជាកំណាញ់ទ្រព្យធនធាន
ប្ដីភិទាលជម្រុននឹងខ្ញាន លុះវិញ្ញាណរលត់ផុតជីវី ។
ក៏ធ្លាក់ចុះនរកទឹកពុះក្ដៅ បំរណៅខ្ពះសោហកុម្ភី ជា
អង្វែងយូរយារគេឃាយ ឲ្យផឹកស៊ីទង់ដែងរ៉ែងរៀទនា ។

ហេតុដូច្នេះព្រោះតែខ្ញុំម្ចាស់ កំណាញ់ណាស់លើស លុបងាប់ផែវា សូមព្រះអង្គទ្រង់ប្រោសទោសពិម្ពា ឲ្យអហោសិ ជាសូន្យស្រឡះ ។

ទើបព្រះនាងភ្លាងទូលពោលពណ៌នា ឋាកាលគ្រា ខ័ណ្ឌាទ័បកប្បយូរណាស់ មានក្រសត្រមួយអង្គទ្រង់តបះ ព្រះនាមព្រះបាទពន្ធុមតី ។ នៅនគរពន្ធុមរម្យរដ្ឋ ជាព្រះពុទ្ធបិតាព្រះវិបស្សី ឯព្រះពុទ្ធមាតាកល្យាណី នាមព្រះស្រីវិបស់ទ្ធរត័នកញ្ញា ។ កាលព្រះពុទ្ធវិបស្សីស្រីសារពេជ្រ បានត្រាស់ត្រាប់សម្តេចព្រះបិតា ទ្រង់ភិយ្យោសោមនស្ស កើតជ្រះថ្លា ត្រាស់ឲ្យសង់សាលាវិហារវត្ត ។ នៅក្នុងទីបរិវេណដែនក្រុងក្រៃ ប្រសើរថ្លៃផ្ទៃធំមាំពេញពន្ធ ហើយនិមន្តព្រះពុទ្ធរាជបុត្ររតន៍ នឹងសាវកបរិសទ្យពុទ្ធបរិវារ ។ មកប្រថាប់ជួបជុំពុំមានសល់ គណនាជលពីរសែនរំណានរដ្ឋា រួចព្រះបាទបពិត្រខត្តិយា ឲ្យជញ្ជូនបុប្ផា

ធ្វើកំផែង ។ ប្រាំពីរជាន់មានទ្វារបិទសោចាក់ ស្ដេចឲ្យ
ដាក់ទឹក-បាយដោយកន្លែង ថ្វាយព្រះពុទ្ធព្រះសំឃអង្គ
គម្ដែង ព្រះអង្គឯងរង់រាប់សព្វពេលា ។ ទ្រង់ផ្គង់ផ្គត់ភត្ត
ទានគ្មានខ្វះខាត ទាំងសង្ឃាតស្ដាប់ធម៌រាល់ទិវា ព្រោះព្រះ
ទ័យព្រះអង្គទ្រង់សទ្ធា រាស្ត្រប្រជាមិនឲ្យដោយធ្វើផង ។

វេលានោះមនុស្សម្នាជាទុក្ខខ្លាំង ព្រោះស្ដេចខាំង
តាំងតែផ្ដើលអឹងកង លើកពួកម៉ាកជាទ័ពជាប់បំណាង
នឹងបួលបងប្របាប់ស្ដេចនោះណា ។ ក្នុងខណៈលើក
ពលជលកំផែង ក៏កំហែងនឹងគាស់ពុះសេមា រាជអាមាត្យ
ស្លុតភ័យវិឆ្លា ទើបបរបាសាកសួរសព្វសេចក្ដី ។
បណ្ដារាស្ត្រទាំងនោះស្រុះឆ្លើយថា យើងត្រូវការមក
ចាប់ស្ដេចមន្ត្រី ពីព្រោះពោះអាក្រក់ល្មក់អប្រិយ៍ មិន
ប្រពរ៉ាសព្រោះរាស្ត្រប្រជា ។ ឲ្យបានបួលធ្វើទានមាន
បាយទឹក យើងរឭកនឹកព្រះព៌ឈ្នះមារ រាជបុរសព្វ

ហើយឆ្លើយរាំងរា ថាបើប្រោះអស់គ្នារង់សិនចុះ ។ យើង
នឹងចូលទៅទូលព្រះរាជា ឲ្យអស់គ្នាធ្វើបុណ្យបានមិនខុស
រាជអាមាត្យដោះសាតែប៉ុណ្ណោះ ក៏ស្រែស្រុះឆ្ពោះកាន់
ព្រះពន្លា ។ យកសេចក្ដីអំទូលពោលតាមត្រង់ ថាបពិត្រ
ព្រះអង្គទ្រង់សម្ភារ ដ្បិតអ្នកស្រុកផ្សឹកផ្អើល ជ្រួលនាំគ្នា
លើកយោធាទាហានមានច្រើនណាស់ ។ ថានឹងតារកាំផែង
លែងគិតខ្លាច ដោយអំណាចវាខឹងនឹងអម្ចាស់ បិទ
បន្ទាយមិនឲ្យចូលថ្វាយព្រះ ឃើញពុំឈ្នះប៉ះរាក់ពុំបាន ។

ហេតុដូច្នេះអស់យើងខ្ញុំទាំងឡាយ សូមទ្រង់
ផ្សាយមេត្តាភិសព្វថាន ឲ្យចូលមករកព្រះខ្លះកុំខាន
ទើបនឹងក្សាន្តសប្បាយដោយបារមី ។ ព្រះរាជាឮហើយ
ឆ្លើយតបថា ម្នាលសេនាអាមាត្យមុខមន្ត្រី ថ្វីបើរាស្ត្របះ
បោត្តុជរ មកធ្វើអ្វីធ្វើបុះទោះប្រហារ ។ ដល់ជីវិតបាត់
បង់យើងពុំស្ដាយ ព្រោះរូបកាយនឹងចិត្តឥតខ្លឹមសារ

យើងស្រឡាញ់តែទានសីលសត្យា សមាធិបញ្ញាពឹងខាងមុខ ៗ អស់មន្ត្រីសេនីយនួរសេនា ឮឱង្ការដូច្នោះ ប៉ុះកើតទុក្ខ ថាព្រះអង្គទ្រង់ជាម្ដាយអាពុក សុំទំនុករក្សាប្រជាជន ។ ដែលបន្ទូលការពោះតាមព្រះទ័យ ពុំអភ័យឲ្យរាស្ត្រលះទ្រព្យធន ធ្វើកុសលផលសោះ ខុសទម្ងន់ មិនមែនមន្តបន្ទូលព្រះទេសនា ។ សូមព្រះអង្គទ្រង់ផ្សាយព្រះទ័យស្មោះ ជាសប្បុរសដោះទុក្ខអ្នកជ្រះថ្លា ទើបជាធម៌ប្រសើរគួររាប់ថា ព្រហ្មវិហារអាណិតអាសូរសត្វ ។ ហេតុដូច្នេះយើងខ្ញុំសុំព្រះអង្គ រំលែកមែកអានិសង្សទ្រង់លះកាត់ បែកជាផលបង្ហាន់ឲ្យទានណាត់ថ្ងៃទីមួយសម្បត្តិព្រះរាជា ។ ថ្ងៃពីរអាមាត្យព្រះញាតិវង្ស ថ្ងៃទីបីរាស្ត្រផងតាមសទ្ធា ហើយត្រឡប់ចាប់ដើមតាមរៀងគ្នាគ្រប់ទិវារាត្រីបីផែនស្រេច ។ បើទ្រង់ប្រោសប្រទានដាក់ផែនបែក តាមបំណែកបែករាស្ត្រនាហ្មឺនស្ដេច អ្នកក្រា

ក្នុងគង់នឹងដឹងបំណាច់ ទ្រង់មិនបាប់អាចព្រួយដោយ
សោភា ។ មហាក្រស័ត្រីទ្វរង់ទ្រង់បានស្តាប់ កំបុះបាប់ព្រះ
ទយវៃសទ្ធា ព្រមបំណែកបែកវេនមានវេលា តាមភ្នាក់ងារ
ទូលសុំជាកំណត់ ។ ទើបព្រះអង្គទ្រង់បាត់ការប្រសាសន៍
តាំងភិយស្គរប្រកាសរាស្ត្រប្រាកដ ឲ្យធ្វើទានតាមវេន
មានបែបបទ ស្រេចម៉ត់បត់គិតសៅក្តៅក្រហាយ ។

ដំណាលពីសេដ្ឋីមួយជាធំ មានកូនស្រីក្រមុំសមរូប
កាយ គ្រប់អាយុសោះឡូសស្រស់ឆោមឆាយ មានតែ
ម្តាយមេម៉ាយនៅមួយគ្នា។ឯសេដ្ឋីបិតាអនិច្ចកម្ម ជាយូរឆ្នាំ
មកហើយដោយជរា នាងមេម៉ាយនឹងកូនមានទ្រព្យ
គណនាត្រាវាប់សព្វតុំអស់ ។ មានមន្ទីរប្រាសាទស្អាត
ពណ្ណរាយ ធំទូលាយល្វើយល្វឹងសឹងល្អស្រស់ មាន
បន្ទប់គ្រប់ថ្នាក់តាក់តែងស្មោះ ប្រាំពីរជាន់ចន្លោះខ្ពស់
ស្កឹមស្កៃ ។ កូនក្រមុំពុំដែលដើរទៅណា នៅតែលើ

ប្រាង្គប្រាសាទថ្លាថ្លៃ កាលបើឮស្នូរស្គរវេលាថ្ងៃ មាន
សម័យនឹងចង់ដឹងពត៌មាន ។ ទើបប្រាណបើកបង្អួចលួច
ផ្ទៀងស្តាប់ ឮស្នូរស័ព្ទគឹកកងរំពងសៀន ជាអ្នក
ស្តេចសម្រេចឱ្យធ្វើទាន មិនឱ្យពានរើនគ្នាជាបីប៉ែក ។
គឺរើនៈស្តេចនាហ៊ឹននំដំរើនរាស្ត្រ នាងក៏ផ្ទៀសផ្ទះដឹងក្នុង
ចំណែក ឃើញជារិនព្រៃថ្ងៃក្នុងថ្ងៃស្រុក នាងសង្វេគ
នឹកយល់ដល់ម៉ែរា ។ ឱអាត្មាអញអើយ ជានសោយ
បុណ្យ កាលនៅចិត្តមានទ្រព្យសព្វប្រការ ព្រោះជាតិ
មុនធ្វើទានច្រើនណាស់ណា ទើបផលាឱ្យមានគ្មាន
បន្លោះ ។ តែអនិច្ចាបិតាអាយុខ្លី ស្លាប់ចោលកូនជាស្រី
ចោលរបស់ តឡូវនេះអាយក្រួនសោឡស កូនស្រណោះ
អាត្មាកទុក្ខកំដែង ។ បើជាឱនៅរស់ម៉្លេះសុខ្ខា ចាយ
ទ្រព្យធ្វើទានមានផ្សែងជា ព្រោះក្រុងនេះព្រះត្រាស់ប្រកាស
ម៉េះម៉ឹង ជានៅផឹងឱ្យយល់ស្លាប់ចិត្តាន ។ នាង

បរិវត្តកុជាទុក្ខក្រៃ តាំងតែសោកាល័យលង់វិញ្ញាណ ឯមាតាសេដ្ឋីស្រីវិះធ្យាន ឃើញបុត្រីមានយោបំយំអួលអាក់ ក៏សែនសល់ពិភាល់ធ្ងល់សួរថា ម្នាលធីតាកល្យាណកូនមានលក្ខណ៍ កូនឈឺអ្វីស្រីម្តាយក្នុងកាយអ្នក ឬធុរៈធុរន់គន់គិតអ្វី ។ នាងកល្យាណបានឮមាតាសួរ ក៏សមគួរតតបសួបសំដី អ្នកម្តាយអើយអ្នកម្តាយកាយកូនស្រី គិតឈឺអីឲ្យអាក់ប្អាក់បិត្តា ។ កូនក្រៀមក្រំយំសោកអាមោកទុក្ខ នឹកអាពុកដែលស្លាប់ស័បសង្ខារ បើជារស់ដល់ពេលនេះម៉្លេះជ្រះថ្លា បានរក្សាសីលស័ត្យគិតធ្វើទាន ។ ថ្វាយបូជាព្រះពុទ្ធជាមកុដលោក ព្រោះមានភោគសម្បត្តិសុទ្ធធនធាន ព្រោងភិសនាអាពុកកើតមកមាន សីលជាយានទានជាស្បៀងលៀងអាត្មា ។ មិនសមបីខ្លីជន្មស្លាប់មុនព្រះ ខានប្រទះលះទ្រព្យសព្វប្រការ កូននឹកហើយឲ្យគិតអាណិតផ្សា សូមមាតាអ្នកជ្រាបសព្វសេចក្តី ។

ម្តាយឪស្មោះចុះចិត្តអាណិតណាស់ ឆ្លើយរហាស់ថា ហៃប្លៃពិស ទ្រព្យយើងមានច្រើនណាស់ចំរុះអូស្រី នឹងក្រក្រីក័យក្រែងតែងមិនគ្រាន់ ។ បើធ្វើហើយកូនអើយ ឲ្យឧទ្ទិស ផលអាមិសស្មោះស្មានជូនទន្ទាន់ គង់ទៅដល់អាពុកមុខមិនភាន់ ទោះទៅជាន់ឋានណាគង់នឹងបាន ។ តែះបើធ្វើកុំធ្វើលើវេនស្តេច គិតឲ្យស្រេចទៅចុះក្រែងខុសខាន នាងធីតាឮហើយឆ្លើយសងសាន ឋាមាតាប្រមាណមិនត្រូវសោះ ។ បើនឹងរង់អង់ចាំទំរាំស្រេច ហួសវេនស្តេចទន្ត្រីបីថ្ងៃស្មោះ ខុសសទ្ធាជាយូរជឿចយអស់ សូន្យស្របប្បវរស្រុះប្លាអសារក្រៃ ។ ការត្រង់ណោះចំពោះលើឈ្មោះខ្ញុំ អ្នកម៉ែកុំចាព្រួយដោយខ្ញុំផ្ទៃ តាមប្រាជ្ញាខ្ញុំស្រាប់ទោះយប់ថ្ងៃ នឹងរស់ក្សុយក៏តាមកម្មផល ។ ទើបនាងធ្វើជានំសំបុកឃ្មុំ ហើយក្រងបងជាសំបុមបុមា មានទាំងផ្កាម្លិះរួចទ្រួតម្លិះលា គ្រប

លើគ្នាជាក្បាច់លេបសឹងភ្ញី ។ កាលៈបើធ្វើនំនោះរួច កាលណា ទើបយកផ្កាកម្រងសុំមទាំងពីរ គ្របលើនំ តម្រូវធ្វើសាជី ថ្កល់លើពានមណីបែបបុប្ផា ។ មើល មិនយល់ជានំធុមក្លិនក្លែប រសក្រអូបក្រៃឯបជាប់នាសា ពានមួយគួរសឹងសុវណ្ណា លុះសុរិយារៀងរះប្យាស់រស្មី ។ នាងក៏តាក់តែងអង្គរុងរឿងស្អាត ចុះពីលើប្រាសាទ រតនរង្សី វែកខ្លួនឯងជាមុខពួកបរិស្រី នាងតិត្ថហែ ហមតាមអណ្ដាប់ ។

លុះទៅដល់ទល់ទ្វារកំផែងវាំង ពួកអ្នករាំងរក្សា ទ្វារប្រញាប់ មកត្រួតមើលយល់ផ្កាធីតាស្រាប់ ក៏ ប្រាយប្រាប់អ្នកយាមភ្លាមបើកទ្វារ ។ នាងក៏វែកនំបាក់ សំបុកឃ្មុំ ចូលទៅជុំព្រមដោយស្រីបរិពារ សម័យនោះ ព្រះមកុដផុតភពភារ សម្ដទាញាណទិព្វរបស្សី ។ ជ្រាបអាការជានាងនាដិឆោមឆាយ វែកនំចាក់មកថ្វាយ

ព្រះជិនស្រី ព្រះពុទ្ធអង្គទ្រង់យាងកាន់កុដី គង់បល្ល័ង្ក
រង្សីទីប្រិយប៉ាប់ ។ បមធីតាក៏ក្រាបទៀបបង្គំ ថ្វាយទាំង
នំសំបុកដាក់បាត្រឆាប់ បាត្រក៏ពេញហៀរហូរជា
លំដាប់ នឹកស្រាប់តែពេញភាជន៍ធម្មតា ។ ព្រះពុទ្ធ
អង្គទ្រង់មានបន្ទូលស្មោះ ឲ្យនាងដោះដាក់បាត្រព្រះ
ខីណា - ស្រពគ្រប់អង្គទាំងអស់ក្នុងសាលា តាម
គណនាពីរសែនណែនក្រុងក្រៃ ។ នំក៏នៅពេញភាជន៍
មិនអាចស្រុត ទីបំផុតនាងថ្វាយព្រះបមត្រៃ ថ្វាយព្រម
ទាំងសំពត់រតនកោសេយ្យ មានតម្លៃមួយពាន់ដំឡឹង
មាស ។ រួបនាងក្រាបសំពះឧទ្ទិស្សាន ឋាតេជះខ្ញុំបាន
ផ្ចង់អង្គាស ថ្វាយទាំងនំសំពត់រតនឱភាស ពេញពោរ
ពាសចំពោះព្រះពុទ្ធអង្គ ។ ជាប្រធានបឋមជុំប្រិយប៉ាប់
រៀងរណ្ដាប់សាវកភិក្ខុសង្ឃ ខ្ញុំសុំបានសួគ៌ផុតរលត់បង់
នៅវដ្ដសង្សារជ្រែះលុះនិព្វាន ។ មុនខ្ញុំម្ចាស់ត្រាស់ត្រៃប

ជាប់កិលេស នៅសល់សេសកំណើតកើតវិញ្ញាណ ទោះជាតិនេះជាតិណាបើខ្ញុំមាន គូជាយានជាយៀនភៀន សុខទុក្ខ ។ សូមជួបជាក់លើអ្នកមានប្រាជ្ញា បេះធម៌ អាចភាសិតល្អិតទំនុក មានសទ្ធាសទ្ធម្មបត្តក ដឹង ទៅមុខទៅក្រោយដោយជ្រះថ្លា ។ ពុំកំណាញ់ស្វាញ ស្វិតបិត្តិរិយ ដឹងប្រណីអាណិតសត្វមនុស្ស ពេញ បណ្ឌិតពិតស្អាតជាតិសម្មា. ទំព្វាបារ្យគួរជាទីស្រឡាញ់ ។

ខណៈនោះអង្គព្រះសាស្តាចារ្យ ឮភាសានារីគិត គ្នេរកាញ់ ផ្សងប្រាថ្នារកគូស្វិអស់អញ បៀសកំណាញ់ ស្វាញស្វិតបិត្តិរិយ ។ ទ្រង់រំពឹងដឹងច្បាស់ព្រះធីតា មាន ភិនិហារផល់ថ្នាក់អគ្គមហេសី នែអនុជាធិរាជព្រះជិនស្រី គ្រងផែនដីស្នងក្សត្រពុទ្ធបិតា ។ ព្រោះព្រះបាទពន្ធុម បរមនាថ មានឱរសរួមជាតិនឹងតបា. គតបំផុតជាតិ មុខអ្នកនេះណា មានភិនិហារបារមីប្រពៃច្បាស់ ។

ឈ្មោះសិទ្ធត្ថក្សត្រក្សាន្តបានបរមា- ភិសេកឯកអស្ចារ្យ
ស្របត្រេចត្រាស់ ឯធីតានេះឯងគង់ផ្លៀងផ្លាស់ ជា
រហាស់ទៅតាមនាមពិម្ពា ។ ព្រះវិបស្សីល័យជ្រាប
សភាពច្បាស់ ទើបទ្រង់ត្រាស់ប្រទានពរពណ៌នា នាង
ក៏មានមនោរម្យបង្គំលា មកគ្រឹះហាជាសុខដូចប្រក្រតី ។

---

សង្ខេបសេចក្តីតែប៉ុណ្ណោះ

និទានទី ២ តទៅទៀត

★ ★ ★

របស់ជនដទៃ ប្រសិនបើចោរកម្ម ឬបរទារិកកម្ម ការរំលោភបំពាន ដែលមនុស្សដទៃបានធ្វើហើយ អំពើនោះនឹងធ្លាក់មកលើបុគ្គលនោះ សូម្បីមិនមាន ឬមិនពិត ក៏រមែងប្រាកដ គឺរមែងធ្លាក់ទៅលើបុគ្គលនោះឯង ។

បទថា ពហូនញ្ច ទុក្ខជម្មានំ (បំពេញនូវធម៌ជាទុក្ខច្រើន) មានសេចក្តីថា បុគ្គលណាម្នាក់ មិនអាចពណ៌នាថា សេចក្តីទុក្ខមានប្រមាណប៉ុណ្ណេះ ទោមនស្សមានប្រមាណប៉ុណ្ណេះ របស់អ្នកដែលត្រូវគេស្អប់ខ្ពើមបានឡើយ ។ ព្រោះហេតុនោះហើយ ទើបអ្នកដែលប្រកបរឿយ ៗ នូវកិរិយាត្រាច់ទៅតាមច្រកល្ហកខុសកាលនោះ ជាអ្នកជួបប្រសព្វនូវហេតុនៃសេចក្តីទុក្ខច្រើន គឺបានទទួលនូវសេចក្តីលំបាកច្រើន ។

## ទោសនៃការដើរមើលល្បែងមហោស្រព ៦ យ៉ាង

## បិដក

ឆ ខោមេ គហបតិបុត្ត អាទីនវា សមជ្ជាភិចរណេ ក្វ នច្ចំ ក្វ គីតំ ក្វ វាទិតំ ក្វ អក្ខាតំ ក្វ បាណិស្សរំ ក្វ កុម្ភថូនំ

ម្នាលគហបតិបុត្ត ទោសក្នុងការដើរមើលល្បែងមហោស្រព នេះ មាន ៦ យ៉ាង គឺរបាំក្នុងទីណា ក៏ទៅក្នុងទីនោះ ១ ចម្រៀងក្នុងទីណា ក៏ទៅក្នុងទីនោះ ១ ការប្រគំក្នុងទីណា ក៏ទៅក្នុងទីនោះ ១ គេប្រជុំនិយាយរឿងព្រេងឥតប្រយោជន៍ (មានរឿងចម្បាំងនៃមហាការតៈ និងរឿងរាមកេរ្តិ៍ជាដើម) ក្នុងទីណា ក៏ទៅក្នុងទីនោះ ១ ល្បែងវាយគង (ច្រៀងប្របកែ) ក្នុងទីណា ក៏ទៅក្នុងទីនោះ ១ ល្បែងវាយនាគ ក្នុងទីណា ក៏ទៅក្នុងទីនោះ ១ ។

ឥឡូវ នេះ គហបតិបុត្ត ៥ អាទីនវៈ សមជ្ជាភិចរណេ ម្នាលគហបតិបុត្ត ទោសក្នុងកិរិយាដើរមើលល្បែងមហោស្រពមាន ៦ យ៉ាង នេះឯង ។

## អដ្ឋកថា

បទថា ក្វ នច្ចំ (របាំក្នុងទីណា ក៏ទៅក្នុងទីនោះ) ដោយសេចក្តីថា របាំទាំងឡាយ មានការរាំរែក និងលោនជាដើម មាននៅក្នុងទីណាហើយ ក៏ចូលទៅកាន់ស្រុកឬនិគមដែលមានរបាំនោះ ។ ពេលអ្នកដែលត្រៀមសំពត់ គ្រឿង

ក្រអូបនិងផ្កាឈើជាដើម ក្នុងថ្ងៃនេះដោយគិតថា ព្រឹកនេះ អញនឹងទៅមើលបោះបស់គេ ត្រូវចោលការងារពេញមួយថ្ងៃ ។ រមែងប្រាកដក្នុងទីនោះពេញមួយថ្ងៃខ្លះ ពីរថ្ងៃខ្លះ បីថ្ងៃខ្លះ ដោយការមើលចាំ ។ អ្នកដែលដើរលេងយប់ សូម្បីក្នុងផ្លូវកៀនច្រកជាដើម ក៏មិនធ្វើការសាបព្រោះ កាលបើដូច្នោះ ភោគៈទាំងឡាយដែលមិនទាន់កើតឡើង ក៏មិនអាចកើតឡើងបាន ។ កាលបើផ្ទះមិនមានអ្នកចាំមើល ពួកចោរបានដឹងច្បាស់ថា ម្ចាស់ផ្ទះចេញទៅខាងក្រៅហើយ រមែងលួចយករបស់ដែល ខ្លួនចង់បានទៅ ។ ព្រោះហេតុដូច្នោះ សូម្បីភោគៈដែលកើតឡើងដល់បុគ្គលនោះហើយ ក៏រមែងវិនាសបាត់បង់ទៅវិញ ។

សូម្បីបទថា កូ គតំ (ចម្រៀងក្នុងទីណា ក៏ទៅក្នុងទីនោះ) ជាដើម ក៏មានន័យដូចគ្នានេះដែរ ។ ការធ្វើផ្សេង ៗ របស់ជនទាំងនោះ លោកបានពោលហើយ ក្នុងព្រហ្មជាលសូត្រ ។

## ទោសនៃការលេងល្បែងភ្នាល់ ៦ យ៉ាង

## បិដក

*ឆ ខោមេ គហបតិបុត្ត អាទីនវា ជូតប្បមាទដ្ឋានានុយោគេ ជយំ វេរំ បសវតិ ជិនោ វិត្តមនុសោចតិ សន្ទិដ្ឋិកា ធនជានិ សភាគតស្ស វចនំ ន រូហតិ មិត្តាមច្ចានំ បរិភូតោ ហោតិ អាវាហវិវាហកានំ អប្បត្ថិតោ ហោតិ អក្ខធុត្តោ បុរិសបុគ្គលោ នាលំ ទារភរណាយាតិ ម្នាលគហបតិបុត្ត ទោសក្នុងការប្រកបរឿយ ៗ នូវការលេងល្បែងភ្នាល់ ដែលជាហេតុជាទីតាំងនៃសេចក្ដីប្រមាទនេះមាន ៦ យ៉ាង គឺ បុគ្គលនោះ បើឈ្នះគេតែងបានពៀរ ១ បើចាញ់គេតែងសោកស្ដាយទ្រព្យសម្បត្តិ ១ វិនាសទ្រព្យសម្បត្តិដែលឃើញជាក់ស្ដែងទាន់ភ្នែក ១ កាលបើទៅសាលាវិនិច្ឆ័យគេមិនជឿស្ដាប់ពាក្យ ១ ពួកមិត្តអាមាត្យតែងបោះបង់ចោល ១ ជាបុគ្គលដែលគេមិនត្រូវការដណ្ដឹង ឬឲ្យកូនស្រី ព្រោះគេគិតថា បុរសបុគ្គលអ្នកលេងល្បែងភ្នាល់ មិនអាចចិញ្ចឹមប្រពន្ធបានទេ ១ ។*

*ឥមេ ខោ គហបតិបុត្ត ឆ អាទីនវា ជូតប្បមា-ទដ្ឋានានុយោគេ ម្នាលគហបតិបុត្ត ទោសក្នុងការប្រកបរឿយ ៗ នូវការលេងល្បែងភ្នាល់ ដែលជាហេតុជាទីតាំងនៃសេចក្តីប្រមាទមាន ៦ យ៉ាងនេះឯង ។*

## អដ្ឋកថា

*បទថា ជយំ វេរំ (បុគ្គលអ្នកឈ្នះគេតែងបានពៀរ) មានសេចក្តីថា អ្នកឈ្នះរមែងកាន់យកនូវសំពត់សាដក ឬសំពត់ជូតក្បាលរបស់អ្នកដទៃ ត្រង់កណ្តាលជំនុំជន ដោយគិតថា យើងឈ្នះហើយដូច្នេះ ។ អ្នកឈ្នះរមែងបាននូវពៀរក្នុងបុគ្គលដទៃនោះថា អ្នកឯងមើលងាយអាត្មាអញត្រង់កណ្តាលជំនុំជន មិនអីទេ (ថ្ងៃក្រោយ) អញនឹងផ្តល់នូវមេរៀនខ្លះដល់ឯងមិនខាន... អ្នកឈ្នះរមែងជួបប្រសព្វនូវពៀរដូច្នេះ ។*

*បទថា ជិនោ (អ្នកចាញ់គេតែងសោកស្តាយទ្រព្យសម្បត្តិ) មានសេចក្តីថា អ្នកចាញ់រមែងសោកស្តាយចំពោះសំពត់ជូតក្បាល សំពត់សាដក ឬទ្រព្យសម្បត្តិ*

មានមាសនិងប្រាក់ជាដើម ដែលអ្នកដទៃបានឈ្នះយកទៅ បុគ្គលនោះរមែងសោយសោក ព្រោះទ្រព្យនោះជាហេតុថា ទ្រព្យនោះបានមកដល់ដៃអញហើយ ស្រាប់តែរបូតពីដៃអញ ទៅវិញ....... ដោយអាការយ៉ាងនេះ ទើបអ្នកចាញ់តែតែង សោកស្ដាយទ្រព្យសម្បត្តិ ។

បទថា សភាគតស្ស វចនំ ន រូហតិ (កាលបើទៅសាលាវិនិច្ឆ័យ គេមិនជឿស្ដាប់ពាក្យ) មានសេចក្ដីថា កាលធ្វើជាសាក្សីក្នុងសាលាវិនិច្ឆ័យ គេមិនជឿស្ដាប់ពាក្យឡើយ ។ ជនទាំងឡាយនាំគ្នានិយាយថា អ្នកនេះជាអ្នកលេងបាស្កា ជាអ្នកលេងល្បែងភ្នាល់ សូមអស់លោកកុំជឿពាក្យរបស់ គេឲ្យសោះ ។

បទថា មិត្តាមច្ចានំ បរិភូតោ ហោតិ (ពួកមិត្តអាមាត្យ តែងបោះបង់ចោល) មានសេចក្ដីថា ពួកមិត្តអាមាត្យទាំងនិយាយជាមួយនឹងបុគ្គលនោះយ៉ាងនេះថា ម្នាលសម្លាញ់ អ្នកឯងក៏ជាបុត្តរបស់អ្នកមានត្រកូលល្អ តែអ្នកបែរជាលេងល្បែងភ្នាល់ ជាអ្នកកាត់ទឹត ជាអ្នកទម្លាយទ្វារផ្ទះអ្នកដទៃយ៉ាងនេះ មិនសមគួរដល់ជាតិនិងត្រកូល

របស់អ្នកទេ តពេលនេះតទៅ អ្នកមិនគប្បីធ្វើយ៉ាងនេះទៀតឡើយ ។ អ្នកលេងល្បែងភ្នាល់នោះ សូម្បីត្រូវពួកមិត្តអាមាត្យដាស់តឿនយ៉ាងនេះ ក៏មិនព្រមស្តាប់ ម្ល៉ោះហើយពួកមិត្តអាមាត្យទាំងនោះរមែងមិនឈរ មិនអង្គុយរួមជាមួយបុគ្គលនោះទៀតឡើយ ដោយហេតុនេះឯង ទើបអ្នកលេងល្បែងភ្នាល់ ត្រូវបានពួកមិត្តអាមាត្យបោះបង់ ។

បទថា អាវាហវិវាហកានំ (អាវាហៈវិវាហៈ) មានសេចក្តីថា អ្នកមានបំណងចង់នាំកូនក្រមុំចេញទៅអំពីផ្ទះរបស់គេ ឈ្មោះថា អាវាហៈ, អ្នកមានបំណងចង់ឲ្យកូនក្រមុំនៅក្នុងផ្ទះរបស់គេ ឈ្មោះថា វិវាហៈ ។

បទថា អប្បត្ថិតោ ហោតិ ប្រែថា មិនមានអ្នកណាប្រាថ្នា ។

បទថា នាលំ ទារភរណាយ មានសេចក្តីថា អ្នកលេងល្បែងភ្នាល់ មិនអាចនឹងចិញ្ចឹមភរិយាបាន ។

# ទោសនៃការសេពគប់បាបមិត្ត ៦ យ៉ាង

## បិដក

ឆ ខោមេ គហបតិបុត្ត អាទីនវា បាបមិត្តានុយោគេ យេ ធុត្តា យេ សោណ្ឌា យេ បិបាសា យេ នេកតិកា យេ វញ្ចនិកា យេ សាហសិកា ត្យាស្ស មិត្តា ហោន្តិ តេ សហាយា ម្នាលគហបតិបុត្ត ទោសក្នុងការសេពគប់នូវបាបមិត្តនេះមាន ៦ យ៉ាង គឺពួកជនដែលជាអ្នកលេងល្បែងភ្នាល់ ១ ជនដែលជាអ្នកលេងស្រី ១ ជនដែលជាអ្នកលេងផឹកស្រា ១ ជនដែលជាអ្នកបោកប្រាសបញ្ឆោតអ្នកដទៃដោយរបស់ក្លែង ១ ជនដែលជាអ្នកបំបាត់ប្រវញ្ចន៍អ្នកដទៃក្នុងទីចំពោះមុខ ១ ជនដែលជាអ្នកឆក់ដណ្តើមទ្រព្យអ្នកដទៃ ១ ជនទាំងនោះជាមិត្តជាសម្លាញ់របស់ជននោះ ។

ឥមេ ខោ គហបតិបុត្ត ឆ អាទីនវា បាបមិត្តានុយោគេ ម្នាលគហបតិបុត្ត ទោសក្នុងការសេពគប់នូវបាបមិត្តមាន ៦ យ៉ាងនេះឯង ។

## អដ្ឋកថា

បទថា ធុត្តា ប្រែថា អ្នកលេងល្បែងភ្នាល់ ។

បទថា សោណ្ឌា (ជនដែលជាអ្នកលេងស្រី) មានសេចក្តីថា នាំឲ្យជាអ្នកលេងស្រី នាំឲ្យជាអ្នកលេងកត្ត នាំឲ្យជាអ្នកលេងផឹកស្រា នាំឲ្យជាអ្នកលេងមើមឈើ មានស៊ីមើមជំឡូងជាដើម ។

បទថា បិបាសា ប្រែថា អ្នកលេងផឹកស្រា ។

បទថា នេកតិកា គឺ ជនដែលជាអ្នកបោកប្រាស បញ្ឆោតអ្នកដទៃដោយរបស់ក្លែង ។

បទថា វញ្ចនិកា គឺ ជនដែលជាអ្នកបំបាត់ ប្រវញ្ចន៍ អ្នកដទៃក្នុងទីចំពោះមុខ ។

បទថា សាហសិកា ( ជនដែលជាអ្នកឆក់ដណ្តើម ទ្រព្យអ្នកដទៃ) មានសេចក្តីថា ជាអ្នកធ្វើការងាររួមជាមួយនឹងអ្នកដែលនៅក្នុងអាគារជាមួយគ្នាជាដើម ។

បទថា ត្យាស្ស មិត្តា ហោន្តិ (ជនទាំងនោះជាមិត្តជាសម្លាញ់របស់ជននោះ) គឺ គេមិនត្រេកអរនឹងជនដទៃ

ដែលជាមនុស្សល្អទេ ហើយរមែងចូលទៅរកមិត្តលាមក ទាំងឡាយនោះតែម្យ៉ាង ដូចជាសត្វជ្រូកដែលគេតាក់តែង ដោយគ្រឿងក្រអូប និងផ្កាឈើជាដើម ហើយឲ្យដេកលើ ទីដ៏ល្អ ក៏នៅតែចូលទៅកាន់រណ្តៅលាមកដូច្នោះ, ព្រោះហេតុ នោះ អ្នកសេពគប់បាបមិត្ត រមែងចូលដល់សេចក្តីសាប សូន្យដ៏ច្រើន ទាំងក្នុងលោកនេះ ទាំងក្នុងលោកខាងមុខ ។

## ទោសនៃសេចក្តីខ្ជិលច្រអូស ៦ យ៉ាង

### បិដក

ឆ ខោមេ គហបតិបុត្ត អាទីនវា អាលស្សានុយោគេ អតិសីតន្តិ កម្មំ ន ករោតិ អតិឧណ្ហន្តិ កម្មំ ន ករោតិ អតិសាយន្តិ កម្មំ ន ករោតិ អតិបាតោតិ កម្មំ ន ករោតិ អតិច្ឆាតោស្មីតិ កម្មំ ន ករោតិ អតិបិបាសិតោស្មីតិ កម្មំ ន ករោតិ តស្ស ឯវំ កិច្ចាបទេសពហុលស្ស វិហរតោ អនុប្បន្នា ចេវ ភោគា នុប្បជ្ជន្តិ ឧប្បន្នា ច ភោគា បរិក្ខយំ គច្ឆន្តិ ម្នាលគហបតិបុត្ត ទោសក្នុងការប្រកបរឿយ ៗ នូវសេចក្តីខ្ជិលនេះមាន ៦ យ៉ាង គឺមិនធ្វើការងារ ដោយ

អាងថា ត្រជាក់ណាស់ ១ មិនធ្វើការងារ ដោយអាងថា ក្តៅណាស់ ១ មិនធ្វើការងារ ដោយអាងថា ល្ងាចណាស់ ១ មិនធ្វើការងារ ដោយអាងថា ព្រឹកណាស់ ១ មិនធ្វើការងារ ដោយអាងថា ឃ្លានណាស់ ១ មិនធ្វើការងារ ដោយអាងថា ស្រេកណាស់ ១ កាលបើជនអ្នកខ្ជិលច្រអូសនោះ ច្រើនដោយការពោលអាងកិច្ចយ៉ាងនេះ ភោគៈទាំងឡាយដែលមិនទាន់កើត ក៏ខានកើតឡើងផង ភោគៈទាំងឡាយដែលកើតឡើងហើយ ក៏ដល់នូវសេចក្តីវេចវិលទៅវិញផង ។

ឥឡូវ នេះ គហបតិបុត្ត ៩ អាទីនវៈ អាលស្សានុយោគតិ ម្នាលគហបតិបុត្ត ទោសក្នុងការប្រកបរឿយ ៗ នូវសេចក្តីខ្ជិលមាន ៦ យ៉ាងនេះឯង ។

## អដ្ឋកថា

បទថា អតិសីតន្តិ កម្មំ ន ករោតិ (មិនធ្វើការងារដោយអាងថា ត្រជាក់ណាស់) ដោយសេចក្តីថា ពួកមនុស្សក្រោកឡើងអំពីព្រឹកព្រលឹមនិយាយថា ម្នាលអ្នកដ៏ចម្រើន

មកយើងទៅធ្វើការជាមួយនឹងគ្នា មនុស្សគេមិលតែងពោល ថា នៅត្រជាក់ពេក ធ្លងនឹងបែកមិនខាន ពួកអ្នកទៅមុនចុះ ខ្ញុំនឹងទៅតាមក្រោយ ហើយក៏អង្គុយអាំងភ្លើង ។ មនុស្សទាំង នោះ ក៏ទៅធ្វើការងារបានសម្រេច ឯការងាររបស់អ្នកខ្ជិល ច្រអូសរមែងវិនាស ។ សូមប្រែប្ដុំបទទាំងឡាយថា អតិឧណ្ហំ (ក្តៅណាស់) ជាដើម ក៏មានន័យដូចគ្នានេះដែរ ។

## និគមគាថា

## ចិដក

ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា ព្រះមានព្រះភាគ ទ្រង់បានសម្ដែងធម៌ នេះហើយ ព្រះសុគតជាសាស្ដា លុះសម្ដែងធម៌នេះហើយ ទ្រង់សម្ដែងគាថាតទ៏នេះ តទៅទៀតថា

ហោតិ បានសខា នាម
ហោតិ សម្មិយសម្មិយោ
យោ ច អត្ថេសុ ជាតេសុ
សហាយោ ហោតិ សោ សខា ។

បុគ្គលខ្លះ ជាមិត្តសម្លាញ់បានតែក្នុងកោនស្រុកក៏មាន បុគ្គលខ្លះជា សម្លាញ់ ៗ តែទៅចំពោះមុខក៏មាន បុគ្គលណា កាលបើប្រយោជន៍ (ខ្លួន) កើតឡើង ទើបធ្វើជាសម្លាញ់ បុគ្គលនោះមកជាសម្លាញ់នឹងខ្លួនក៏មាន ។

ឧស្សូរសេយ្យា បរទារសេវនា
វេរប្បសវោ ច អនត្ថតា ច
បាបា ច មិត្តា សុកទរិយតា ច
ឯតេ ឆ ឋានា បុរិសំ ធំសយន្តិ ។

កិរិយាដេកដល់ថ្ងៃ ១ ធ្វើសេវនកិច្ចនឹងប្រពន្ធអ្នកដទៃ ១ ការៈជាអ្នកមានពៀរច្រើន ១ ការៈជាអ្នកធ្វើអំពើឥតប្រយោជន៍ ១ បាបមិត្ត ១ ការៈជាអ្នកកំណាញ់ស្វិតស្វាញ ១ ហេតុទាំង ៦ នុ៎ះ រមែងបំផ្លាញបុរស (ឲ្យវិនាស) ។

បាបមិត្តោ បាបសខោ
បាបអាចារគោចរោ
អស្មា លោកា បរម្ហា ច
ឧភយា ធំសតេ នរោ ។

នរជនដែលមានមិត្តអាក្រក់ មានសម្លាញ់អាក្រក់ មានមារយាទនិងគោចរអាក្រក់ តែងវិនាសចាកលោកទាំងពីរ គឺ លោកនេះនិងលោកខាងមុខ ។

អក្ខិត្ថិយោ វារុណី នច្ចគីតំ
ទិវាសោប្បំ បារិចរិយា អកាលេ
បាបា ច មិត្តា សុកទរិយតា ច
ឯតេ ឆ ឋានា បុរិសំ ធំសយន្តិ ។

ល្បែងភ្នាល់ ល្បែងស្រី និងល្បែងសុរា ១ របាំនិងចម្រៀង ១ ការដេកថ្ងៃ ១ ការឲ្យគេបម្រើខ្លួនក្នុងកាលមិនគួរ ១ ពួកមិត្តអាក្រក់ ១ ការៈជាអ្នកមានសេចក្តីកំណាញ់ស្វិតស្វាញ ១ ហេតុទាំង ៦ នេះ តែងបំផ្លាញបុរសឲ្យវិនាស ។

អគ្គេហិ ទិត្តិ សុរំ បិវន្តិ
យន្តិត្ថិយោ ពាណសមា បរេសំ
និហីនសេវី ន ច វុឌ្ឍិសេវី
និហីយតិ កាឡបក្ខេវ ចន្ទិមា ។

ពួកជនដែលលេងល្បែងភ្នាល់ ផឹកសុរា ធ្វើសេវនកិច្ចនឹងស្រី ដែលស្មើដោយជីវិតរបស់បុរសដទៃ សេពគប់នឹងបុគ្គលថោកទាប (ខាតលក្ខណ៍) មិនសេពគប់នឹងបុគ្គលដែលមានសេចក្ដីចម្រើន (គ្រប់លក្ខណ៍) យសរបស់ពួកជននោះ តែងសាបសូន្យដូចព្រះចន្ទខាងរនោច ។

យោ វារុណិ អធនោ អកិញ្ចនោ
បិបាសោសិ អត្ថបាគតោ
ឧទកមិវ ឥណំ វិគាហតិ
អាកុលំ កាហតិ ខិប្បមត្តនោ ។

ជនដែលជាអ្នកផឹកសុរា ជាអ្នកខ្សត់ទ្រព្យ ជាអ្នកឥតមានកន្ទេល ដោយការផោរចិញ្ចឹម

ជីវិត មានតែស្រវឹងជានិច្ច ប្រាសចាក
សេចក្ដីចម្រើន លិចចុះក្នុងបំណុល ដូច
ដុំថ្មលិចចុះទៅក្នុងទឹក បុគ្គលនោះ តែង
ធ្វើការនៅរទ្បើកវរដល់ខ្លួនដោយឆាប់ ។

ន ទិវា សុប្បសីលេន
រត្តិនុដ្ឋានទេស្សិនា
និច្ចំ មត្តេន សោណ្ឌេន
សក្កា អាវសិតុំ ឃរំ ។

បុគ្គលដេកក្នុងវេលាថ្ងៃជាប្រក្រតី មិន
ក្រោកឡើងពីយប់ជាប្រក្រតី ជាអ្នកស្រវឹង
ជានិច្ច ជាអ្នកលេងល្បែង មិនអាចនឹង
គ្រប់គ្រងផ្ទះសម្បែងបាន ។

អតិសីតំ អតិឧណ្ហំ
អតិសាយមិទំ អហុ
ឥតិ វិស្សដ្ឋកម្មន្តេ
អត្ថា អច្ចេន្តិ មាណវេ ។

ប្រយោជន៍ទាំងឡាយ តែងកន្លងហួស មនុស្ស ដែលលះបង់ចោលនូវការងារ ដោយពោលអាងថា វេលានេះ ត្រជាក់ណាស់ ក្ដៅណាស់ ល្ងាចណាស់ ។

យោ ច សីតញ្ច ឧណ្ហញ្ច
តិណា ភិយ្យោ ន មញ្ញតិ
ករំ បុរិសកិច្ចានិ
សោ សុខា ន វិហាយតិ ។

ជនណាមួយ ធ្វើនូវកិច្ចការរបស់បុរស មិនអើពើនូវត្រជាក់និងក្ដៅ ក្រៃលែងជាងស្មៅ (ទៅទៀត) ជននោះ រមែងមិនសាបសូន្យចាកសេចក្ដីសុខឡើយ ។

## អដ្ឋកថា

បទថា ហោតិ បានសខា នាម (បុគ្គលខ្លះ ជាមិត្តសម្លាញ់តែក្នុងពេលសុកក៏មាន) មានសេចក្ដីថា មនុស្សខ្លះ ជាមិត្តសម្លាញ់នឹងគ្នាក្នុងពេលស្រាជាទីផឹកនោះឯង ។

បទថា សម្មិយសម្មិយោ (បុគ្គលខ្លះថា សម្លាញ់ ៗ តែនៅចំពោះមុខក៏មាន) មានសេចក្ដីថា បុគ្គលខ្លះ និយាយថា សម្លាញ់ ៗ តែនៅចំពោះមុខប៉ុណ្ណោះ តែក្នុងទីកំបាំងមុខក្លាយជាសត្រូវ រមែងស្វែងរកតែកំហុស ។

បទថា អត្ថេសុ ជាតេសុ (កាលបើប្រយោជន៍ខ្លួនកើតឡើង) មានសេចក្ដីថា កាលបើកិច្ចដែលខ្លួនឃើញថា នឹងបានសម្រេចកើតឡើងហើយ ។

បទថា ពហុបច្ចត្ថិកា ប្រែថា ការៈជាអ្នកមានពៀរច្រើន ។

បទថា អនត្ថតា ប្រែថា ការៈជាអ្នកធ្វើអំពើឥតប្រយោជន៍ ។

បទថា សុកទរិយតា ប្រែថា ការៈជាអ្នកកំណាញ់ស្វិតស្វាញ ។

បទថា ឧទកមិវ ឥណំ វិគាហតិ (លិចចុះក្នុងបំណុល ដូចដុំថ្មលិចចុះទៅក្នុងទឹក) មានសេចក្ដីថា បុគ្គលនោះរមែងលិចចុះក្នុងបំណុល ដូចដុំថ្មលិចចុះទៅក្នុងទឹកដូច្នោះឯង ។

បទថា វត្តិទុដ្ឋានទេស្សិនោ គឺ មិនក្រោកឡើងពីយប់ជាប្រក្រតី ។

បទថា អតិសាយមិទំ អហុ (វេលានេះល្ងាចណាស់) គឺបុគ្គលពោលយ៉ាងនេះថា វេលានេះល្ងាចណាស់ មិនធ្វើការងារទេ ។

បទថា ឥតិ វិស្សជ្ជកម្មន្តេ (លះបង់ចោលនូវការងារ) គឺ ពោលយ៉ាងនេះហើយ មិនធ្វើការងារ ។

បទថា អត្ថា អច្ចេន្តិ មាណវេ (ប្រយោជន៍រមែងកន្លងហួសមាណពទាំងឡាយ) មានសេចក្តីថា ប្រយោជន៍ទាំងឡាយ រមែងកន្លងហួសបុគ្គលដែលមានសភាពបែបនេះ គឺ មិនតាំងនៅក្នុងបុគ្គលទាំងឡាយនោះ ។

បទថា តិណា ភិយ្យោ ប្រែថា ក្រៃលែងជាងស្មៅ ។

បទថា សោ សុខា ន វិហាយតិ (ជននោះ រមែងមិនសាបសូន្យចាកសេចក្តីសុខឡើយ) មានសេចក្តីថា បុរសនោះ មិនខ្វះខាតសេចក្តីសុខឡើយ រមែងជាអ្នកសម្បូណ៌ដោយសេចក្តីសុខតែម្យ៉ាង ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់សំដែងនូវសេចក្ដីនេះ ដោយយកជាមគ្គនេះ ។ អ្នកគ្រប់គ្រងផ្ទះ មិនគួរធ្វើអំពើនេះ ឈ្មោះនៃសេចក្ដីចម្រើន រមែងមិនមានដល់បុគ្គលអ្នកធ្វើទេ ផ្ទុយទៅវិញតែងទទួលបាននូវការតិះដៀលតែម្យ៉ាង ទាំងក្នុងលោកនេះ ទាំងក្នុងលោកខាងមុខ ។

## លក្ខណៈរបស់អមិត្ត ៤ យ៉ាង
## បិដក

ចត្តារោមេ គហបតិបុត្ត អមិត្តា មិត្តប្បដិរូបកា វេទិតព្វា អញ្ញទត្ថុហរោ អមិត្តោ មិត្តប្បដិរូបកោ វេទិតព្វោ វចីបរមោ អមិត្តោ មិត្តប្បដិរូបកោ វេទិតព្វោ អនុប្បិយភាណី អមិត្តោ មិត្តប្បដិរូបកោ វេទិតព្វោ អបាយសហាយោ អមិត្តោ មិត្តប្បដិរូបកោ វេទិតព្វោ ម្នាលគហបតិបុត្ត អ្នកត្រូវស្គាល់ពួកមនុស្សដែលមិនមែនជាមិត្ត គ្រាន់តែជាមិត្តប្រៀប ៤ ពួកនេះ គឺអ្នកត្រូវស្គាល់មនុស្សដែលគិតយកតែប្រយោជន៍ខ្លួនថា មិនមែនជាមិត្ត គ្រាន់តែជាមិត្តប្រៀប ១ អ្នកត្រូវស្គាល់មនុស្សល្អតែសម្ដីថា មិនមែនជាមិត្ត គ្រាន់តែ

ជាមិត្តបួម ១ អ្នកត្រូវស្គាល់មនុស្សដែលនិយាយចាក់បណ្ដោយឲ្យគាប់ចិត្តជាមិនមែនជាមិត្ត គ្រាន់តែជាមិត្តបួម ១ អ្នកត្រូវស្គាល់មនុស្សជាសម្លាញ់ ក្នុងការវិនាសកោតៈទាំងឡាយថា មិនមែនជាមិត្ត គ្រាន់តែជាមិត្តបួម ១ ។

## អដ្ឋកថា

ឥឡូវនេះ ព្រះមានព្រះភាគ ដើម្បីសំដែងអំពីមនុស្សដែលមិនមែនជាមិត្ត គ្រាន់តែជាមិត្តបួម ជាបុគ្គលពាលថា បុគ្គលណាដូយ៉ាងនេះ សេចក្ដីវិនាសរមែងកើតមានដល់បុគ្គលនោះ ឬថាភ័យផ្សេងៗ អន្តរាយទាំងឡាយ និងឧបសគ្គណាទីមួយ រមែងកើតឡើងព្រោះតែអាស្រ័យបុគ្គលពាល ព្រោះហេតុដូច្នោះ មិនគួរសេពគប់បុគ្គលពាលដែលមានសភាពបែបនេះ ។ ដូច្នេះ ទើបទ្រង់ត្រាស់នូវព្រះតម្រាស់ជាដើមថា ម្នាលគហបតិបុត្ត មនុស្សដែលមិនមែនជាមិត្ត គ្រាន់តែជាមិត្តបួម មាន ៤ ពួកនេះ ដូច្នេះ ។

បទថា អញ្ញទត្ថុហរោ (និយាយរកប្រយោជន៍) មានសេចក្តីថា ខ្លួនឯងមកហើយដោយដៃទទេ នាំយករបស់ណាទីមួយទៅដោយចំណែកម្យ៉ាង ។

បទថា វចីបរមោ (ល្អតែសំដី) មានសេចក្តីថា ល្អបានត្រឹមតែសំដី ប៉ុន្តែគ្មានបានធ្វើអ្វីទាំងអស់ ។

បទថា អនុប្បិយភាណី (និយាយចាក់បណ្តោយឲ្យគាប់ចិត្ត) គឺនិយាយចាក់បណ្តោយតាម ។

បទថា អបាយសហាយោ (សម្លាញ់ក្នុងផ្លូវវិនាស) គឺសម្លាញ់ក្នុងផ្លូវវិនាសនៃភោគៈទាំងឡាយ ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់សម្តែងអំពីមនុស្សដែលមិនមែនជាមិត្ត ៤ ពួកយ៉ាងនេះហើយ គ្រាដែលទ្រង់បែងចែកនូវហេតុនីមួយ ៗ ក្នុងមនុស្សដែលមិនមែនជាមិត្តនោះដោយហេតុ ៤ យ៉ាង ទើបត្រាស់នូវពាក្យជាដើមថា ម្នាលគហបតិបុត្ត ស្ថាន ៤ យ៉ាង ដូច្នេះ ។

## លក្ខណៈមិត្តគិតតែប្រយោជន៍ខ្លួន ៤ យ៉ាង

### បិដក

ចតូហិ ខោ គហបតិបុត្ត ឋានេហិ អញ្ញទត្ថុហរោ អមិត្តោ មិត្តប្បដិរូបកោ វេទិតព្វោ អញ្ញទត្ថុហរោ ហោតិ អប្បេន ពហុមិច្ឆតិ ភយស្ស កិច្ចំ ករោតិ សេវតិ អត្ថការណា ម្នាលគហបតិបុត្ត មនុស្សគិតយកតែប្រយោជន៍ខ្លួន មិនមែនជាមិត្ត គ្រាន់តែជាមិត្តប្ចម (នោះ) អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាងគឺ មិត្តគិតយកតែប្រយោជន៍ខ្លួន ១ មិត្តប្រាថ្នាយករបស់ច្រើនដោយ (ឲ្យ) របស់តិចតួច ១ ទាល់តែមានភ័យទើបជួយធ្វើកិច្ចរបស់មិត្ត ១ សេពគប់មិត្តព្រោះហេតុតែប្រយោជន៍ ១ ។

ឥមេហិ ខោ គហបតិបុត្ត ចតូហិ ខោ ឋានេហិ អញ្ញទត្ថុហរោ អមិត្តោ មិត្តប្បដិរូបកោ វេទិតព្វោ ម្នាលគហបតិបុត្ត មិត្តគិតយកតែប្រយោជន៍ខ្លួន មិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្ចម អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាងនេះឯង ។

## អដ្ឋកថា

បទថា អញ្ញទត្ថុហរោ ហោតិ (មិត្តគិតយកតែប្រយោជន៍ខ្លួន) មានសេចក្ដីថា ជាអ្នកនាំយកទៅដោយចំណែកម្យ៉ាងប៉ុណ្ណោះ គឺជាអ្នកមានដៃទទេមកកាន់ផ្ទះរបស់មិត្ត ហើយនិយាយដល់គុណរបស់សំពត់សាដក ដែលខ្លួនស្លៀក ។ បុគ្គលអ្នកនិយាយក្រប្រយោជន៍ពោលថា ម្នាលសម្លាញ់ អ្នកឯណោះរមែងពោលអំពីគុណនៃផ្ទាំងសំពត់នេះនឹងអ្នកយ៉ាងក្រៃលែងដូច្នេះហើយ ខ្លួនឯងស្លៀកសំពត់ថ្មី រួចឲ្យសំពត់ដែលខ្លួនស្លៀកនោះទៅមិត្ត ។

បទថា អប្បេន ពហុមិច្ឆតិ (ចង់បានរបស់ច្រើនដោយឲ្យរបស់តិច) គឺ ឲ្យរបស់ឯណាទីមួយដែលមានប្រមាណតិចតួច ហើយប្រាថ្នារបស់ច្រើនអំពីគេវិញ ។

បទថា ភយស្ស កិច្ចំ ករោតិ (ទាល់តែមានភ័យទើបជួយធ្វើកិច្ច) មានសេចក្ដីថា កាលបើភ័យកើតឡើងដល់ខ្លួន រមែងធ្វើកិច្ចនោះ ៗ ប្រៀបដូចជាទាសៈរបស់គេ អ្នកនិយាយចាក់បណ្ដោយនេះ មិនធ្វើគុណកាលទាំងពួងទេ

ពេលដែលមានភ័យទើបធ្វើ មិនធ្វើដោយសេចក្ដីស្រឡាញ់ឡើយ ព្រោះហេតុដូច្នោះហើយ ទើបឈ្មោះថា ជាបុគ្គលមិនមែនមិត្ត ។

បទថា សេវតិ អត្ថការណា (សេពគប់មិត្តព្រោះហេតុតែប្រយោជន៍) មានសេចក្ដីថា មិនសេពគប់ដោយសេចក្ដីស្រឡាញ់ស្និទ្ធស្នាលទេ គឺទាល់តែសម្លឹងឃើញនូវប្រយោជន៍ដល់ខ្លួនទើបសេពគប់ ។

## លក្ខណៈមិត្តល្អតែសំដី ៤ យ៉ាង

### បិដក

ចតូហិ ខោ គហបតិបុត្ត ឋានេហិ វចីបរមោ អមិត្តោ មិត្តប្បដិរូបកោ វេទិតព្វោ អតីតេន បដិសន្ថរតិ អនាគតេន បដិសន្ថរតិ និរត្ថកេន សង្គណ្ហាតិ បច្ចុប្បន្នេសុ កិច្ចេសុ ព្យសនំ ទស្សេតិ ម្នាលគហបតិបុត្ត មិត្តល្អតែសម្ដីមិនមែនជាមិត្តទេ គ្រាន់តែជាមិត្តបម អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាងគឺ មិត្តទទួលរាក់ទាក់ដោយរបស់ដែលកន្លងហើយ ១ ទទួលរាក់ទាក់ដោយរបស់ដែលមិនទាន់មានមក

១ សង្គ្រោះដោយអំពើឥតប្រយោជន៍ ១ កាលកិច្ចទាំងឡាយ កើតឡើងក្រោយ ៗ ក៏សម្តែងអានរបស់ខូចខាត ១ ។

ឥមេហិខោ គហបតិបុត្ត ចតូហិ ឋានេហិ វចីបរមោ អមិត្តោ មិត្តប្បដិរូបកោ វេទិតព្វោ ម្នាលគហបតិបុត្ត មិត្តល្អតែសម្តី មិនមែនជាមិត្តទេ គ្រាន់តែជាមិត្តបួម អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាងនេះឯង ។

## អដ្ឋកថា

បទថា អតីតេន បដសន្ថរតិ (ទទួលរាក់ទាក់ដោយរបស់ដែលកន្លងហើយ) មានសេចក្តីថា មនុស្សល្អតែសម្តី កាលបើមិត្តមកដល់ រមែងសង្គ្រោះដោយរបស់ដែលកន្លងទៅហើយយ៉ាងនេះថា ថ្ងៃមុនអ្នកមិនមក ព្រោះថ្ងៃមុន ស្រូវសន្ទូងរបស់យើងបានសម្រេចផលដ៏ច្រើនលើសលប់ ពួកខ្ញុំបានសម្រាំងទុកស្រូវសាលី ស្រូវដំណើបនិងពញ្ញជាតិជាដើមដោយច្រើន ហើយអង្គុយមើលផ្លូវអ្នក តែថ្ងៃនេះអស់រលីងទៅហើយ ដូច្នេះ ។

បទថា អនាគតេន (ទទួលកក់ទាក់ដោយរបស់ដែលមិនទាន់មកដល់) មានសេចក្ដីថា មនុស្សល្អតែសំដីនោះ រមែងសង្គ្រោះដោយរបស់ដែលមិនទាន់មកដល់ យ៉ាងនេះថា ក្នុងថ្ងៃនេះ ស្រូវសន្ទូងរបស់ខ្ញុំលូតលាស់ល្អគួរឲ្យពេញចិត្ត ពេលច្រូតរួចហើយ បើបានផលពេញបរិបូណ៌ ខ្ញុំនឹងអាចសង្គ្រោះពួកអ្នកដោយស្រូវ មានស្រូវសាលីជាដើម ដូច្នេះ ។

បទថា និរត្ថកេន (សង្គ្រោះដោយអំពើឥតប្រយោជន៍) មានសេចក្ដីថា មនុស្សល្អតែសំដី អង្គុយលើដីរ ឬលើខ្នងសេះ ពេលបានឃើញមិត្តហើយ ពោលថាម្នាលសម្លាញ់! ចូរសម្លាញ់មកអង្គុយក្នុងទីនេះមក ៗ មនុស្សល្អតែសំដីនុះ ស្លៀកសំពត់សាដកមួយផ្ទាំងដ៏ល្អ ហើយពោលថា សំពត់សាដកនេះសមនឹងសម្លាញ់ឯងណាស់ ទាស់តែខ្ញុំមិនមានសំពត់ដទៃទៀត ៗ យ៉ាងនេះ ឈ្មោះថាសង្គ្រោះដោយអំពើឥតប្រយោជន៍ ។

បទថា បច្ចុប្បន្នេសុ កិច្ចេសុ ព្យសនំ ទស្សេតិ (កាលកិច្ចទាំងឡាយកើតឡើងភ្លាម ៗ ក៏សម្ដែងអាងរបស់ខូចខាត) មានសេចក្ដីថា កាលបើមានអ្នកពោលថា ខ្ញុំ

ត្រការរទេះ មនុស្សល្អតែសំដីពោលពាក្យជាដើមថា សោក
ស្តាយណាស់ កង់រទេះរបស់ខ្ញុំបាក់ទ្រុឌទ្រោមហើយ ។

## លក្ខណៈមិត្តនិយាយចាក់បណ្តោយ ៤ យ៉ាង
### បិដក

ចតូហិ ខោ គហបតិបុត្ត ឋានេហិ អនុប្បិយភាណី អមិត្តោ មិត្តប្បដិរូបកោ វេទិតព្វោ បាបកម្មំបិស្ស អនុជានាតិ កល្យាណំបិស្ស អនុជានាតិ សម្មុខស្ស វណ្ណំ ភាសតិ បរម្មុខស្ស អវណ្ណំភាសតិ ម្នាលគហបតិបុត្ត មិត្តនិយាយចាក់បណ្តោយឲ្យគាប់ចិត្ត មិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្លម អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាង គឺ បើមិត្តធ្វើអំពើអាក្រក់ ក៏យល់ព្រមតាម ១ មិត្តធ្វើអំពើល្អ ក៏យល់ព្រមតាម ១ ពណ៌នាគុណមិត្តតែក្នុងទីចំពោះមុខ ១ ពោលទោសមិត្តក្នុងទីកំបាំងមុខ ១ ។

ឥមេហិ ខោ គហបតិបុត្ត ចតូហិ ឋានេហិ អនុប្បិយភាណី អមិត្តោ មិត្តប្បដិរូបកោ វេទិតព្វោ ម្នាលគហបតិបុត្ត មិត្តនិយាយចាក់បណ្តោយឲ្យគាប់ចិត្ត មិនមែន

ជាមិត្តទេ គ្រាន់តែជាមិត្តប្ញម អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាងនេះឯង ។

## អដ្ឋកថា

បទថា បាបកម្មំបសាួ អនុជានាតិ (បើមិត្តធ្វើអំពើអាក្រក់ ក៏យល់ព្រមតាម) មានសេចក្តីថា កាលបើមិត្តនិយាយថា ពួកយើងនឹងធ្វើបាណាតិបាត (គឺសម្លាប់សត្វ) ជាដើម យ៉ាងណាមួយ ក៏និយាយចាក់បណ្តោយឲ្យគាប់ចិត្តថា ល្អហើយសម្លាញ់ ចូរធ្វើទៅ ។ សូម្បីក្នុងការធ្វើអំពើល្អ ក៏មានន័យដូចគ្នានេះដែរ ។

## លក្ខណៈមិត្តក្នុងផ្លូវវិនាស ៤ យ៉ាង

## បិដក

ចតូហិ ខោ គហបតិបុត្ត ឋានេហិ អបាយសហាយោ អមិត្តោ មិត្តប្បដិរូបកោ វេទិតព្វោ សុរាមេរយមជ្ជប្បមាទដ្ឋានានុយោគេ សហាយោ ហោតិ វិកាលវិសិខាចរិយានុយោគេ សហាយោ ហោតិ សមជ្ជាភិចរណេ សហាយោ

ហោតិ ជូតប្បមាទដ្ឋានានុយោគេ សហាយោ ហោតិ ម្នាល គហបតិបុត្ត មនុស្សជាសម្លាញ់ក្នុងផ្លូវវិនាស មិនមែនជា មិត្តទេ គ្រាន់តែជាមិត្តប្រួម អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាង គឺ ជាសម្លាញ់ក្នុងកិរិយាប្រកបរឿយ ៗ នូវការផឹកទឹក ស្រវឹងគឺសុរាមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ ១ ជា សម្លាញ់ក្នុងការប្រកបរឿយ ៗ នូវការត្រាច់ទៅតាមច្រក ល្ហកខុសកាល ១ ជាសម្លាញ់ក្នុងកិរិយាដើរមើលល្បែង មហោស្រព ១ ជាសម្លាញ់ក្នុងកិរិយាប្រកបរឿយ ៗ នូវ ល្បែងភ្នាល់ដែលជាហេតុជាទីតាំងនៃសេចក្តីប្រមាទ ១ ។

ឥមេហិ ខោ គហបតិបុត្ត ចតូហិ ឋានេហិ អបាយសហាយោ អមិត្តោ មិត្តប្បដិរូបកោ វេទិតព្វោ ម្នាលគហបតិបុត្ត មនុស្សជាសម្លាញ់ក្នុងផ្លូវវិនាស មិនមែន ជាមិត្តទេ គ្រាន់តែជាមិត្តប្រួម អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាងនេះឯង ។

## អដ្ឋកថា

បទថា សហាយោ ហោតិ (ជាសម្លាញ់) មាន សេចក្ដីថា កាលមិត្តពោលថា ជនទាំងឡាយនាំគ្នាផឹក សុរាក្នុងទីនោះ អ្នកចូរមក យើងនឹងទៅក្នុងទីនោះ មនុស្សជា សម្លាញ់ក្នុងផ្លូវវិនាសឆ្លើយតបថា ល្អហើយ ហើយក៏ទៅ ។ ក្នុងបទទាំងឡាយដទៃ ក៏មានន័យដូច្នេះដែរ ។

## និគមគាថា

## បិដក

ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា ព្រះមានព្រះភាគទ្រង់បានសម្ដែងសេចក្ដី នេះ លុះព្រះសុគតជាសាស្ដាសម្ដែងសេចក្ដីនេះហើយ ទើប ទ្រង់សម្ដែងនូវគាថាព័ន្ធតទៅទៀតថា :

អញ្ញទត្ថុហរោ មិត្តោ
យោ ច មិត្តោ វចីបរមោ
អនុប្បិយញ្ច យោ អាហុ

អបាយេសុ ច យោ សខា

ឯតេ អមិត្តេ ចត្តារោ

ឥតិ វិញ្ញាយ បណ្ឌិតោ

អារកា បរិវជ្ជេយ្យ

មគ្គំ បដិភយំ យថាតិ ។

បុគ្គលជាមិត្ត គិតយកតែប្រយោជន៍ខ្លួន ១ បុគ្គលជាមិត្តល្អតែសម្តី ១ បុគ្គលដែលនិយាយចាក់បណ្តោយឲ្យគាប់ចិត្ត ១ បុគ្គលដែលជាសម្លាញ់ក្នុងផ្លូវវិនាស ១ បណ្ឌិតដឹងថាបុគ្គលទាំង ៤ ពួកនុ៎ះមិនមែនជាមិត្តហើយ គប្បីចៀសវាងឲ្យឆ្ងាយ ដូចជាអ្នកដំណើរចៀសវាងផ្លូវដែលប្រកបដោយភ័យដូច្នោះ ។

## អដ្ឋកថា

បទថា ឥតិ វិញ្ញាយ (បណ្ឌិតដឹងច្បាស់យ៉ាងនេះហើយ) គឺដឹងយ៉ាងនេះថា ជាពួកមិត្តក្លែងក្លាយ ដូច្នេះ ។

## លក្ខណៈរបស់មិត្តមានសន្តានល្អ ៤ យ៉ាង

### បិដក

*ចត្តារោមេ គហបតិបុត្ត មិត្តា សុហទា វេទិតព្វា ឧបការកោ មិត្តោ សុហទោ វេទិតព្វោ សមានសុខទុក្ខោ មិត្តោ សុហទោ វេទិតព្វោ អត្ថក្ខាយី មិត្តោ សុហទោ វេទិតព្វោ អនុកម្បកោ មិត្តោ សុហទោ វេទិតព្វោ ម្នាល គហបតិបុត្ត មនុស្ស ៤ ពួកនេះ អ្នកត្រូវដឹងថាជាមិត្តមានសន្តានល្អ គឺមិត្តមានឧបការៈ អ្នកត្រូវដឹងថាជាមិត្តមានសន្តានល្អ ១ មិត្តរួមសុខទុក្ខ អ្នកត្រូវដឹងថាជាមិត្តមានសន្តានល្អ ១ មិត្តប្រាប់ប្រយោជន៍ អ្នកត្រូវដឹងថាជាមិត្តមានសន្តានល្អ ១ មិត្តមានសេចក្ដីឈឺឆ្អាល អ្នកត្រូវដឹងថាជាមិត្តមានសន្តានល្អ ១ ។*

### អដ្ឋកថា

*កាលព្រះមានព្រះភាគ ទ្រង់សម្ដែងអំពីមិត្តអាក្រក់ ដែលមិនគួរសេពគប់យ៉ាងនេះហើយ ឥឡូវនេះទើបត្រាស់*

សម្តែងអំពីមិត្តល្អដែលគួរសេពគប់ ដោយព្រះតម្រាស់ជាដើមថា ម្នាលគហបតិបុត្ត មនុស្ស ៤ ពួកនេះ អ្នកត្រូវដឹងថា ជាមិត្តមានសន្តានល្អតទៅទៀត ។

ក្នុងបទទាំងឡាយនោះ បទថា សុហទា ប្រែថា មិត្តមានសន្តានល្អ ។

## មិត្តមានឧបការៈ ៤ យ៉ាង

### បិដក

ចតូហិ ខោ គហបតិបុត្ត ឋានេហិ ឧបការកោ មិត្តោ សុហទោ វេទិតព្វោ បមត្តំ រក្ខតិ បមត្តស្ស សាបតេយ្យំ រក្ខតិ ភីតស្ស បដិសរណំ ហោតិ ឧប្បន្នេសុ កិច្ចេសុករណីយេសុ តទ្ទិគុណំ ភោគំ អនុប្បទេតិ ម្នាលគហបតិបុត្ត មិត្តមានឧបការៈ ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាងគឺ រក្សាមិត្តដែលធ្វេសប្រហែស ១ រក្សាសម្បត្តិរបស់មិត្ត ដែលធ្វេសប្រហែស ១ ជាទីពឹងពំនាក់នៃមិត្តដែលមានសេចក្តីភិតភ័យ ១ កាលបើកិច្ចដែលត្រូវធ្វើកើតឡើងហើយ តែងជួយផ្តល់ភោគៈជាទ្វិគុណជាងទ្រព្យដែលមិត្តត្រូវការនោះ ១ ។

ផមេហិ ខោ គហបតិបុត្ត ចតូហិ ឋានេហិ ឧបការកោ មិត្តោ សុហទោ វេទិតព្វោ ម្នាលគហបតិបុត្ត មិត្តមានឧបការៈ ជាមិត្តមានសន្ដានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាងនេះឯង ។

## អដ្ឋកថា

បទថា បមត្តំ រក្ខតិ (រក្សាមិត្តដែលធ្វេសប្រហែស) មានសេចក្ដីថា មិត្តមានឧបការៈ កាលបើឃើញមិត្តផឹកទឹកស្រវឹង ហើយដេកត្រង់កណ្ដាលផ្ទះ ត្រង់ទីជិតទ្វារ ឬដេកនៅតាមផ្លូវក៏គិតថា បើមិត្តរបស់អញដេកលក់យ៉ាងនេះ អាចជានឹងមានអ្នកណាម្នាក់មកលួចយកសំពត់សម្រាប់ស្លៀក និងសំពត់សម្រាប់ដណ្ដប់យកទៅបាន ដូច្នេះហើយក៏អង្គុយជិតមិត្តនោះ ពេលមិត្តក្រោកឡើង ក៏នាំយកទៅ ។

បទថា បមត្តស្ស សាបតេយ្យំ (រក្សាសម្បត្តិរបស់មិត្តដែលធ្វេសប្រហែស) មានសេចក្ដីថា មិត្តមានឧបការៈគិតថា សម្ភារៈរបស់អញបានចេញទៅខាងក្រៅ

ឬដីកទឹកស្រែវីង រីឯផ្ទះមិនមានអ្នកនៅចាំ អាចជានឹងមាន អ្នកដទៃចូលមក លួចរបស់ណាទីមួយយកទៅ ដូច្នេះ ក៏ចូលទៅកាន់ផ្ទះមិត្ត ហើយជួយថែទ្រព្យសម្បត្តិ ។

បទថា ភីតស្ស (ជាទីពឹងពំនាក់នៃមិត្ត ដែលមានសេចក្ដីភិតភ័យ) មានសេចក្ដីថា កាលបើភ័យណាមួយកើតឡើង មិត្តមានឧបការៈនិយាយថា កុំភ័យអី មានខ្ញុំនៅហើយ អ្នកខ្លាចអ្វី ហើយក៏កម្ចាត់បង់នូវភ័យនោះចេញ ទៅជាទីពឹងពំនាក់បាន ។

បទថា តទ្ទិគុណំ ភោគំ (កាលបើកិច្ចដែលត្រូវធ្វើកើតឡើងហើយ តែងជួយផ្ដល់ភោគៈជាទ្វិគុណជាងទ្រព្យដែលមិត្តត្រូវការនោះ) មានសេចក្ដីថា កាលបើកិច្ចដែលគួរធ្វើកើតឡើងហើយ មិត្តមានឧបការៈបានឃើញមិត្តមករកខ្លួនហើយសួរថា មានរឿងអ្វីបានជាអ្នកមក?

មិត្តរបស់ខ្លួនប្រាប់ថា មានការងារក្នុងរាជត្រកូល ។

មិត្តមានឧបការៈសួរថា តើអ្នកត្រូវការអ្វី?

មិត្តរបស់ខ្លួនប្រាប់ថា ខ្ញុំត្រូវការ ១ កហាបណៈ ។

មិត្តមានឧបការៈនិយាយថា ធម្មតាការងារក្នុងនគរនឹងមិនអាចសម្រេចដោយកហាបណៈ ១ ទេ អ្នកចូរយក ២ កហាបណៈចុះ រូបក៏បានឲ្យ ២ កហាបណៈដូចដែលបាននិយាយមែន ។

## មិត្តរួមសុខរួមទុក្ខ ៤ យ៉ាង
## បិដក

ចតូហិ ខោ គហបតិបុត្ត ឋានេហិ សមានសុខទុក្ខោ មិត្តោ សុហទោ វេទិតព្វោ គុយ្ហមស្ស អាចិក្ខតិ គុយ្ហមស្ស បរិគុយ្ហតិ អាបទាសុ ន វិជហតិ ជីវិតំបិស្ស អត្ថាយ បរិច្ចត្តំ ហោតិ ម្នាលគហបតិបុត្ត មិត្តរួមសុខរួមទុក្ខ ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាងគឺ ប្រាប់នូវអាថ៌កំបាំងរបស់ខ្លួនដល់មិត្ត ១ ជួយបិទបាំងនូវអាថ៌កំបាំងរបស់មិត្ត ១ មិនបោះបង់គ្នាក្នុងគ្រាមានវិបត្តិ ១ សូម្បីជីវិតក៏ហ៊ានលះបង់ដើម្បីប្រយោជន៍ដល់មិត្ត (ស៊ូប្តូរជីវិត) ១ ។

ឥមេហិ ខោ គហបតិបុត្ត ចតូហិ ឋានេហិ សមានសុខទុក្ខោ មិត្តោ សុហទោ វេទិតព្វោ ម្នាល

គហបតិបុត្ត មិត្តរួមសុខរួមទុក្ខ ជាមិត្តមានសន្ដានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាងនេះឯង ។

## អដ្ឋកថា

បទថា គុយ្ហមស្ស អាចិក្ខតិ (ប្រាប់នូវអាថ៌កំបាំងរបស់ខ្លួនដល់មិត្ត) មានសេចក្ដីថា មិនប្រាប់រឿងអាថ៌កំបាំងរបស់ខ្លួនដល់អ្នកដទៃ ប្រាប់ដល់មិត្តតែប៉ុណ្ណោះ ។

បទថា គុយ្ហមស្ស បរិគុយ្ហតិ (ជួយបិទបាំងនូវអាថ៌កំបាំងរបស់មិត្ត) មានសេចក្ដីថា មិត្តរួមសុខរួមទុក្ខ រមែងរក្សានូវអាថ៌កំបាំង ដែលមិត្តបាននិយាយប្រាប់មិនឲ្យមនុស្សដទៃដឹង ។

បទថា អាបទាសុ ន វិជហតិ (មិនបោះបង់គ្នាក្នុងគ្រាមានវិបត្តិ) មានសេចក្ដីថា កាលបើភ័យកើតឡើង មិត្តរួមសុខរួមទុក្ខ រមែងមិនបោះបង់គ្នាចោលឡើយ ។

បទថា ជីវិតំបិស្ស អត្ថាយ (សូម្បីជីវិតក៏ហ៊ានលះបង់ដើម្បីប្រយោជន៍មិត្ត) មានសេចក្ដីថា សូម្បីតែជីវិតក៏មិត្តរួមសុខរួមទុក្ខ ហ៊ានលះបង់ដើម្បីប្រយោជន៍ដល់មិត្ត

បានដែរ ។ មិត្តរួមសុខរួមទុក្ខនោះ ធ្វើការងាររបស់មិត្ត ឲ្យទាល់តែបានសម្រេច ដោយមិនគិតដល់ជីវិតរបស់ខ្លួនឡើយ។

## មិត្តប្រាប់ប្រយោជន៍ ៤ យ៉ាង

## បិដក

ចតូហិ ខោ គហបតិបុត្ត ឋានេហិ អត្ថក្ខាយី មិត្តោ សុហទោ វេទិតព្វោ បាបា និវារេតិ កល្យាណេ និវេសេតិ អស្សុតំ សាវេតិ សគ្គស្ស មគ្គំ អាចិក្ខតិ ម្នាលគហបតិបុត្ត មិត្តប្រាប់ប្រយោជន៍ ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាងគឺ ហាមមិត្តឲ្យឃ្លាតចាកអំពើអាក្រក់ ១ ដឹកនាំឲ្យមិត្ត តម្កល់នៅតែក្នុងអំពើល្អ ១ ឲ្យបានឮពាក្យដែលមិនធ្លាប់បានឮ ១ ប្រាប់ផ្លូវឋានសួគ៌ ១ ។

ឥមេហិ ខោ គហបតិបុត្ត ចតូហិ ឋានេហិ អត្ថក្ខាយី មិត្តោ សុហទោ វេទិតព្វោ ម្នាលគហបតិបុត្ត មិត្តប្រាប់ប្រយោជន៍ ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាងនេះឯង ។

## អដ្ឋកថា

បទថា បាបា និវារេតិ (ហាមមិត្តឲ្យឃ្លាតចាកអំពើអាក្រក់) មានសេចក្តីថា មិត្តប្រាប់ប្រយោជន៍ រមែងហាមថា កាលបើខ្ញុំឃើញហើយ អ្នកមិនគួរធ្វើយ៉ាងនេះទេ អ្នកចូរកុំធ្វើនូវវេរាទាំង ៥ និងអកុសលកម្មបថ ១០ ឡើយ ។

បទថា កល្យាណេ និវេសេតិ (ដឹកនាំមិត្តឲ្យតម្កល់នៅតែក្នុងអំពើល្អ) មានសេចក្តីថា មិត្តប្រាប់ប្រយោជន៍ រមែងឲ្យតាំងនៅក្នុងសេចក្តីល្អយ៉ាងនេះថា អ្នកចូរធ្វើនូវអំពើល្អ ចូរតាំងនៅក្នុងព្រះសរណគមន៍ ៣ ក្នុងសីល ៥ ក្នុងកុសលកម្មបថ ១០ ចូរឲ្យទាន ធ្វើបុណ្យ ស្តាប់នូវព្រះធម៌ដូច្នេះ ។

បទថា អស្សុតំ សាវេតិ (ឲ្យបានឮពាក្យដែលមិនធ្លាប់បានឮ) គឺឲ្យស្តាប់នូវពាក្យដែលមានន័យជ្រាលជ្រៅនាំឲ្យមានប្រាជ្ញា ដែលមិនធ្លាប់បានឮ ។

បទថា សគ្គស្ស មគ្គំ (ប្រាប់ផ្លូវឋានសួគ៌) មានសេចក្តីថា មិត្តប្រាប់ប្រយោជន៍ រមែងប្រាប់ផ្លូវឋានសួគ៌

យ៉ាងនេះថា ជនទាំងឡាយធ្វើកម្មនេះ រមែងកើតក្នុងឋានសួគ៌ ។

## មិត្តមានសេចក្តីឈឺឆ្អាល ៤ យ៉ាង
## បិដក

ចតូហិ ខោ គហបតិបុត្ត ឋានេហិ អនុកម្បកោ មិត្តោ សុហទោ វេទិតព្វោ អភវេនស្ស ន នន្ទតិ ភវេនស្ស នន្ទតិ អវណ្ណំ ភណមានំ និវារេតិ វណ្ណំ ភណមានំ បសំសតិ ម្នាលគហបតិបុត្ត មិត្តមានសេចក្តីឈឺឆ្អាល ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាងគឺ ជួយព្រួយចិត្តពីព្រោះមិត្តបានសេចក្តីវិនាស ១ ជួយត្រេកអរព្រោះមិត្តបានសេចក្តីចម្រើន ១ ទទឹងទាស់នឹងមនុស្សដែលពោលទោសមិត្ត ១ សរសើរតែមនុស្សដែលពណ៌នាគុណមិត្ត ១ ។

ឥមេហិ ខោ គហបតិបុត្ត ចតូហិ ឋានេហិ អនុកម្បកោ មិត្តោ សុហទោ វេទិតព្វោតិ ម្នាលគហបតិបុត្ត មិត្តមានសេចក្តីឈឺឆ្អាល ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាងនេះឯង ។

# អដ្ឋកថា

បទថា អកវេទស្ស ន ទទូតិ (ជួយព្រួយចិត្តចំពោះមិត្តមានសេចក្ដីវិនាស) មានសេចក្ដីថា មិត្តមានសេចក្ដីឈឺឆ្អាល កាលបានឃើញ ឬបានឮថា សេចក្ដីវិនាសនៃបុត្តករិយា ឬជនជាបរិវារ ព្រោះហេតុតែការបាត់បង់ គឺសេចក្ដីមិនចម្រើនរបស់មិត្តយ៉ាងនោះ រមែងមិនពេញចិត្ត គឺមិនសប្បាយចិត្តឡើយ ។

បទថា កវេទស្ស (ដោយបានសេចក្ដីចម្រើន) មានសេចក្ដីថា មិត្តមានសេចក្ដីឈឺឆ្អាល បានឃើញបានឮអំពីសេចក្ដីចម្រើននៃស្រូវសន្ទូងជាដើម ឬការបាននូវភាពជាធំ ព្រោះសេចក្ដីចម្រើនរបស់មិត្តមានសភាពបែបនោះ រមែងសប្បាយរីកាយ ។

បទថា អវណ្ណំ ភណមានំ និវារេតិ (ទទឹងទាស់នឹងមនុស្សដែលពោលទោសមិត្ត) មានសេចក្ដីថា កាលបើមានមនុស្សនិយាយថា អ្នកនុ៎ះមានរូបអាក្រក់មិនគួរជ្រះថ្លា មានជាតិថោកទាប ឬជាអ្នកទ្រុស្តសីល ដូច្នេះ ៗ មិត្តមាន

សេចក្ដីឈឺធ្ងាល រមែងហាមអ្នកដទៃដែលពោលតិះដៀល មិត្តរបស់ខ្លួនដោយពាក្យទាំងឡាយជាដើមថា សូមអ្នកកុំនិយាយយ៉ាងនេះ មិត្តរបស់ខ្ញុំមានរូបល្អគួរឲ្យជ្រះថ្លា មានជាតិល្អ និងដល់ព្រមដោយសីល ។

បទថា វណ្ណំ ភណមានំ បសំសតិ (សរសើរតែមនុស្សដែលពណ៌នាគុណមិត្ត) មានសេចក្ដីថា កាលបើមានអ្នកនិយាយថា មនុស្សឈ្មោះនោះមានរូបល្អគួរឲ្យជ្រះថ្លា មានជាតិល្អ ដល់ព្រមដោយសីល មិត្តមានសេចក្ដីឈឺធ្ងាល រមែងសរសើរមនុស្សដទៃ ដែលពោលសរសើរមិត្តរបស់ខ្លួនថា អ្នកនិយាយយ៉ាងនេះ ល្អហើយ ត្រឹមត្រូវហើយ អ្នកនោះ ពិតជាមានរូបល្អ គួរឲ្យជ្រះថ្លា មានជាតិល្អ និងដល់ព្រមដោយសីលមែន ។

## និគមគាថា

## មិត្តក

*ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា* ព្រះមានព្រះភាគទ្រង់បានសម្តែងសេចក្តីនេះ លុះព្រះសុគតជាសាស្តាត្រាស់សេចក្តីនេះហើយ ទើបទ្រង់សម្តែងនូវពាក្យជាគាថាព័ន្ធតទៅទៀតថា :

*ឧបការោ ច យោ មិត្តោ*
*សុខទុក្ខោ ច យោ សខា*
*អត្ថក្ខាយី ច យោ មិត្តោ*
*យោ ច មិត្តានុកម្បកោ ។*
*ឯតេបិ មិត្តេ ចត្តារោ*
*ឥតិ វិញ្ញាយ បណ្ឌិតោ*
*សក្កច្ចំ បយិរុបាសេយ្យ*
*មាតា បុត្តំវ ឱរសំ ។*

មិត្តដែលមានឧបការៈ សម្លាញ់ដែលរួមសុខរួមទុក្ខ មិត្តដែលប្រាប់ប្រយោជន៍ មិត្ត

ដែលមានសេចក្ដីឈ្លាស បណ្ឌិតស្គាល់ជាក់នូវបុគ្គលទាំង ៤ ពួកនុ៎ះថា ជាមិត្តមែនទែន ហើយគប្បីចូលទៅអង្គុយជិតស្និទ្ធស្នាល ដូចជាមាតានឹងបុត្តដែលកើតពីទ្រូង ។

បណ្ឌិតោ សីលសម្បន្នោ
ជលំ អគ្គីវ ភាសតិ
ភោគេ សំហរមានស្ស
ភមរស្សេវ ឥរីយតោ ។

អ្នកប្រាជ្ញបរិបូណ៌ដោយសីល តែងរុងរឿង ដូចជាភ្លើងដែលភ្លឺដូច្នោះឯង កាលបុគ្គលសន្សំទ្រព្យ រមែងធ្វើទ្រព្យឲ្យជាគំនរដូចជាឃ្មុំដូច្នោះឯង ។

ភោគា សន្និចយំ យន្តិ
វម្មិកោវុបចីយតិ
ឯវំ ភោគេ សមាហរិត្វា
អលមត្តោ កុលេ គិហី ។

ចតុធា វិភជេ ភោគេ
សវេ មិត្តានិ គន្ថតិ
ឯកេន ភោគេ ភុញ្ជេយ្យ
ទ្វីហិ កម្មំ បយោជយេ
ចតុត្ថញ្ច និធាបេយ្យ
អាបទាសុ ភវិស្សតីតិ ។

ភោគៈទាំងឡាយ តែងដល់នូវការពូនជាគំនរ ដូចជាដំបូកដែលកណ្ដៀរកពូនដូច្នោះឯង ។ គ្រហស្ថក្នុងត្រកូល បានសន្សំភោគៈទាំងឡាយយ៉ាងនេះហើយ ទើបអាច (តាំងខ្លួន) កុលបុត្រដែលចែកភោគៈ ទាំងឡាយជា ៤ ចំណែក គឺបរិភោគភោគៈទាំងឡាយ ១ ចំណែក ប្រកបការងារពីរចំណែក ទាំងតម្កល់ទុកនូវចំណែកទី ៤ ដោយក្រែងមានអន្តរាយទាំងឡាយ (ទៅខាងមុខ) កុលបុត្រនោះទើបឈ្មោះថា ចងបាច់មិត្តទាំងឡាយបាន ។

## អដ្ឋកថា

បទថា ជលំ អគ្គីវ ភាសតិ (បណ្ឌិតបរិបូណ៌ដោយសីល តែងរុងរឿងដូចជាភ្លើងដែលភ្លឺដូច្នោះដែរ) មានសេចក្ដីថា រមែងរុងរឿងដូចជាភ្លើងដែលភ្លឺនៅលើកំពូលភ្នំក្នុងវេលាយប់ ។

បទថា ភោគេ សំហរមានស្ស (កាលបុគ្គលសន្សំទ្រព្យ) មានសេចក្ដីថា កាលបុគ្គលមិនបៀតបៀនខ្លួនឯងខ្លះ អ្នកដទៃខ្លះ សន្សំភោគៈដោយធម៌ ដោយស្មើ គឺធ្វើឲ្យជាគំនរ ។

បទថា ភមរស្សេវ ឥរីយតោ (ដូចជាឃ្មុំធ្វើសម្បុក) មានសេចក្ដីថា ធ្វើភោគៈឲ្យជាគំនរធំដោយលំដាប់ ដូចជាឃ្មុំដែលមិនបំផ្លាញពណ៌និងក្លិនរបស់ផ្កាឈើ នាំយកកេសរដោយចុងចំពុះខ្លះ ដោយស្លាបទាំងពីរខ្លះ ហើយធ្វើសម្បុកតាំងពីគ្មានអ្វីសោះរហូតក្លាយជាផ្ទិតដ៏ធំ ដោយលំដាប់ ។

បទថា ភោគា សន្និចយំ យន្តិ (ភោគៈទាំងឡាយតែងដល់នូវការកេតូនជាគំនរ) មានសេចក្ដីថា ភោគៈ

ទាំងឡាយរបស់បុគ្គលនោះ រមែងដល់នូវការកពូនជាគំនរ យ៉ាងណា គឺ ដូចជាដំបូកដែលកណ្ដៀរកពូនឡើងដោយលំដាប់ ៗ ព្រោះហេតុនោះ ទើបលោកពោលថា ដូចជាដំបូកដែលកណ្ដៀរកពូនឡើង អធិប្បាយថា ភោគៈទាំងឡាយរមែងដល់នូវការកពូនជាគំនរ ដូចជាដំបូកដែលកណ្ដៀរកពូនឡើង ដូច្នោះ ។

បទថា សមាហរិត្វា ប្រែថា ប្រមូលរួបរួមហើយ ។

បទថា អលមត្តោ (អ្នកមានអាង) មានសេចក្ដីថា គ្រហស្ថអ្នកមានសភាពសមគួរ ឬជាអ្នកអាច ឬជាជាអ្នកប្រាជ្ញាដើម្បីគ្រប់គ្រងផ្ទះ ។ ឥឡូវនេះ កាលដែលព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រទាននូវឱវាទដល់អ្នកតាំងនៅក្នុងការគ្រប់គ្រងផ្ទះ ទើបត្រាស់នូវព្រះតម្រាស់ជាដើមថា ចតុធា វិភជេ ភោគេ (អ្នកគ្រប់គ្រងផ្ទះគប្បីបែងចែកភោគៈជា ៤ ចំណែក ដូច្នេះ ។

ក្នុងបទទាំងឡាយនោះ បទថា សវេ មិត្តានិ គន្ថតិ (បុគ្គលនោះឯងរមែងចងមិត្តបាន) មានសេចក្ដីថា បុគ្គលជាអ្នកគ្រប់គ្រងផ្ទះនោះ កាលបែងចែកភោគៈយ៉ាងនេះ

ឈ្មោះថា រមែងចងមិត្តទុកបាន គឺចងតែនូវមិត្តភាពមិនឲ្យ
កេចេញពីគ្នា ។ បុគ្គលអ្នកមានភោគៈរមែងអាចរក្សា
វមិត្តបាន ពួកជនដទៃមិនអាចរក្សាបានឡើយ ។

បទថា ឯកេន ភោគេ ភុញ្ជេយ្យ ប្រែថា គប្បី
រិភោគភោគៈទាំងឡាយ ១ ចំណែក ។

បទថា ទ្វីហិ កម្មំ បយោជយេ (ប្រកបការងារ ២
ណែក) មានសេចក្តីថា គប្បីប្រកបការងារទាំងឡាយ
ានកសិកម្ម និងពាណិជ្ជកម្មជាដើម ដោយទ្រព្យ ២
ណែក ។

បទថា ចតុត្ថញ្ច និធាបេយ្យ (តម្កល់ទុក) គឺគប្បី
ម្កល់ទុកនូវទ្រព្យចំណែកទី ៤ ។

បទថា អាបទាសុ ភវិស្សតិ (ក្រែងមានអន្តរាយ
ំងឡាយ) មានសេចក្តីថា ព្រោះការងារនោះ មិនមែន
ះតែសម្រេចបានដោយល្អហេតុទេ ជួនកាលអន្តរាយក៏
ើតឡើងដោយអំណាចរាជភ័យជាដើម ។ ដូច្នេះ ភោគៈ
ប្រមាន ក្នុងកាលអន្តរាយទាំងឡាយកើតឡើងយ៉ាងនេះ

ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា បុគ្គលអ្នកគ្រប់គ្រងផ្ទះគប្បីតម្កល់ទុកនូវទ្រព្យ ១ ចំណែក ដូច្នេះ ។

ក្នុងចំណែកទាំងឡាយ ៤ នេះ គប្បីតម្កល់ទុកនូវចំណែកណាមួយសម្រាប់បំពេញកុសលផង គឺក្នុងចំណែកដែលលោកពោលក្នុងបទថា ភោគេ កុញ្ជេយ្យ. គួរកាន់យកអំពីចំណែកនោះ បរិច្ចាគទានដល់ភិក្ខុទាំងឡាយខ្លះ ដល់មនុស្សកំព្រា និងអ្នកដើរផ្លូវជាដើមខ្លះ គួរឲ្យស្នងដល់ជាងតម្បាញ និងជាងកាត់សក់ជាដើមខ្លះ ។

ដោយយកជាមគ្គត្រឹមប៉ុណ្ណេះ ដែលព្រះមានព្រះភាគទ្រង់ប្រទាននូវឱវាទដើម្បីឲ្យវៀរចាកធម៌ដែលគួរវៀរ និងដើម្បីសេពនូវធម៌ដែលគួរសេពថា ម្នាលគហបតិបុត្ត អរិយសាវ័កលះបង់នូវអកុសលដោយហេតុទាំងឡាយ ៤ វៀរចាកនូវផ្លូវនៃសេចក្ដីវិនាសភោគៈ ដោយហេតុទាំងឡាយ ៦ សេពគប់មិត្ត ១៦ ពួកស្ថិតនៅក្នុងការគ្រប់គ្រងផ្ទះ ធ្វើការចិញ្ចឹមកិរិយា - រមែងចិញ្ចឹមជីវិតប្រកបដោយធម៌ នឹងរមែងរុងរឿងដូចជាគំនរភ្លើង ក្នុងវាងទេវតានិងមនុស្សទាំងឡាយឥឡូវនេះ ដើម្បីនឹងសម្ដែងអំពីទិស ៦ ដែលគួរគោរព ទើប

ត្រាស់នូវព្រះតម្រាស់ជាដើមថា ម្នាលគហបតិបុត្ត អរិយសាវកបិទបាំងទិសទាំង ៦ ដូចម្ដេច ។

## ទិស ៦

### បិដក

កថញ្ច គហបតិបុត្ត អរិយសាវកោ ឆទិសាបដិច្ឆាទី ហោតិ ម្នាលគហបតិបុត្ត អរិយសាវកបិទបាំងទិសទាំង ៦ ដូចម្ដេច ។

៨ ឥមា គហបតិបុត្ត ទិសា វេទិតព្វា បុរត្ថិមា ទិសា មាតាបិតរោ វេទិតព្វា ទក្ខិណា ទិសា អាចរិយា វេទិតព្វា បច្ឆិមា ទិសា បុត្តទារា វេទិតព្វា ឧត្តរា ទិសា មិត្តាមច្ចា វេទិតព្វា ហេដ្ឋា ទិសា ទាសកម្មករា វេទិតព្វា ឧបរិមា ទិសា សមណព្រាហ្មណា វេទិតព្វា ម្នាលគហបតិបុត្ត អ្នកត្រូវដឹងទិសទាំង ៦ ដូច្នេះគឺ មាតាបិតា អ្នកត្រូវដឹងថា ទិសខាងកើត ១ អាចារ្យ អ្នកត្រូវដឹងថា ទិសខាងត្បូង ១ កូននិងប្រពន្ធ អ្នកត្រូវដឹងថា ទិសខាងលិច ១ មិត្តអាមាត្យ អ្នកត្រូវដឹងថា ទិសខាងជើង ១ ទាសៈនិងកម្មករ

អ្នកត្រូវដឹងថា ទិសខាងក្រោម ១ សមណព្រាហ្មណ៍អ្នកត្រូវដឹងថា ទិសខាងលើ ១ ។

## អដ្ឋកថា

ក្នុងបទទាំងឡាយនោះ បទថា ឆទិសាបដិច្ឆាទី (អរិយសាវកបិទបាំងទិសទាំង ៦) មានសេចក្តីថា ព្រះមានព្រះភាគទ្រង់ស្ថិតនៅក្នុងទីដែលមិនមានភ័យអំពីទិសទាំង ៦ ជាដែនក្សេមចាកភ័យ ទើបត្រាស់ថា អរិយសាវកជាអ្នកបិទបាំងទិសទាំង ៦ ដូច្នេះ ។

ក្នុងបទទាំងឡាយ មានបទជាដើមថា បុរត្ថិមា ទិសា មាតាបិតរោ វេទិតព្វា (មាតាបិតា អ្នកត្រូវដឹងថា ជាទិសខាងកើត) គឺគប្បីជ្រាបថា មាតាបិតាជាទិសខាងកើត ព្រោះជាអ្នកមានឧបការៈមុន ។ គ្រូអាចារ្យ ជាទិសខាងត្បូង ព្រោះជាអ្នកគួរដល់ទក្ខិណា ។ កូនទិងប្រពន្ធ ជាទិសខាងលិច ដោយអំណាចជាប់តាមមកពីខាងក្រោយ ។ មិត្ត-អាមាត្យ ជាទិសខាងជើង ព្រោះកុលបុត្តនោះ អាស្រ័យនឹងមិត្តអាមាត្យ ទើបឆ្លងផុតទុក្ខពិសេសនោះ ៗ បាន ។ ទាសៈ

ទិសកម្មករ ជាទិសខាងក្រោម ដោយអំណាចការតាំងនៅទៀបជើង ៗ សមណព្រាហ្មណ៍ ជាទិសខាងលើ ព្រោះភាវៈជាអ្នកតាំងនៅខាងលើដោយគុណធម៌ទាំងឡាយ ៗ

## មាតាបិតាជាទិសខាងកើត

### បិដក

បញ្ចហិ ខោ គហបតិបុត្ត ឋានេហិ បុត្តេន បុរត្ថិមា ទិសា មាតាបិតរោ បច្ចុបដ្ឋាតព្វា ភតោ នេសំ ភរិស្សាមិ កិច្ចំ នេសំ ករិស្សាមិ កុលវំសំ ឋបេស្សាមិ ទាយជ្ជំ បដិបជ្ជាមិ អថវា បន បេតានំ កាលកតានំ ទក្ខិណំ អនុប្បទស្សាមីតិ ម្នាលគហបតិបុត្ត មាតាបិតាជាទិសខាងកើត កូនត្រូវទំនុកបម្រុងដោយស្ថានទាំងឡាយ ៥ យ៉ាងគឺ កូនត្រូវតាំងចិត្តថា អាត្មាអញ មាតាបិតាបានចិញ្ចឹមរក្សាមកហើយ នឹងចិញ្ចឹមមាតាបិតាវិញ ១ នឹងជួយធ្វើការងាររបស់មាតាបិតា ១ ទាំងតម្កល់វង្សត្រកូល ១ ប្រតិបត្តិឲ្យជាអ្នកសមគួរទទួលទ្រព្យមត៌កបាន ១ មួយទៀតឧទ្ទិសទក្ខិណាទានដល់ មាតាបិតាដែលធ្វើកាលកិរិយាទៅកាន់បរលោកហើយ ១ ៗ

## អដ្ឋកថា

បទថា កតោ នេសំ ករិស្សាមិ (អាត្មាអញ មាតាបិតាបានចិញ្ចឹមរក្សាមកហើយ នឹងចិញ្ចឹមមាតាបិតាវិញ) មានសេចក្ដីថា អាត្មាអញដែលមាតាបិតា បំបៅដោះ ញ៉ាំងដៃនិងជើងឲ្យចម្រើន ជូតទឹកសំបោរឲ្យ ក្តួតទឹកឲ្យ ស្លៀកពាក់ឲ្យ ប្រដាប់តាក់តែងខ្លួនឲ្យ និងចិញ្ចឹមថ្នាក់ថ្នម .... អាត្មាអញនឹងចិញ្ចឹមមាតាបិតាទាំងនោះ ដែលចាស់ជរា ដោយការលាងជើង ក្តួតទឹក ជូនបបរនិងបាយ ជាដើម ។

បទថា កិច្ចំ នេសំ ករិស្សាមិ (នឹងជួយធ្វើការងារ របស់មាតាបិតា) មានសេចក្ដីថា អាត្មាអញនឹងលះបង់ការងាររបស់ខ្លួនដែលត្រូវធ្វើ ដូចជាការងារក្នុងរាជដំណាក់ ជាដើម ដើម្បីជួយដល់ការងាររមាតាបិតា ។

បទថា កុលវំសំ ឋបេស្សាមិ (ទាំងតម្កល់វង្សត្រកូល) មានសេចក្ដីថា បុត្តមិនត្រូវធ្វើឲ្យមត៌ករបស់មាតាបិតា មានមាសប្រាក់និងដីស្រែជាដើមវិនាសបាត់បង់ទៅទេ ។ សូម្បីការថែរក្សាទុក ក៏ឈ្មោះថា តម្កល់វង្សត្រកូលដែរ ។

មួយ៉ាងទៀត បុត្តអ្នកធ្វើឲ្យមាតាបិតា ដែលវិនាស ចាកវង្សត្រកូលដែលមិនប្រកបដោយធម៌ ឲ្យមាតាបិតាតាំងនៅក្នុងវង្សត្រកូលប្រកបដោយធម៌វិញ មិនចូលទៅកាត់ផ្តាច់នូវសេលាកកត្តជាដើម ដែលមកដល់ហើយ ដោយវង្សត្រកូលឲ្យប្រព្រឹត្តទៅ ក៏ឈ្មោះថា តម្កល់វង្សត្រកូល ។ លោកសំដៅយកសេចក្តីនេះ ទើបពោលថា អញនឹងតម្កល់វង្សត្រកូល ដូច្នេះ ។

បទថា ទាយជ្ជំ បដិបជ្ជាមិ (ប្រតិបត្តិឲ្យជាអ្នកសមគួរទទួលទ្រព្យមត៌កបាន) មានសេចក្តីថា មាតាបិតាទៅកាន់តុលាការ ធ្វើកូនដែលជាអ្នកមិនប្រតិបត្តិនៅក្នុងឱវាទរបស់ខ្លួន អ្នកដែលប្រតិបត្តិខុស មិនឲ្យមានឈ្មោះថាជាកូន កូនទាំងនោះ ក៏មិនសមគួរជាអ្នកទទួលមត៌កឡើយ ។ ប៉ុន្តែមាតាបិតា រមែងញ៉ាំងកូនដែលប្រតិបត្តិនៅក្នុងឱវាទ ឲ្យជាម្ចាស់ទ្រព្យ ដែលមាននៅក្នុងត្រកូល ។ លោកពោលថា អញនឹងប្រតិបត្តិ ឲ្យជាអ្នកសមគួរទទួលទ្រព្យមត៌កបាន ដោយបំណងថា អញនឹងប្រតិបត្តិយ៉ាងដូច្នេះ ។

បទថា ទក្ខិណំ អនុប្បទស្សាមិ (ឧទ្ទិសទក្ខិណាទានដល់មាតាបិតា ដែលធ្វើកាលកិរិយាទៅកាន់បរលោកហើយ) មានសេចក្តីថា អញនឹងធ្វើទានផ្សាយចំណែកបុណ្យឲ្យដល់លោកទាំងនោះ រួចផ្តើមឧទ្ទិសទានដល់មាតាបិតា ចាប់តាំងពីថ្ងៃទីបីទៅ ។

(មាតាបិតាសង្គ្រោះកូនដោយស្ថាន ៥ យ៉ាង)

## បិដក

ឥមេហិ ខោ គហបតិបុត្ត បញ្ចហិ ឋានេហិ បុត្តេន បុរត្ថិមា ទិសា មាតាបិតរោ បច្ចុបដ្ឋិតា បញ្ចហិ ខោ ឋានេហិ បុត្តំ អនុកម្បន្តិ បាបា និវារេន្តិ កល្យាណេ និវេសេន្តិ សិប្បំ សិក្ខាបេន្តិ បដិរូបេន ទារេន សញ្ញោជេន្តិ សមយេ ទាយជ្ជំ និយ្យាទេន្តិ ម្នាលគហបតិបុត្ត មាតាបិតាជាទិសខាងកើត ដែលកូនទំនុកបម្រុង ដោយស្ថានទាំងឡាយ ៥ យ៉ាងនេះ ឯងហើយ រមែងអនុគ្រោះកូន ដោយស្ថានទាំងឡាយ ៥ យ៉ាងវិញដូច្នេះគឺ ហាមឃាត់កូនចាកអំពើអាក្រក់ ១ ឲ្យកូនតម្កល់នៅក្នុងអំពើល្អ ១ ឲ្យកូនរៀនសូត្រសិល្បសាស្ត្រ

ដណ្តឹងភរិយាស្វាមីសមគួរឲ្យ ១ ចែកទ្រព្យឲ្យកូនក្នុងសម័យគួរ ១ ។

ឥមេហិ ខោ គហបតិបុត្ត បញ្ចហិ ឋានេហិ បុត្តេន បុរត្ថិមា ទិសា មាតាបិតរោ បច្ចុបដ្ឋិតា ឥមេហិ បញ្ចហិ ឋានេហិ បុត្តំ អនុកម្បន្តិ ឯវមស្ស ឯសា បុរត្ថិមា ទិសា បដិច្ឆន្នា ហោតិ ខេមា អប្បដិភយា ម្នាលគហបតិបុត្ត មាតាបិតាជាទិសខាងកើត ដែលកូនទំនុកបម្រុងដោយស្ថាន ៥ យ៉ាងនេះឯងហើយ រមែងអនុគ្រោះកូនដោយស្ថាន ៥ យ៉ាងនេះ ទិសខាងកើតនោះ ដែលកូនបានបិទបាំងហើយ ជាទិសមានសេចក្តីក្សេម ឥតមានភយន្តរាយយ៉ាងនេះ ។

## អដ្ឋកថា

បទថា បាបា និវារេន្តិ (ហាមឃាត់កូនចាកអំពើអាក្រក់) មានសេចក្តីថា មាតាបិតាពោលអំពីទោសដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងភពខាងមុខរបស់បាណាតិបាតជាដើម ហើយហាមថា នែកូន! ចូរអ្នកកុំធ្វើនូវអំពើបែបនេះ

បែបនេះឡើយ ដូច្នេះគិះដៀលកូនដែលបានធ្វើហើយ ។

បទថា កល្យាណេ និវេសេន្តិ (ឲ្យតម្កល់នៅតែក្នុងអំពើល្អ) មានសេចក្តីថា មាតាបិតា សូម្បីត្រូវឲ្យទ្រព្យសម្បត្តិ ដូចលោកអនាថបិណ្ឌិកសេដ្ឋី ដើម្បីឲ្យកូនតាំងនៅក្នុងការសមាទានសីលជាដើម ។

បទថា សិប្បំ សិក្ខាបេន្តិ (ឲ្យរៀនសិល្បសាស្រ្ត) មានសេចក្តីថា មាតាបិតាបានដឹងថា បុត្តតាំងនៅក្នុងឱវាទរបស់ខ្លួនហើយ ញ៉ាំងកូនឲ្យសិក្សាសិល្បសាស្រ្ត មានការសិក្សាគណិតសាស្រ្តឲ្យដល់ថ្នាក់ខ្ពស់ជាដើម តាមវង្សត្រកូល ។

បទថា បដិរូបេន (ដណ្តឹងករិយា ស្វាមីសមគួរឲ្យ) គឺសមគួរដោយត្រកូល សីល និងរូបជាដើម ។

បទថា សមយេ ទាយជ្ជំ និយ្យាទេន្តិ (ចែកទ្រព្យឲ្យកូនក្នុងសម័យគួរ) មានសេចក្តីថា ចែកទ្រព្យឲ្យកូនក្នុងសម័យដែលសមគួរ ។ ក្នុងបទនោះ សម័យមាន ២ យ៉ាងគឺ និច្ចសម័យ ១ កាលសម័យ ១ ។

មាតាបិតាឲ្យដោយពាក្យថា ចូរកូនប្រញាប់ប្រញាល់កាន់យកនូវរបស់ដែលគួរកាន់យក ចូរកោយនូវការចំណាយរបស់អ្នក ចូរធ្វើនូវកុសល ដោយការចំណាយនេះ ដូច្នេះឈ្មោះថា ឲ្យក្នុងនិច្ចសម័យ គឺឲ្យជានិច្ច ។

មាតាបិតា រមែងឲ្យក្នុងសម័យកាត់ក្នុងសក់រៀបមង្គលការជាដើម ឈ្មោះថា ឲ្យក្នុងកាលសម័យ ។

ម្យ៉ាងទៀត មាតាបិតាកាលឲ្យដល់បុត្តដែលឈឺដេកលើគ្រែទៀបនឹងស្លាប់ដោយពាក្យថា ចូរកូនធ្វើកុសលដោយទ្រព្យនេះ ក៏ឈ្មោះថា ឲ្យក្នុងកាលសម័យដែរ ។

បទថា បដិច្ឆន្នា ហោតិ (ទិសខាងកើតនោះ ដែលកូនបានបិទបាំងហើយ) មានសេចក្ដីថា ទិសខាងកើតដែលកូនបិទបាំងហើយ ភ័យដែលកើតអំពីទិសខាងកើត រមែងមិនកើតឡើងឡើយ ។ ប្រសិនបើកូនទាំងឡាយជាអ្នកប្រតិបត្តិខុស ឯមាតាបិតាជាអ្នកប្រតិបត្តិល្អដោយការចិញ្ចឹមថែរក្សាជាដើម តាំងតែពីកូននៅតូច កូននោះជាអ្នកមិនសមគួរចំពោះមាតាបិតា ព្រោះហេតុនោះ ភ័យនោះរមែងមានមិនខាន ។ កូនទាំងឡាយ ជាអ្នកប្រតិបត្តិល្អ មាតាបិតា

ជាអ្នកប្រតិបត្តិខុស មាតាបិតា ក៏មិនសមគួរដល់បុត្តទាំងឡាយ ដូច្នោះ ភ័យនេះគប្បីមកដល់ ។ កាលបើទាំងសងខាងប្រតិបត្តិខុស ភ័យក៏រមែងមានទាំងសងខាង កាលបើប្រតិបត្តិត្រូវទាំងសងខាង ភ័យរមែងមិនមានទាំងអស់ ។ ដោយហេតុនោះទើបលោកពោលថា ទិសខាងកើត ដែលកូនបទបុំងឲ្យក្សេមក្សាន្តហើយ រមែងមិនឲ្យមានភ័យ ដូច្នេះ ។ កាលព្រះមានព្រះភាគបានសម្តែងយ៉ាងនេះហើយ ទ្រង់ត្រាស់នឹងសិង្គាលក:ថា ម្នាលគហបតិបុត្ត បិតារបស់អ្នកមិនបានឲ្យអ្នកថ្វាយបង្គំទិសខាងកើត ដែលជនក្នុងលោកសន្មតិគ្នាទេ ប៉ុន្តែបិតារបស់អ្នកបានសំដៅយក មាតាបិតាជាទិសខាងកើត ហើយឲ្យអ្នកថ្វាយបង្គំ បិតារបស់អ្នកពោលអំពីទិសខាងកើត គឺយ៉ាងនេះឯង មិនមែនយ៉ាងដទៃឡើយ ។

## គ្រូអាចារ្យជាទិសខាងត្បូង

## បាលី

បញ្ចហិ ខោ គហបតិបុត្ត ឋានេហិ អន្តេវាសិនា ទក្ខិណា ទិសា អាចរិយា បច្ចុបដ្ឋាតព្វា ឧដ្ឋានេន ឧបដ្ឋានេន

សុស្រូសាយ បារិចរិយាយ សក្កច្ចំ សិប្បំ បដិគ្គហណេន ម្នាលគហបតិបុត្ត អាចារ្យជាទិសខាងត្បូង សិស្សត្រូវប្រតិបត្តិដោយស្ថាន ៥ យ៉ាងគឺ ដោយការក្រោកឡើងទទួល ១ ដោយការគាល់បម្រើ ១ ដោយការជឿស្តាប់ឱវាទ ១ ដោយការបម្រើតូច ៗ (មានឲ្យទឹកលុបមុខនិងឈើស្ទន់ជាដើម) ១ ដោយការរៀនសិល្បសាស្ត្រដោយគោរព ១ ។

## អដ្ឋកថា

បទថា ឧដ្ឋានេន (ដោយការក្រោកឡើងទទួល) គឺ ដោយក្រោកឡើងចាកទីអង្គុយ ។ ពិតណាស់ សិស្ស កាលឃើញគ្រូអាចារ្យមកអំពីចម្ងាយ ត្រូវក្រោកចាកទីអង្គុយធ្វើការស្វាគមន៍ ទទួលរបស់អំពីដៃ ក្រាលនូវអាសនៈឲ្យគ្រូអាចារ្យអង្គុយហើយ គប្បីធ្វើការបក់ផ្លិត លាងជើង គក់ប្រេងបាច់ជាដើមនោះ លោកពោលសំដៅយកបទថា ដោយការក្រោកឡើងទទួល ដូច្នេះ ។

បទថា ឧបដ្ឋានេន (ដោយការគាល់បម្រើ) មានសេចក្ដីថា ដោយការចូលទៅគាល់បម្រើ ៣ ដងក្នុងមួយថ្ងៃ តែជានិច្ចកាល ក៏គួរទៅក្នុងកាលរៀនសិល្បសាស្ត្រ ។

បទថា សុស្សូសាយ (ដោយការជឿស្ដាប់ឱវាទ) មានសេចក្ដីថា កាលបើសិស្សមិនជឿស្ដាប់ រមែងមិនបានចាក់ដុះនូវគុណវិសេសឡើយ ។

បទថា បារិចរិយាយ (ដោយការប្រតិបត្តិតូច ៗ) គឺ ដោយការបម្រើតូច ៗ តិច ៗ មិនហួសពីសមត្ថភាព ។ ជាការពិតណាស់ សិស្សគួរក្រោកឡើងអំពីព្រឹកព្រលឹម ឲ្យទឹកខ្ពុរមាត់ ឈើស្ទាំងអាគមធ្មេញ (ច្រាសដុះធ្មេញ) សូម្បីពេលអាហារក៏កាន់ទឹកសម្រាប់ផឹកយកទៅឲ្យ ហើយខ្នះខ្នែងបម្រើ កាលបើរួចស្រេចហើយ ថ្វាយបង្គំត្រឡប់ទៅវិញ គួរបោកគក់សំពត់ដែលប្រឡាក់សៅហ្មង គួរតម្កល់ទឹកសម្រាប់ងូតក្នុងវេលាល្ងាច គួរចូលទៅបម្រើក្នុងពេលដែលលោកមានអាពាធ ។ សូម្បីបព្វជិតក៏គួរធ្វើអន្តេវាសិកវត្តគ្រប់យ៉ាងដែរ ។ នេះលោកសំដៅយកបទថា ដោយការប្រតិបត្តិតូច ៗ ។

បទថា សក្កច្ចំ សិប្បំ បដិគ្គហណេន (ដោយការរៀនសិល្បសាស្ត្រដោយគោរព) មានសេចក្តីថា ការរៀនបន្តិចបន្តួចហើយទន្ទេញច្រើនដង ៗ សូម្បីតែបទមួយ ក៏ត្រូវតែរៀនឲ្យដឹងច្បាស់ ឈ្មោះថា រៀនដោយសេចក្តីគោរព ។

*(គ្រូអាចារ្យសង្គ្រោះសិស្សដោយស្ថាន ៥ យ៉ាង)*

## បិដក

ឥមេហិ ខោ គហបតិបុត្ត បញ្ចហិ ឋានេហិ អន្តេវាសិនា ទក្ខិណា ទិសា អាចរិយា បច្ចុបដ្ឋិតា បញ្ចហិ ឋានេហិ អន្តេវាសឹ អនុកម្បន្តិ សុវិនីតំ វិនេន្តិ សុគ្គហិតំ គាហាបេន្តិ សព្វសិប្បេសុ តំ សមក្ខាយិនោ ភវន្តិ មិត្តាមច្ចេសុ បដិវេទេន្តិ ទិសាសុ បរិត្តាណំ ករោន្តិ ម្នាលគហបតិបុត្ត អាចារ្យជាទិសខាងត្បូង ដែលសិស្សប្រតិបត្តិដោយស្ថាន ៥ យ៉ាងនេះឯងហើយ រមែងអនុគ្រោះសិស្សដោយស្ថាន ៥ យ៉ាងវិញគឺ ដឹកនាំល្អ ១ ឲ្យរៀនល្អ ១ ប្រៀនប្រដៅសិស្សឲ្យចេះត្រឹមត្រូវ ក្នុងសិល្បសាស្ត្រសព្វគ្រប់ ១ តែងលើកតម្កើងក្នុងទីប្រជុំមិត្តអាមាត្យ ១ ធ្វើសេចក្តីការពារក្នុងទិសទាំងឡាយ ១ ។

ឥមេហិ ខោ គហបតិបុត្ត បញ្ចហិ ឋានេហិ អន្តេវាសិនា ទក្ខិណា ទិសា អាចរិយា បច្ចុបដ្ឋិតា ឥមេហិ បញ្ចហិ ឋានេហិ អន្តេវាសី អនុកម្បន្តិ ឯវមស្ស ឯសា ទក្ខិណា ទិសា បដិច្ឆន្នា ហោតិ ខេមា អប្បដិភយា ម្នាល គហបតិបុត្ត ពួកអាចារ្យជាទិសខាងត្បូង ដែលសិស្សប្រតិបត្តិដោយស្ថាន ៥ យ៉ាងនេះឯងហើយ រមែងអនុគ្រោះសិស្សដោយស្ថាន ៥ យ៉ាងនេះ ទិសខាងត្បូងនោះ ដែលសិស្សបានបិទបាំងហើយ ជាទិសមានសេចក្តីក្សេមឥតមានភយន្តរាយយ៉ាងនេះ ។

## អដ្ឋកថា

បទថា សុវិនីតំ វិនេន្តិ (ដឹកនាំល្អ) មានសេចក្តីថា គ្រូអាចារ្យទាំងឡាយ រមែងឲ្យសិស្សសិក្សា គឺណែនាំមារយាទយ៉ាងនេះថា អ្នកគួរអង្គុយយ៉ាងនេះ គួរឈរយ៉ាងនេះ គួរទំពាស៊ីយ៉ាងនេះ គួរបរិភោគយ៉ាងនេះ គួរវៀរមិត្តអាក្រក់ គួរសេពគប់មិត្តល្អ ដូច្នេះ ។

បទថា សុគ្គហិតំ គាហាបេន្តិ (ឲ្យរៀនល្អ) មានសេចក្ដីថា គ្រូអាចារ្យទាំងឡាយ ជម្រះ (ពន្យល់) អត្ថនិងព្យញ្ជនៈ ព្រមទាំងចន្លុលបង្ហាញនូវប្រយោគហើយ ញ៉ាំងសិស្សឲ្យរៀនដោយអាការដែលសិស្សអាចរៀនបានល្អ ។

បទថា មិត្តាមច្ចេសុ បដិវេទេន្តិ (តែងលើកតម្កើងក្នុងទីប្រជុំមិត្តអាមាត្យ) មានសេចក្ដីថា គ្រូអាចារ្យទាំងឡាយពោលអំពីសេចក្ដីល្អរបស់សិស្សយ៉ាងនេះថា សិស្សរបស់ខ្ញុំនេះ ឆ្លាតណាស់ ជាពហុស្សូតប្រហាក់ប្រហែលនឹងខ្ញុំដែរ សូមពួកលោកជឿជាក់សិស្សនេះចុះ ហើយក៏បង្ហាញសិស្សឲ្យប្រាកដក្នុងទីប្រជុំជនទាំងឡាយ ។

បទថា ទិសាសុ បរិត្តាណំ ករោន្តិ (ធ្វើសេចក្ដីការពារក្នុងទិសទាំងឡាយ) មានសេចក្ដីថា គ្រូអាចារ្យរមែងធ្វើការការពារសិស្សក្នុងទីទាំងពួង ដោយឲ្យសិក្សាសិល្បសាស្ត្រ ។ ព្រោះថា លាភសក្ការៈរមែងកើតមានដល់អ្នករៀនសិល្បសាស្ត្រ ក្នុងទីដែលទៅសម្ដែងសិល្បសាស្ត្រ លាភសក្ការៈនោះឯងឈ្មោះថា គ្រូអាចារ្យបានធ្វើហើយ ។ សូម្បីកាលមហាជន ពោលសរសើរអំពីគុណរបស់សិស្ស

នោះ រមែងពោលដល់គុណរបស់គ្រូអាចារ្យមុនថា សិស្ស របស់លោកនេះ ជាសិស្សដែលធ្លាប់លាងជើងគ្រូអាចារ្យ ដូច្នេះ ។ លាភដែលកើតឡើងដល់សិស្សនោះ សូម្បីមាន ប្រមាណដល់ព្រហ្មលោក ក៏ជារបស់គ្រូអាចារ្យនោះឯង ។ ម្យ៉ាងទៀត ចោរទាំងឡាយក្នុងព្រៃ រមែងមើលមិនឃើញ អមនុស្សក្តី ពស់ជាដើមក្តី រមែងមិនបៀតបៀនសិស្សណា ដែលចង់បានវិជ្ជាដើរព្រៃ សូម្បីគ្រូអាចារ្យទាំងឡាយញ៉ាំង សិស្សឲ្យរៀន ក៏ឈ្មោះថា រមែងធ្វើនូវសេចក្តីការពារក្នុង ទិសទាំងឡាយ ។ សូម្បីគ្រូអាចារ្យទាំងឡាយលើកសរសើរ សិស្សយ៉ាងនេះថា សិស្សរបស់ខ្ញុំនៅក្នុងទិសនេះ វិជ្ជា សិល្បសាស្ត្ររបស់សិស្សនេះ ក៏មិនខុសអំពីសិល្បសាស្ត្រ របស់ខ្ញុំដែរ អ្នកចូរទៅសួរសិស្សនោះចុះ ដល់មនុស្សដែល កើតសេចក្តីសង្ស័យអំពីទិសដែលសិស្សនោះទៅ ហើយមក រកខ្លួន ក៏ឈ្មោះថា រមែងធ្វើការការពារ ព្រោះលាភសក្ការៈ ដែលកើតឡើងដល់សិស្សក្នុងទីនោះ អធិប្បាយថា រមែងធ្វើ ឲ្យជាទីពឹង ។ បទដែលនៅសល់ក្នុងរឿងនេះ គប្បីប្រកប ដោយន័យមុននោះឯង ។

# ភរិយាជាទិសខាងលិច

## បិដក

បញ្ចហិ ខោ គហបតិបុត្ត ឋានេហិ សាមិកេន បច្ឆិមា ទិសា ភរិយា បច្ចុបដ្ឋាតព្វា សម្មាននាយ អវិមាននាយ អនតិចរិយាយ ឥស្សរិយវោស្សគ្គេន អលង្ការានុប្បទានេន សិង្គាលគហបតិបុត្ត ភរិយាជាទិសខាងលិច ស្វាមីត្រូវទំនុកបម្រុងដោយស្ថានទាំងឡាយ ៥ យ៉ាង គឺ ដោយការរាប់អានជាភរិយាពេញទី ១ ដោយមិនមើលងាយ ១ ដោយមិនប្រព្រឹត្តក្បត់ចិត្ត ១ ដោយប្រគល់ឲ្យជាធំ (ក្នុងការផ្ទះ) ១ ដោយការឲ្យគ្រឿងតែងខ្លួន ១ ។

## អដ្ឋកថា

គប្បីជ្រាបនូវសេចក្ដីក្នុងវារៈទិសទី ៣ ។

បទថា សម្មាននាយ (ដោយលើកសរសើរ) គឺ ដោយការរាប់អានថាជាភរិយាពេញទី ។

បទថា អវិមាននាយ (ដោយមិនមើលងាយ) មានសេចក្តីថា ដោយមិននិយាយមើលងាយមើលថោក មិនវាយដំប្រំដាក់ដូចជាទាសៈនិងកម្មករជាដើម ដូច្នោះ ៗ

បទថា អនតិចរិយាយ (ដោយមិនប្រព្រឹត្តក្បត់ចិត្ត) មានសេចក្តីថា ស្វាមីមិនប្រព្រឹត្តកន្លងនូវកិរិយារបស់ខ្លួនឯងហើយទៅបម្រើផ្គាប់ផ្គុនស្រីដទៃ ឈ្មោះថា ដោយមិនប្រព្រឹត្តក្បត់ចិត្ត ៗ

បទថា ឥស្សរិយវោស្សគ្គេន (ដោយប្រគល់ឲ្យជាធំ) មានសេចក្តីថា ជាការពិតណាស់ ស្ត្រីទាំងឡាយសូម្បីបាននូវអាភរណៈដូចជាគ្រឿងប្រដាប់មហាលតា តែបើមិនបានចាត់ចែងអាហារមែងក្រោធខឹង កាលស្វាមីប្រគល់ឲ្យនូវវែកដាក់ក្នុងដៃហើយនិយាយថា សូមម៉ែវាចាត់ចែងតាមសេចក្តីគាប់ចិត្តរបស់ម៉ែវាឯងចុះ ដូច្នេះហើយប្រគល់ផ្ទះបាយឲ្យ ឈ្មោះថា ប្រគល់ឲ្យភាពជាធំទាំងអស់ អធិប្បាយថា ដោយការធ្វើយ៉ាងនោះ ៗ

បទថា អលង្កានុប្បទានេន (ដោយការឲ្យគ្រឿងតែងខ្លួន) មានសេចក្តីថា ដោយការឲ្យគ្រឿងប្រដាប់តាមសមគួរដល់សម្បត្តិរបស់ខ្លួន ។

(ភរិយាសង្គ្រោះស្វាមីដោយស្ថាន ៥ យ៉ាង)

**បិដក**

ឥមេហិ ខោ គហបតិបុត្ត បញ្ចហិ ឋានេហិ សាមិកេន បច្ឆិមា ទិសា ភរិយា បច្ចុបដ្ឋិតា បញ្ចហិ ឋានេហិ សាមិកំ អនុកម្បន្តិ សុសំវិហិតកម្មន្តា ច ហោតិ សុសង្គហិតបរិជនា អនតិចារិនី ច សម្ភតញ្ច អនុរក្ខតិ ទក្ខា ច ហោតិ អនលសា សព្វកិច្ចេសុ ម្នាលគហបតិបុត្ត ភរិយាជាទិសខាងលិច ដែលស្វាមីទំនុកបម្រុងដោយស្ថានទាំងឡាយ ៥ យ៉ាងនេះឯងហើយ រមែងអនុគ្រោះស្វាមីដោយស្ថានទាំងឡាយ ៥ យ៉ាងវិញ គឺ ចាត់ចែងការងារដោយល្អ ១ សង្គ្រោះជនជាញាតិទាំងពីរខាងដោយល្អ ១ មិនប្រព្រឹត្តក្បត់ចិត្ត ១ ថែទាំទ្រព្យដែលស្វាមីរកបានមក ១ ឈ្លាសវៃមិនខ្ជិលច្រអូសក្នុងកិច្ចការសព្វគ្រប់ ១ ។

ឥមេហិ ខោ គហបតិបុត្ត បញ្ចហិ ឋានេហិ សាមិកេន បច្ឆិមា ទិសា ភរិយា បច្ចុបដ្ឋិតា ឥមេហិ បញ្ចហិ ឋានេហិ សាមិកំ អនុកម្បន្តិ ឯវមស្ស ឯសា បច្ឆិមា ទិសា បដិច្ឆន្នា ហោតិ ខេមា អប្បដិភយា ម្នាលគហបតិបុត្ត ភរិយា ជាទិសខាងលិច ដែលស្វាមីទំនុកបម្រុងដោយស្ថាន ៥ យ៉ាងនេះឯងហើយ រមែងអនុគ្រោះស្វាមីដោយស្ថាន ៥ យ៉ាងនេះ ទិសខាងលិចនោះ ដែលស្វាមីបិទបាំងហើយ ជាទិសមានសេចក្ដីក្សេម ឥតមានភយន្តរាយយ៉ាងនេះ ។

## អដ្ឋកថា

បទថា សុសំវិហិតកម្មន្តា (ចាត់ចែងការងារដោយល្អ) មានសេចក្ដីថា មិនប្រព្រឹត្តកន្លងវេលាព្រឹក ក្រោកឡើងចម្អិនបបរនិងបាយជាដើម ហើយចាត់ចែងការងារឲ្យល្អ ការធ្វើសេចក្ដីល្អដល់ស្វាមីនោះ ៗ ។

បទថា សុសង្គហិតបរិជនា (សង្គ្រោះជនជាញាតិទាំងពីរខាងដោយល្អ) មានសេចក្ដីថា សង្គ្រោះបរិជនដោយការកោប់អាន និងដោយការផ្ដល់ដំណឹងសុខទុក្ខជាដើម ។

ជនជាញាតិរបស់ស្វាមី និងជនជាញាតិរបស់ខ្លួន ឈ្មោះថា បរិជន ក្នុងទីនេះ ។

បទថា អនតិចារិនី (មិនប្រព្រឹត្តក្បត់ចិត្ត) មានសេចក្តីថា មិនប្រព្រឹត្តក្បត់ចិត្តស្វាមី ហើយប្រាថ្នាបុរសដទៃបួម្បីដោយផ្លូវចិត្ត ។

បទថា សម្ភតំ (ថែទាំទ្រព្យដែលស្វាមីរកបានមក) មានសេចក្តីថា ទ្រព្យដែលស្វាមីធ្វើកសិកម្ម និងពាណិជ្ជកម្មជាដើម ហើយនាំមករក្សាទុកឲ្យបានល្អ ។

បទថា ទក្ខា ច ហោតិ (ជាមនុស្សឈ្លាស) មានសេចក្តីថា ជាមនុស្សឆ្លាតវាងវៃប៉ិនប្រសប់ក្នុងការចាត់ចែងបបរនិងកត្តជាដើម ។

បទថា អនលសា (មិនខ្ជិលច្រអូស) មានសេចក្តីថា ជាអ្នកមិនទម្រន់ ។ ករិយាមិនមែនដូចជាពួកស្រីដទៃ ដែលខ្ជិលច្រអូស អង្គុយសំកុកក្នុងទីដែលខ្លួនអង្គុយហើយ ឈរទ្រឹងនៅក្នុងទីដែលខ្លួនឈរហើយទេ រមែងញាំងកិច្ចការទាំងពួងឲ្យសម្រេចដោយចិត្តទូលំទូលាយស្វាហាប់ ។ គប្បីប្រកបបទដទៃដែលនៅសល់ក្នុងរឿងនេះ ដោយន័យដែលពោលហើយនោះឯង ។

## មិត្តអាមាត្យជាទិសខាងជើង

### បិដក

បញ្ចហិ ខោ គហបតិបុត្ត ឋានេហិ កុលបុត្តេន ឧត្តរា ទិសា មិត្តាមច្ចា បច្ចុបដ្ឋាតព្វា ទានេន បិយវជ្ជេន អត្ថចរិយាយ សមានត្តតាយ អវិសំវាទនតាយ ម្នាល គហបតិបុត្ត មិត្តអាមាត្យជាទិសខាងជើង កុលបុត្តត្រូវប្រតិបត្តិដោយស្ថានទាំងឡាយ ៥ យ៉ាងគឺ ដោយការឲ្យរបស់ ១ ដោយការនិយាយតែពាក្យគាប់ចិត្ត ១ ដោយការប្រព្រឹត្តិឲ្យជាប្រយោជន៍ ១ ដោយការប្រព្រឹត្តិខ្លួនស្មើ ១ ដោយការមិនកុហកបញ្ឆោត ១ ។

### អដ្ឋកថា

គប្បីជ្រាបសេចក្តីក្នុងវារៈទិសទី ៤ ។

បទថា អវិសំវាទនតាយ (ដោយការមិនកុហកបញ្ឆោត) មានសេចក្តីថា ដោយមិនក្លែងពោលពាក្យឲ្យឃ្លាត

ចាកការពិតដល់អ្នកដែលប្រកាន់យកហើយ ។ មិនក្នុង ពោលឲ្យឃ្លាតចាកសេចក្ដីពិត ហើយឲ្យយ៉ាងនេះថា សូម្បី របស់នេះក៏មាននៅក្នុងផ្ទះរបស់ពួកយើង និងរបស់នេះ ក៏មានដែរ លោកចូរទទួលយកទៅចុះ ។

(មិត្តអាមាត្យអនុគ្រោះតបវិញដោយស្ថាន ៥ យ៉ាង)

**បិដក**

